# និមិត្តដ៏សំខាន់

## ការបំពេញមហាបេសកកម្មតាមរយៈការបណ្តុះក្រុមជំនុំគ្រប់ទិសទី

THE ALLIANCE
FOR SATURATION CHURCH PLANTING

# មាតិកា

**កថាផ្តើម**..........៥

**រូបភាពដ៏ធំមួយ**..........៧

មូលដ្ឋានគ្រឹះនៃព្រះបន្ទូល..........៩

មហាបេសកកម្មក្នុងព្រះគម្ពីរ..........១៣

**មូលដ្ឋានគ្រឹះសំរាប់ការបណ្តុះក្រុមជំនុំគ្រប់ទិសទី**..........១៧

និមិត្តៈ  គំនិតនៃ “ទទ”..........១៩

តួនាទីក្នុងការដឹកនាំ..........២១

ក្រុមជំនុំ..........២៥

**កត្តានៃការបណ្តុះក្រុមជំនុំគ្រប់ទិសទី**..........២៩

ចលនានៃការអធិដ្ឋាន..........៣១

ស្រាវជ្រាវៈព័តមានសំរាប់គោលដៅយុទ្ធសាស្ត្រ..........៣៥

ការបំផុសនិមិត្ត..........៤១

ការផ្សាយដំនឹងល្អដែលនាំទៅដល់ការបណ្តុះក្រុមជំនុំ..........៤៥

ការបណ្តុះបណ្តាល..........៥១

ចលនាប្រមូលផ្តុំ..........៥៧

**ការបណ្តុះក្រុមជំនុំគ្រប់គ្រប់ទិសទី-អាចធ្វើទៅបាន !**..........៦១

ឧទាហរណ៍ជាក់ស្តែងខ្លះៗអំពីការបណ្តុះក្រុមជំនុំគ្រប់ទិសទី (កកត)..........៦៣

**ជំហានបន្ទាប់**..........៦៧

**យល់ដឹងអំពី Alliance**..........៦៩

# កថាផ្តើម

ដ្បិតមនុស្សនឹងស្គាល់ដល់សិរីល្អនៃព្រះយេហូវ៉ានៅពេញលើផែនដី ដូចជាទឹកក៏នៅពេញសមុទ្រដែរ។ "ហាបាគុក ២ :១៤"។

រំពឹងគិតជាមួយយើងមួយរយៈពេលខ្លី។ សូមក្រលេកមើលទៅ២៥ឆ្នាំខាងមុខពេលអនាគត។ ប្រសិនបើការបណ្តុះក្រុមជំនុំគ្រប់ទិសទីបានសំរេច នោះនៅឆ្នាំ២០២៥គួរតែមានក្រុមជំនុំថ្មីដែលត្រូវបង្កើតឡើងរាប់រយរាប់ពាន់ទូទាំងភូមិភាគកណ្តាលនិងខាងកើតនៃអឺរ៉ុប ព្រមទាំងអតីតសហភាពសូវៀត។

នៅឆ្នាំ២០២៥គួរតែមានអ្នកបណ្តុះក្រុមជំនុំរាប់ពាន់ក្រុមប្រមូលផ្តុំគ្នាដើម្បីផ្សាយដំនឹងល្អ ព្រមទាំងបណ្តុះក្រុមជំនុំតំបន់រាប់រយទៀត ដែលគេទាំងនោះនឹងបង្វឹកបង្វឹនអោយមានក្រុមដែលបណ្តុះបណ្តាលក្រុមជំនុំថ្មីបន្ថែមទៀត។ គួរតែមានទីកន្លែងសំរាប់ បណ្តុះបណ្តាល ក្រុមជំនុំរាប់រយកន្លែង ដែលជួបជុំគ្នាជាធម្មតានៅតាមផ្ទះ តាមក្រុមជំនុំ ហើយសូម្បីតែនៅតាមហាងកាហ្វេក៏ដោយ។ គួរតែមាន អ្នកអធិដ្ឋានទាំងតមជាច្រើនពាន់នាក់ទៀត ដែលចេញពីនិកាយផ្សេងៗរាប់ពាន់រួមដៃគ្នា ក្នុងការអធិដ្ឋានយ៉ាងសកម្មដើម្បីបង្កើតក្រុមជំនុំថ្មីៗជាច្រើន។

នៅឆ្នាំ២០២៥ អ្នកស្រាវជ្រាវរាប់រយក្រុម មកពីតាមក្រុមជំនុំតំបន់ ដើម្បីធ្វើការសិក្សាអំពី ទីក្រុង និងប្រទេសរបស់គេឬក៏តំបនណាមួយ ដើម្បីអោយដឹងពីទីតាំងដែលអាចអធិដ្ឋាន និង ផ្សាយដំនឹងល្អ ព្រមទាំង ពីទីកន្លែងដែលក្រុមជំនុំថ្មីអាចបង្កើតឡើង។ ហើយនៅឆ្នាំ ២០២៥នេះឯង នឹងមានបេសកជនរាប់រយនាក់ដែលធ្វើព័ន្ធកិច្ចឆ្លងវប្បធម៌ ជាមួយប្រជាជនក្នុងស្រុកដើម្បីបង្កើតក្រុមជំនុំថ្មី។ ពួកគេផ្តោតអារម្មណ៍ខ្លាំងទៅលើប្រជាជននៃសាសនាអ៊ីស្លាមនិងសាសនាព្រះពុទ្ធ។

គួរយើងចងចាំថា ថ្ងៃណាមួយក្នុងឆ្នាំ ២០២៥ មនុស្សដែលមិនទាន់បានសង្គ្រោះ នឹងមានអំណរ ក្នុងការទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់ ដើម្បីបង្កើតក្រុមជំនុំថ្មីនៅកន្លែងផ្សេងៗ ដែលសព្វថ្ងៃនេះមិនទាន់មានពួកជំនុំផ្សាយដំនឹងល្អនៅឡើយ។ ចូរយើងតំកើង និង ថ្វាយសិរីល្អដល់ព្រះដ៏ធំឧត្តមនៃយើង ព្រមទាំងរង់ចាំទទួលនូវគ្រប់កិច្ចការទាំងអស់ដែលទ្រង់ នឹងធ្វើក្នុងយើងហើយ តាមរយះយើង ដើម្បីជួយដល់មនុស្សរាប់ពាន់នាក់ ដែលនឹងត្រូវជួបព្រះអង្គជាលើកដំបូងក្នុងឆ្នាំ ២០២៥ នេះ។

**អ្វីទៅជានិមិត្ត!**

យើងជឿថា ឧបករណ៍ជាចំបងរបស់ព្រះដើម្បីផ្សាយដំនឹងល្អពាសពេញសាកលលោកគឺតាមរយះក្រុមជំនុំតំបន់។ ឯការបណ្តុះក្រុមជំនុំគឺអាស្រ័យទៅលើគោលការណ៍នៃការធ្វើពហុគុណ ដែលជាវិធីសាស្រ្តមួយដ៏ជោគជ័យសំរាប់បំពេញមហាបេសកកម្ម ។ ជាបឋម ក្រុមជំនុំថ្មីៗត្រូវតែមាននិមិត្តក្នុងការបង្កើនចំនួនព្រមទាំងមានលទ្ធភាពក្នុងការផ្តួចផ្តើមក្រុមជំនុំថ្មីៗ។ ការនេះអាចកើតមានឡើង គឺនៅពេលដែលអ្នកចាប់ផ្តើមចលនានៃក្រុមជំនុំថ្មី ដែលអាចឈោងចាប់យកប្រទេសទាំងមូល និងបំផ្លាស់បំប្រែជីវិតមនុស្ស ជាច្រើនក្នុងប្រទេសនោះ។ ដំណើរការនៃការបណ្តុះក្រុមជំនុំនេះត្រូវបានគេហៅថា "ការបណ្តុះក្រុម

ជំនុំគ្រប់ទិសទី"(កកគ)។

គោលបំណងចំបងរបស់ សៀវភៅនេះគឺ ដើម្បីជួយដល់គ្រូគង្វាល អ្នកដឹកនាំក្រុមជំនុំ និងអ្នកបង្កើតក្រុមជំនុំ អោយអាចអភិវឌ្ឍនូវការយល់ដឹងអំពីសារៈសំខាន់ក្នុងការបំពេញដល់ប្រទេសរបស់ផងគេដោយសិរីល្អនៃព្រះតាមរយៈការបណ្តុះក្រុមជំនុំថ្មីៗ។ គោលបំនងនេះមាន៤ផ្នែក។ ផ្នែកទី១ផ្តោតទៅលើសិរីល្អនៃព្រះ និង លក្ខណៈនៃមហាបេសកកម្មផ្សារភ្ជាប់ជាមួយ នឹងការបណ្តុះក្រុមជំនុំ។ ផ្នែកទី២ ជាផ្នែកមួយនៃនិមិត្តរបស់ព្រះ។ ដើម្បីអោយគោលបំណងនេះបានសំរេច ដោយជោគជ័យ យើងត្រូវផ្តោតអារម្មណ៏ទៅលើ "តួនាទីនៃការដឹកនាំ" "គោលបំណងរបស់ក្រុមជំនុំ" "និងនិមិត្តរបស់ព្រះ"។ ផ្នែកទី៣ជា ជំហានសំខាន់ៗជាច្រើននៃការអភិវឌ្ឍន៏ដើម្បីអោយការបណ្តុះក្រុមជំនុំគ្រប់ទិសទីអាចកើតឡើង គឺជាកត្តាដែលត្រូវការក្នុងការអភិវឌ្ឍន៏ចលនានៃការបណ្តុះក្រុមជំនុំថ្មីក្នុងប្រទេសរបស់អ្នក។ ចំពោះផ្នែកចុងក្រោយនេះ មានភ្ជាប់មកនូវឧទាហរណ៏ខ្លះៗ និងជំហានបន្ទាប់ សំរាប់សំរេចនិមិត្តនៃការបង្កើតក្រុមជំនុំគ្រប់ទិសទី ក្នុងតំបន់របស់លោកអ្នក។ គោលបំណងផ្សេងទៀត របស់សៀវភៅនេះគឺផ្តល់អោយអ្នកនូវធនធានដែលអាចយកទៅប្រើដើម្បីបំផុសនិមិត្តខ្លួនអ្នកផ្ទាល់។ សូមអោយព្រះប្រទានពរ និងជួយដល់អ្នកក្នុងការដែលអ្នកថ្វាយសិរីល្អនិងបំរើទ្រង់តាមរយៈជីវិតនិងព័ន្ធកិច្ច។

# រូបភាពដ៏ធំមួយ

ហាបាគុក ២:១៤ " ដ្បិតមនុស្សនឹងស្គាល់ដល់សិរីល្អនៃព្រះយេហូវ៉ា នៅពេញលើផែនដីដូចជាទឹកក៏នៅពេញសមុទ្រដែរ ។




ទំនុកដំកើង ១២៧:១ " បើគ្មានព្រះយេហូវ៉ាសង់ផ្ទះឡើង នោះពួកជាងដែលសង់គេធ្វើការជាឥតប្រយោជន៍ទេ" ។

# ១

# មូលដ្ឋានគ្រឹះនៃព្រះបន្ទូល

## សិរីល្អនៃព្រះ

ព្រះហឫទ័យដ៏ធំឧត្តមរបស់ព្រះគឺលើកសិរីល្អព្រះអង្គទ្រង់។ នៅពេលដែលព្រះសំដែងពីសិរីល្អរបស់ទ្រង់គឺព្រះអង្គ បានបង្ហាញការនោះតាមរបៀបជាច្រើនដូចមានចែងតាមរយះព្រះបន្ទូលខាងក្រោមៈ



⑊ ព្រះទ្រង់បានបង្កើតយើងមកសំរាប់ជាសិរីល្អរបស់ទ្រង់ (អេសាយ ៤៣:៦-៧)

⑊ ព្រះទ្រង់នឹងមិនលាក់សិរីល្អរបស់ទ្រង់ចំពោះអ្នកណាទេ (អេសាយ ៤៨:១១)

⑊ ព្រះបានត្រាស់ហៅជនជាតិអ៊ីស្រាអែលសំរាប់សិរីល្អរបស់ទ្រង់ (អេសាយ ៤៩:៣)

⑊ ព្រះបានរំដោះអ៊ីស្រាអែលពីអេស៊ីព្ទសំរាប់សិរីល្អរបស់ទ្រង់ (ទំនុក ១០៦:៧-៨)

⑊ ព្រះបាននាំអ៊ីស្រាអែលរួចពីភាពជាទាសករសំរាប់សិរីល្អរបស់ទ្រង់ (អេសេគាល ៣៦:២២-២៣)

⑊ ព្រះយេស៊ូបានសំរេចគ្រប់កិច្ចការទាំងអស់ក្នុងសិរីល្អរបស់ព្រះវរបិតា (យ៉ូហាន ១៧:៤)

⑊ ព្រះយេស៊ូឆ្លើយតបនឹងការអធិដ្ឋានដើម្បីសិរីល្អនៃព្រះ (យ៉ូហាន ១៤:១៣)

⑊ ព្រះយេស៊ូរងទុក្ខដើម្បីសិរីល្អនៃព្រះ (យ៉ូហាន ១៧:១, ១៣:៣១-៣២)

⑊ ព័ន្ធកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធ គឺដើម្បីថ្វាយសិរីល្អដល់ព្រះរាជបុត្រានៃព្រះ (យ៉ូហាន១៦:១៣-១៤)

⑊ ព្រះប្រាប់យើងអោយបំរើដើម្បីថ្វាយសិរីល្អដល់ទ្រង់ (១ពេត្រុស ៤:១១)

⑊ ព្រះយេស៊ូនឹងយាងត្រលប់មកវិញដើម្បីជាសិរីល្អនៃព្រះ (ម៉ាថាយ ១៦:២៧, ២៤:៣០)

⑊ នៅក្នុងក្រុងយេរូសាលឹមថ្មីសិរីល្អនៃព្រះជំនួសអោយព្រះអាទិត្យ (វិវរណៈ ២១:២៣)

## សិរីល្អរបស់ព្រះត្រូវបានបង្ហាញ តាមរយះស្នាព្រះហស្តរបស់ទ្រង់

គឺត្រូវបានបង្ហាញតាមរយះស្ថានភាពភិភពលោក។ ទំនុកដំកើង ១៩ លំអិតពីរបៀបជាច្រើនដែលសិរីល្អនៃព្រះត្រូវបានបង្ហាញអោយឃើញ មិនមែនគ្រាន់តែជាផ្កាយនិងភពខុសៗគ្នាជាច្រើនប៉ុណ្ណោះទេ ប៉ុន្តែមានភ្ជាប់ទាំងព្រះបញ្ញោ និង ច្បាប់ទាំងឡាយរបស់ព្រះដែលមានចែងទុកក្នុងព្រះគម្ពីរ។ សូម្បីតែរូបរាងកាយរបស់យើង ក៏បង្ហាញពីសិរីល្អរបស់ព្រះដែរ (ទំនុកដំកើង ១៣៩:១៣-១៦)។

## ព្រះយេស៊ូបង្ហាញសិរីល្អនៃព្រះដល់យើង

យ៉ូហានជំពូក ១ ពណ៌នាអំពីព្រះថាជាព្រះបន្ទូល (ខ១) ហើយថាព្រះបន្ទូលត្រឡប់ទៅជាមនុស្ស ដែលរស់នៅជាមួយយើង

ហើយបានបង្ហាញសិរីល្អរបស់ព្រះដល់យើង (ខ១៤)  ម៉ាថាយ  ម៉ាកុស  និង លូកា  ប្រាប់អំពីសិរីល្អរបស់ព្រះយេស៊ូដែលបានបង្ហាញ អោយឃើញពីលក្ខណៈខ្លះៗ ដូចជាការផ្លាស់ប្រែព្រះភក្ត្រនិងព្រះពស្ត្ររបស់ទ្រង់ (ម៉ាថាយ១៧:១-៨, ម៉ាកុស៩:២-៨, លូកា៩:២៨-៣៦) ។  អ្នកនិពន្ធព្រះគម្ពីរហេព្រើរនិយាយពីព្រះយេស៊ូថា  "គឺទ្រង់ជារស្មីភ្លឺនៃសិរីល្អរបស់ព្រះ"  (ហេព្រើរ ១:៣) ។

**កិច្ចការរបស់ព្រះនាំមកនូវសិរីល្អដល់ទ្រង់**

ព្រះគម្ពីរពិពណ៌នាពីរឿងរ៉ាវជាច្រើនដែលព្រះបានធ្វើហើយ  ដូច្នេះហើយទ្រង់គួរត្រូវបានគេលើកដំកើន ។  ជនជាតិអ៊ីស្រាអែល ត្រូវបានបង្កើតឡើងសំរាប់សិរីល្អនៃទ្រង់ (អេសាយ ៤៣:៦-៧) ។ ទ្រង់បាននាំជនជាតិអ៊ីស្រាអែលចេញពីអេស៊ីព្ទសំរាប់សិរីល្អនៃទ្រង់ (និក្ខមនំ១៤:១៥-១៨, ទំនុក ១០៦:៧-៨) ។ ទ្រង់បានសង្គ្រោះយើងដោយយល់ដល់ព្រះនាមទ្រង់ (អេសាយ ៤៣:២៥, ទំនុកតំកើង ២៥:១១) ។

ព្រះយេស៊ូខិតខំលើកតំកើងដល់ព្រះក្នុងគ្រប់ការទាំងអស់ ។  ទ្រង់ក៏បានអត់ទ្រាំនៅលើឈើឆ្កាងដើម្បីនាំសិរីល្អដល់ព្រះ (យ៉ូហាន ១២:២៨, ១៣:៣១-៣២, ១៧:១-៤) ។

## សេចក្តីពិតនៃព្រះបន្ទូល #១

## បំណងព្រះហឫទ័យដ៏ធំឧត្តមរបស់ព្រះគឺនាំសិរីលដល់ទ្រង់ក្នុងគ្រប់ការទាំងអស់  ហើយអោយសិរីល្អរបស់ទ្រង់គ្របដណ្តប់រឺបំពេញនៅលើផែនដីទាំងមូល ។

មានជាច្រើនកន្លែងដែលនិយាយអំពីសិរីល្អនៃព្រះបំពេញមកលើផែនដី (ជនគណនា ១៤:២១, ទំនុកតំកើង ១០៨:៥, ហាបាគុក ២:១៤) ។ អត្ថបទខាងលើនេះ មិនមែនមានន័យថា  ឥលូវនេះសិរីល្អរបស់ព្រះមិនបានបំពេញមកផែនដីទាំងមូលនោះទេ តែសិរីល្អនៃព្រះ   នឹងត្រូវបានគេដឹងពាសពេញផែនដីតាមរយះមនុស្សទាំងអស់វិញ  (ទំនុកតំកើង ១០២:១៥, អេសាយ ៦៦:១៨, វិវរណៈ ១៥:៤) ។

## សេចក្តីពិតនៃព្រះបន្ទូល #២:  ព្រះទ្រង់មានផែនការដើម្បីសំរេចបំណងព្រះហឫទ័យរបស់ទ្រង់

ព្រះបានប្រទានពរដល់យើងក្នុងចំណែកនៃផែនការរបស់ទ្រង់ដើម្បីបំពេញផែនដីនេះដោយសិរីល្អនៃទ្រង់ ។ ព្រះប្រទានពរដល់ប្រជារាស្ត្ររបស់ទ្រង់  ដើម្បីបង្ហាញពីព្រះគុណទ្រង់ និងបំបែរអារម្មណ៍ជាតិសាសន៍ទាំងឡាយមកឯទ្រង់ ។  ម្យ៉ាងវិញទៀតគ្រប់ជាតិសាស៍ទាំងឡាយចែកចាយព្រះពរដែលព្រះបានផ្តល់មកអោយដល់គ្នាទៅវិញទៅមក (លោកុប្បត្តិ ១២:១-៣, អេសាយ ៤៩:៦, កិច្ចការ ៣:២៥-២៦) ។  មួយវិញទៀតព្រះប្រទានពរដល់រាស្ត្ររបស់ផងទ្រង់ដើម្បីបង្ហាញអោយគ្រប់ទាំងជាតិសាសន៍បានឃើញពីភាពខុសគ្នារវាង ពួកគេនិង រាស្ត្ររបស់ទ្រង់  (ទំនុក៦៧:៦-៧) ។ ឧទាហរណ៍  ដូចជារឿងដែលកើតឡើងនៅក្នុងព្រះគម្ពីរនិក្ខមនំ  យើងបានអានអំពីសេចក្តីខ្ទាល់ដែលព្រះបានទំលាក់ដល់ជនជាតិអេស៊ីព្ទ  ប៉ុន្តែទ្រង់មិនបានធ្វើអោយប៉ះពាល់ដល់ជនជាតិហេព្រើរដែលជា ជនជាតិរបស់ទ្រង់ទេ (និក្ខ៩:៤-៧, ២៥-២៦, ១០:២៣) ។

**ព្រះប្រើយើងអោយប្រាប់ដល់អ្នកដទៃពីសិរីល្អនៃទ្រង់**

ព្រះប្រើប្រជាជនដែលទ្រង់បានជ្រើសរើស ដើម្បីសំរេចគោលដៅនៃការ នាំអោយអ្នកដទៃស្គាល់នូវសិរីល្អរបស់ទ្រង ពាសពេញផែនដី។ សិរីល្អនេះនឹងត្រូវបានបង្ហាញនៅពេលដែលប្រជាជនគ្រប់ទាំងសាសន៏បានផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់ក្នុងព្រះគ្រីស្ទយេស៊ូ (អេភេសូ ១:៩-១០)។

## សេចក្តីពិតនៃព្រះបន្ទូល #3: ព្រះនឹងប្រើក្រុមជំនុំរបស់ទ្រង់

ព្រះទ្រង់បានផ្តល់នូវអំនាចនិងសិទ្ធិដល់ក្រុមជំនុំដើម្បីសំរេចគោលបំណងរបស់ទ្រង់។ នៅក្នុងម៉ាថាយ២៨:១៨-២០ យើងបានអានអំពីព្រះគ្រីស្ទដែលប្រាប់ពីសិទ្ធិអំណាចនៃអង្គទ្រង់នៅពេលដែលទ្រង់ចាត់សិស្សអោយចេញទៅដើម្បី បង្កើតសិស្សថែមទៀត ។ ព្រះយេស៊ូក៏បានសន្យាថានឹងបង្កើតក្រុមជំនុំរបស់ទ្រង់ ហើយសូម្បីតែទ្វានរកក៏គ្មានអំណាចរារាំងផង (ម៉ាថាយ១៦:១៨-១៩)។

**ព្រះស្រឡាញ់ក្រុមជំនុំទ្រង់**

ក្រុមជំនុំត្រូវរាប់ថាជាកូនក្រមុំរបស់ព្រះគ្រីស្ទ (អេសាយ៦២:៥, អេភេសូ ៥:២៥-២៧) និងជា " រូបកាយរបស់ផងព្រះគ្រីស្ទ " (១កូរិនថូស ១២:២៧) ដែលត្រូវបានទិញដោយព្រះលោហិតនៃព្រះគ្រីស្ទ (១ពេត្រុស១:១៩)។

**ព្រះទ្រង់សព្វព្រះទ័យប្រើក្រុមជំនុំទ្រង់**

ព្រះបានផ្តល់ព័ន្ធកិច្ចមួយដល់យើង (ម៉ាថាយ២៨:១៨-២០) ហើយបានសន្យាថាផ្តល់រង្វាន់ដល់អ្នកដែលមានជំនឿពិត (២ទីតុស៤:៨, វិវរណៈ ២:១០)។

**បំណងព្រះហឬទ័យរបស់ព្រះនឹងត្រូវសំរេច ទោះជាបីគ្មានរាស្ត្ររបស់ផងទ្រង់**

ព្រះបានជ្រើសរើសសាំសុនដើម្បីអោយរំដោះជនជាតិអ៊ីស្រាអែលពីភាពជាទាសករនៃប៉ាលេស្ទីន។ សាំសុនដូចជាមិនចាប់អារម្មណ៏ជាមួយនឹងផែនការណ៏របស់ព្រះសោះ តែគាត់បានសំរេចការនោះហូតដល់គាត់បាត់បង់ជីវិត (ចៅហ្វាយ ១៣:១៦)។ អ្នកស៊ើបការទាំង១២នាក់បានចូល ទៅស៊ើបការក្នុងទឹកដីមួយ។ ១០នាក់ក្នុងចំនោមពួកគេបាននិយាយថា ពួកយើងមិនអាច ដណ្តើមយកទឹកដីនោះបានទេ។ ឯពីនាក់ទៀតជឿលើព្រះហើយនិយាយថា គឺពិតជាអាចយកបានព្រោះព្រះនឹងជួយយើង (ជនគណនា១៣-១៤)។ ព្រះនឹងសំរេចគោលបំណងរបស់ទ្រង់ តើអ្នកព្រមធ្វើការជាមួយនឹងទ្រង់ទេ?

# ២

# មហាបេសកកម្មក្នុងព្រះគម្ពីរ

នៅក្នុងមហាបេសកកម្មព្រះយេស៊ូបានបញ្ជាក់យ៉ាងច្បាស់ពីបំណងព្រះហឫទ័យរបស់ទ្រង់ចំពោះក្រុមជំនុំទម្រាំទ្រង់យាងត្រលប់មកវិញ។



## ១, កិច្ចការៈ បង្កើតសិស្ស

លក្ខណៈសំខាន់បំផុតនៃមហាបេសកកម្មស្ថិតនៅលើព្រះបញ្ជាអោយ "បង្កើតសិស្ស"។ កាតព្វកិច្ចសំខាន់នៃក្រុមជំនុំគឺបង្កើតសិស្ស មិនមែនគ្រាន់តែនាំអោយគេជឿនោះទេ។

**តើការបង្កើតសិស្សមានរួមបញ្ចូលនូវអ្វីខ្លះ?**

### ក, ការជ្រមុជៈ បែរមកឯព្រះគ្រីស្ទ

ការធ្វើបុណ្យជ្រមុជទឹកគឺជាការធ្វើទីបន្ទាល់ជាសាធារណៈអំពីការផ្លាស់ប្រែចិត្ត ដោយសកម្មភាពសំដែងចេញមកខាងក្រៅ គឺបង្ហាញ ប្រាប់ពីការប្រែចិត្តដែលមាននៅខាងក្នុងដែលបញ្ជាក់អំពីសេចក្តីសង្គ្រោះ។ ដើម្បីអោយមនុស្សម្នាក់ខ្លាយជាអ្នកដើរតាមព្រះយេស៊ូគ្រីស្ទ ជាដំបូងគាត់ត្រូវលន់តួរហើយជឿ (ម៉ាកុស១:១៥, កិច្ចការ ២០:២១, ទីតុស ៣:៥)។ ការធ្វើបុណ្យជ្រមុជទឹកគឺជាទីសំគាល់នៃការកើតជាថ្មី ការអត់ទោសបាប និងជីវិតថ្មីដែលមានក្នុងព្រះយេស៊ូគ្រីស្ទ (ម៉ាកុស ១:៤, រ៉ូម ៦:៣-៤)។

### ខ, ការបង្រៀនៈ "អោយដូចអង្គព្រះគ្រីស្ទ"

បំពោះការផ្លាស់ប្រែ សិស្សថ្មីៗ ត្រូវតែទទួលការបណ្តុះបណ្តាលពីអ្នកណាម្នាក់ដែលពួកគេសំរេចចិត្តក្នុងការដើរតាម។ ការផ្លាស់ប្រែរួមបញ្ចូលទាំងការចាប់ផ្តើមមានទំនាក់ទំនងជាមួយព្រះផ្ទាល់តែម្តង។ យើងទទួលព្រះបញ្ជាអោយបណ្តុះបណ្តាលអ្នកជឿអោយក្លាយទៅជា "អ្នកដើរតាម"រឺ "អ្នកធ្វើត្រាប់តាម" ព្រះយេស៊ូគ្រីស្ទ ដោយបង្រៀនពួកគេអោយស្តាប់តាមព្រះបញ្ជា របស់ទ្រង់ (១កូរិនថូស ១១:១)។ ដោយព្រោះតែមានសិស្សដើរតាមព្រះយេស៊ូច្រើនទៅៗនោះពួកគេអាចបន្តដំនើរការនៃការបង្រៀនសិស្សថ្មីៗថែមទៀត។

## ២,គោលដៅនៃព្រះបញ្ជា នោះគឺ "គ្រប់ទាំងសាសន៍"

យើងត្រូវបានត្រាស់ហៅមកដើម្បីអោយនាំដំនឹងល្អដល់គ្រប់ទាំងសាសន៍ ពីព្រោះព្រះយេស៊ូបានលោះយើងរាល់គ្នា

ដោយព្រះលោហិតទ្រង់ "ចេញពីគ្រប់ទាំងពូជមនុស្ស គ្រប់ភាសា គ្រប់នគរ ហើយពីគ្រប់ទាំងសាសន៍ថ្វាយដល់ទ្រង់" (វិវរណៈ ៥:៩) ។ សាវ័កយ៉ូហានមានអភ័យឯកសិទ្ធិឃើញក្នុងនិមិត្តរបស់លោកពីការសំរេចទាំងអស់តាមព្រះបញ្ជានេះក្នុងរូបភាពនៃស្ថានសួគ៌ ដែលមានមនុស្សមកពី គ្រប់ទាំងសាសន៍ដើម្បីថ្វាយបង្គំព្រះអម្ចាស់ (វិវរណៈ ៧:៩) ។

**តើជាតិសាសន៍ជាអ្វី?** ភាសាក្រិចសំរាប់ពាក្យជាតិសាសន៍នៅក្នុងអត្ថបទនេះគឺ (ethnos) ។ ពួកកុលសម្ពន្ធ (ethnic) គឺជាមនុស្សមួយក្រុមដែលរស់នៅជាមួយគ្នាមាន ភាសា វប្បធម៌ និងទំនៀមទំលាប់ដូចគ្នា ។ ប្រទេសមួយអាចមានកុលសម្ពន្ធ (ethnic) ជាច្រើនដែលរស់នៅក្នុងចំនោមពួកគេនិមួយៗ ហើយកុលសម្ពន្ធនិមួយៗត្រូវទទួលបាននូវការប្រកាសដំនឹងល្អជាភាសាផ្ទាល់ខ្លួនតាមរយៈ វប្បធម៌និងទំនៀមទំលាប់របស់ពួកគេ បើសិនជាយើងធ្វើតាមមហាបេសកកម្ម ដោយនាំដំនឹងល្អដល់ "គ្រប់ទាំងសាសន៍" ។

តើមានកុលសម្ពន្ធ (ethnic) ចំនួនប៉ុន្មាននៅក្នុងភូមិភាគរបស់អ្នក?"

## ៣.ព្រះបញ្ជានេះស្ថិតស្ថេរនៅ "រហូតដល់អស់កល្ប"

- ◆ គ្រប់ទាំងសិទ្ធិអំណាច
- ◆ គ្រប់ទាំងជនជាតិ
- ◆ គ្រប់ទាំងរបស់
- ◆ គ្រប់ទាំង ថ្ងៃ

តាមរយៈពាក្យថា "រហូតដល់អស់កល្ប" ព្រះយេស៊ូបង្ហាញសេចក្តីបង្រៀនទាំងនេះដល់ក្រុមជំនុំទាំងមូលរហូតដល់ ទ្រង់យាងត្រលប់មកវិញគឺមិនត្រឹមតែដល់សាវ័កទាំង១២ប៉ុណ្ណោះទេ ។ យើងត្រូវតែរក្សាទុកនូវព្រះបញ្ជាទាំង៣នេះគឺ (បង្កើត ធ្វើបុណ្យជ្រមុជ និង បង្រៀនសិស្ស) "រហូតដល់អស់កល្ប" គឺថារហូតដល់ព្រះយេស៊ូ យាងត្រលប់មកក្រុមជំនុំទ្រង់វិញ ។ នៅពេលនោះទីបន្ទាល់អំពីព្រះគ្រីស្ទនឹងត្រូវបាន "ប្រកាសក្នុងសាកលលោកទាំងមូលដល់គ្រប់ទាំងសាសន៍" (ម៉ាថាយ ២៤:១៤) ។

## ៤. សេចក្តីសន្យា

យើងអាចដើរឆ្ពោះទៅមុខដោយទំនុកចិត្ត! យើងមិនដើរតែឯងទេ ។ សិទ្ធិអំណាច និងការធានារ៉ាប់រងនៃយើងគឺស្ថិតក្នុងអង្គព្រះយេស៊ូគ្រីស្ទផ្ទាល់ ដែលសន្យាថានឹងគង់ជាមួយយើងរហូតទាល់តែបេសកកម្មបានសំរេច ។

### មហាបេសកកម្ម និងការបណ្តុះក្រុមជំនុំគ្រប់ទិសទី

ដោយយោងទៅតាមព្រះគម្ពីរ ម៉ាថាយ ២៤:១៤, ម៉ាកុស ១៣:១០, លូកា ២៤:៤៥-៤៧ និង កិច្ចការ ១:៨ មហាបេសកកម្មនឹងត្រូវបានបំពេញនៅពេលដែលមានសិស្សក្នុងគ្រប់ទាំងសាសន៍ ។ ការបណ្តុះក្រុមជំនុំគ្រប់ទិសទីត្រូវធ្វើឡើងតាមទិសដៅ និងគោលដៅយ៉ាងប្រសើរបំផុតនៃមហាបេសកកម្ម ។

### មហាបេសកកម្មនិងគោលបំណងនៃក្រុមជំនុំ

ការបំពេញមហាបេសកកម្មគឺជាកាតព្វកិច្ចរបស់ក្រុមជំនុំ ។ ក្រុមជំនុំមិនមែនមានឡើងដើម្បីបំរើខ្លួនឯងទេ រឺធ្វើតាមតែកម្មវិធីរបស់ខ្លួន តែត្រូវនាំដំនឹងល្អទៅដល់ "គ្រប់ទាំងសាសន៍" ។ ការឈោងចាប់ផ្នែកខាងក្រៅរបស់ក្រុមជំនុំមិនមែនគ្រាន់

តែជាផ្នែកមួយនៃបេសកកម្មទាំងឡាយនោះទេ គឺជាហេតុផលដែលក្រុមជំនុំយើងមានឡើង ។

ក្រុមជំនុំគួរតែរីកលូតលាស់តាមរយះការផ្សាយដំនឹងល្អ និងបង្កើតសមាជិងខ្លួនឯងតាមរយះការបណ្ដុះក្រុមជំនុំដែលបណ្ដាលអោយមនុស្សជាច្រើនក្លាយជាសិស្សរបស់ព្រះយេស៊ូគ្រីស្ទ ។ កម្មវិធីនិងព័ន្ធកិច្ចនៃក្រុមជំនុំគួរតែវាយតំលៃនិងអភិវឌ្ឍដោយយោងថា តើគេបំរើទៅតាមគោលដៅបានល្អប៉ុណ្ណាដែរ ។ តើកម្មវិធីនិងព័ន្ធកិច្ចរបស់អ្នកផ្ដល់នូវលទ្ធផលដែររឺទេ នៅក្នុងរបៀបនៃការបង្កើតសិស្សដែលព្រះ,យេស៊ូទ្រង់សព្វព្រះទ័យនៅពេលដែលទ្រង់ផ្ដល់នូវមហាបេសកកម្មនោះ?




**មហាបេសកកម្ម និងការបណ្ដុះក្រុមជំនុំ**

ការបណ្ដុះក្រុមជំនុំថ្មីគឺបំពេញទៅតាមព្រះបញ្ញាដែលប្រាប់អោយ "បង្កើតសិស្ស" តាមរយះការផ្សាយដំនឹងល្អដោយធ្វើទៅតាមការបណ្ដុះបណ្ដាលអ្នកជឿថ្មីនិង អប់រំសិស្សជាបន្ត ។ ការនេះនឹងសំរេចជាលទ្ធផលបានតាមរយះការបង្កើតអ្នកដឹកនាំថ្មីសំរាប់ក្រុមជំនុំថ្មីៗ ដែលក្រុមជំនុំទាំងនេះអាចយល់ពីគោលដៅនិងហេតុផលដែលមានក្រុមជុំនុំនេះឡើង ដើម្បីនឹងបង្កើតក្រុមជំនុំថ្មីៗទៀតដែលមានហេតុផលដូចគ្នា ហើយធ្វើដូច្នេះក្នុងន័យផ្ដល់អត្ថប្រយោជន៏ក្នុងការផ្សព្វផ្សាយដំនឹងល្អដល់ "គ្រប់ទាំងសាសន៏" ។

អ្នកបណ្ដុះក្រុមជំនុំនិងអ្នកដែលចូលរួមក្នុងការចាប់ផ្ដើមក្រុមជំនុំថ្មីៗ គឺមានចំណែកក្នុងយុទ្ធសាស្ត្រនៃព័ន្ធកិច្ចដ៏សំខាន់មួយ ព្រោះថាវាបានបញ្ចូលយ៉ាងពេញលេញតាមគោលការណ៏ដែលបានបង្រៀនក្នុងមហាបេសកកម្ម ។ និយាយអោយស្រួលស្ដាប់ទៅ ការបណ្ដុះក្រុមជំនុំជាវិធិសាស្ត្រដ៏ល្អប្រសើរបំផុតក្នុងការ បំពេញមហាបេសកកម្ម ។

**មហាបេសកកម្មនិង "ការបង្កើតសិស្សគ្រប់ជាតិសាសន៏"**

មិនមែនដូចជាព្រះវិហារនៅក្នុងជំនាន់សញ្ញាចាស់ទេ ផ្ទុយទៅវិញ ក្រុមជំនុំត្រូវបានបង្កើតឡើងដើម្បីបង្ហាញពីសិរីល្អនៃព្រះដល់គ្រប់ទាំងជាតិសាសន៏ ។ កំពង់ដែលធ្វើដំណើរចេញទៅ បេសកកម្មរបស់ក្រុមជំនុំគឺត្រូវតែបង្កើតសិស្សដល់គ្រប់ទាំងមនុស្សជាតិ ឬគ្រប់កុលសម្ពន្ធ គឺថា "គ្រប់ទាំងសាសន៏" ។ ដើម្បីអោយមានប្រសិទ្ធិភាពក្រុមជំនុំត្រូវតែបង្កើតសិស្សនៅគ្រប់ទាំងជាតិសាសន៏ ។

អ្វីទៅជា "ការបង្កើតសិស្សគ្រប់ជាតិសាសន៏"? ការបង្កើតសិស្សគ្រប់ជាតិសាសន៏គឺជាការដែលគ្រប់មនុស្ស គ្រប់កុល

សម្ពន្ធមានឱកាសនឹងលឺ ហើយយល់ពីដំនឹងល្អនៃព្រះយេស៊ូគ្រីស្ទ គឺដើម្បីអោយមនុស្សម្នាក់ៗអាចទទួលរឺបដិសេធព្រះយេស៊ូគ្រីស្ទជាព្រះអង្គសង្គ្រោះ ។ ការដឹកនាំមនុស្សអោយប្រែចិត្តនិងជឿលើព្រះគ្រីស្ទ អោយមានកំនើតខាងវិញ្ញាណនិងបណ្តុះបណ្តាលគេអោយក្លាយជាអ្នកដើរតាមដែលនឹងធឹងក្នុងព្រះគ្រីស្ទ និងរីកចំរើនខាងព្រលឹងវិញ្ញាណគឺជាទិសដៅដ៏ល្អបំផុតក្នុងការបំពេញបេសកកម្មក្រុមជំនុំតំបន់ ។ ដូច្នេះហើយ "ការបង្កើតសិស្សគ្រប់ទាំងជាតិសាសន៍" ជាសហាគមន៍ទីបន្ទាល់នៃអ្នកជឿដែលប្រកបគ្នាតាមក្រុមជំនុំតំបន់នៅក្នុងភូមិសាស្ត្រ វប្បធម៌និងភាសាតាមជនជាតិនិមួយៗ ។ ក្រុមជំនុំមួយចំនួនដែលបានបណ្តុះឡើងទាំងមានការរីកចំរើននៅតាមតំបន់ដែលផ្តល់អោយ ដូចជា ទីរួមខេត្ត ទីក្រុង ជនបទ រឺតាមតំបន់ដោយដឹងថាមនុស្សទាំងអស់ នៅក្នុងតំបន់នោះពិតជាមានឱកាស លឺនិងឆ្លើយតបទៅនឹងដំណឹងល្អ ។ ក្រុមជំនុំមួយចំនួនដែលរីកចំរើនក្នុងតំបន់នោះគឺជាអត្ថប្រយោជន៍ដ៏ប្រសើរបំផុតសំរាប់នាំការប្រោសលោះដល់សង្គម ។

✱✱✱✱

# មូលដ្ឋានគ្រឹះសំរាប់ការ

# បណ្តុះក្រុមជំនុំគ្រប់ទិសទី

ហាបាគុក ២:១៤ " ដ្បិតមនុស្សនឹងស្គាល់ដល់សិរីល្អនៃព្រះយេហូវ៉ា នៅពេញលើផែនដីដូចជាទឹកក៏នៅពេញសមុទ្រដែរ ។




ទំនុកដំកើង ១២៧:១ " បើគ្មានព្រះយេហូវ៉ាសង់ផ្ទះឡើង នោះពួកជាងដែលសង់គេធ្វើការជាឥតប្រយោជន៍ទេ" ។

# ៣



## និមិត្តិៈ គំនិតនៃ "អ"

ហេតុអ្វីបានជានិមិត្តមានសារៈសំខាន់ខ្លាំងម្ល៉េះសំរាប់ក្រុមជំនុំនៅសតវត្សទី ២១នេះ? ពីព្រោះតែនិមិត្តផ្តល់នូវគោលដៅនៃព័ន្ធកិច្ច។ វាឆ្លើយតបទៅនឹងសំនួរថា "តើព័ន្ធកិច្ចនឹងឆ្ពោះទៅទីណា?" វាបាននាំមកនូវអនាគត់អោយស្ថិតនៅក្នុងការផ្តោតអារម្មណ៍យ៉ាងច្បាស់លាស់សំរាប់ទាំងអ្នកដឹកនាំ និង សមាជិក តាមក្រុមជំនុំតំបន់។ និមិត្តមានសារៈសំខាន់ណាស់សំរាប់ក្រុមជំនុំ។ បើគ្មានទស្សននេះទេ ក្រុមជំនុំឯកឯងជាច្រើននឹងទៅជាក្រិន រឺក៏អាចស្លាប់ក៏ថាបាន។ "បើសិនជារាស្ត្ររបស់ផងព្រះចង់បំពេញកិច្ចការដ៏ធំអោយបានសំរេចថ្វាយទ្រង់ គេត្រូវតែដឹងថា តើអ្វីទៅដែលពួកគេត្រូវចាប់ផ្តើមធ្វើដើម្បីបង្កើយការនោះ" (អូប្រេយ ម៉ាលហ្វឺរ Aubrey Malphurs)។ លោកឪពុកនៃបេសកកម្មបែបថ្មី ឈ្មោះ វីលៀម ការេ (William Carey) មានប្រសាសន៏ថា "ចង់បានកិច្ចការធំមកពីព្រះ ខំធ្វើកិច្ចការធំថ្វាយព្រះ"។ តើយើងដឹងថាចង់បានកិច្ចការអ្វីរឺខំធ្វើកិច្ចការអ្វីបានយ៉ាងដូចម្តេចទៅបើសិនជាគ្មាននិមិត្តសោះ។ គំនិតនៃ "**អ**"គឺចង់ចង្អុរបង្ហាញអំពីនិមិត្តខាលើនេះ។

**តើគំនិតនៃ "អ" មានអត្ថន័យយ៉ាងដូចម្តេច?**

អក្សរ "អ" គឺជាអក្ខរក្រមចុងក្រោយគេបំផុតនៃភាសាខ្មែរយើង។ សាមញ្ញបំផុតនោះ គំនិតអំពី "អ" គឺយើងផ្តើមគិតចាប់ពីចុងក្រោយគេបំផុតនៃគំនិត។ តើព្រះទ្រង់សព្វព្រះហឫទ័យធ្វើអ្វីជាចំបង? គឺទ្រង់សព្វព្រះហឫទ័យនាំសិរីល្អដល់ទ្រង់ដោយការផ្សះផ្សាររវាងមនុស្សនិងព្រះអង្គតាមរយៈព្រះយេស៊ូគ្រីស្ទ (១ធីម៉ូថេ ២:៣-៤, ២ពេត្រុស ៣:៩)។ បំណងព្រះហឫទ័យរបស់ព្រះ គឺដើម្បីអោយមនុស្ស ប្រុស ស្រី រួមទាំងក្មេងៗ បានលឺហើយយល់អំពីដំនឹងល្អ។ តើគ្រប់គ្នាអាចមានឱកាសបានយល់ និង លឺបានដោយរបៀបណា? លោក ពេត្រុស វ៉ាញ៉ូរ (Peter Wagner) និយាយយ៉ាងដូច្នេះថា "វិធីសាស្ត្រផ្សាយដំនឹងល្អតែមួយគត់ដែលមានប្រសិទ្ធិភាពជាងគេបំផុតនៅក្រោមផ្ទៃមេឃ នោះគឺ ការបណ្តុះក្រុមជំនុំថ្មីៗ (លោក ពេត្រុស វ៉ាញ៉ូរ, Peter Wagner, ការបណ្តុះក្រុមជំនុំ សំរាប់ចំរូតដ៏ធំអស្ចារ្យ, ទំ១១)។

មានរឿងជាច្រើនដែលយើងត្រូវធ្វើនៅក្នុងព័ន្ធកិច្ច ដើម្បីអោយ "អ" កើតឡើង។ បើសិនជាយើងគិតអំពីលទ្ធផលចុងក្រោយ, "អ" ហើយធ្វើការត្រលប់មករក "ក" (ជាកន្លែងដែលយើងកំពុងនៅឥលូវនេះ) ជំហានបន្តបន្ទាប់ទៀតនឹងកាន់តែច្បាស់ច្បាស់ឡើង។ យើងត្រូវតែកំនត់អោយច្បាស់ពីចំនុចនិមួយៗ គឺពីជំហានចុងក្រោយ ឆ្ពោះទៅរកជំហានដំបូងដោយជំហាននិមួយៗ ដែលត្រូវតែចាប់ផ្តើមឡើងពីចំនុចដែលស្ថិតនៅឥលូវ ឆ្ពោះទៅចំនុចដែលយើងត្រូវឈានទៅដល់កន្លែង"**អ**"។ តាមរយៈ "អ" យើងមិនមែនមានន័យថាជា គោលដៅផ្ទាល់ខ្លួន ដូចជាអាគាសំរាប់ក្រុមជំនុំរបស់អ្នក រឺក៏ការលូតលាស់នៃព័ន្ធកិច្ចរបស់អ្នកនោះទេ។ យើងកំពុងតែនិយាយអំពី គោលដៅមួយដែលធំជាងគោលដៅផ្សេងទៀតរបស់យើង រឺក្រុមណាមួយ

ដទៃទៀត ។ យើងកំពុងតែនិយាយអំពីគោលដៅដែលអាចសំរេចទៅបានដោយសារព្រះ ។ នៅក្នុងចំនុចនេះ "អ" គឺជាការបណ្តុះឡើងនៃក្រុមជំនុំជាច្រើន ដែលគ្រប់គ្នានៅក្នុងប្រទេសរបស់អ្នកនឹងមានក្រុមជំនុតំបន់នៅជិតល្មម មិនមែនគ្រាន់តែលឺដំ-នឹងល្អនោះទេ ប៉ុន្តែបានឃើញផ្ទាល់នៅក្នុងជីវិតនៃរាស្ត្ររបស់ផងព្រះទៀតផង ។

អ្វីទាំងអស់ដែលយើងធ្វើក្នុងព័ន្ធកិច្ច គួរតែមានការចូលរួម ហើយដឹកនាំទៅការការយល់ច្បាស់ពីបំណងព្រះហឬទ័យ ព្រះគឺថា: ដែលផែនដីទាំងមូលត្រូវពេញដោយសិរីល្អនៃព្រះ ។ នៅពេលដែលយើងបោះជំហានទៅដល់ "អ" ដែលបានគ្រោងទុកច្បាស់ហើយយើងត្រូវតែបន្តសួរខ្លួនឯងទៀតថា "តើព័ន្ធកិច្ចរបស់យើងកំពុងនាំឆ្ពោះទៅរកចំនុច"អ" ដែលជាគោលដៅ ចុងក្រោយ រឺទេ?"

បើ "អ"កើតឡើង នោះនឹងមានក្រុមជំនុំគ្រប់ទីកន្លែងដែលមនុស្សគ្រប់គ្នាអាចចូលរួមបាន ។

ការផ្សាយដំនឹងល្អ រឺការបំពេញដំនឹងល្អដល់គ្រប់ជាតិសាសន៏ដោយក្រុមជំនុំបានធ្វើឡើងឆ្ពោះទៅរកគោលដៅដែលមនុស្សទាំងអស់បានឃើញហើយបានលឺដំនឹងល្អ ។ ដូច្នេះការបណ្តុះក្រុមជំនុំគ្រប់ទិសទី ជាលទ្ធផលរបស់គំនិតនៃ "អ" ពីព្រោះតាមរយះក្រុមជំនុំនេះហើយដែលសិស្ស ត្រូវបានបង្កើតឡើង ។ ហើយកិច្ចការ ថ្វាយបង្គំ ការអធិដ្ឋាន សេចក្តីស្រលាញ់ ការអោយ ការផ្សាយដំនឹងល្អ ការអធិប្បាយ ការបង្រៀន ការរួបរួម និងនិមិត្តអាចជាការលើកទឹកចិត្តយ៉ាងខ្លាំង ។

បើ "អ" កើតឡើង នោះនឹងមានក្រុមជំនុំគ្រប់ទីកន្លែងដែលមនុស្សគ្រប់គ្នា អាចចូលរួមបាន ។ ទូទាំងជាតិសាសន៏ ទីក្រុង ភូមិភាគ ត្រូវតែពេញទៅដោយសិរីល្អនៃព្រះ និងតាមរយះក្រុមជំនុំនៃទ្រង់ ។ នេះហើយដែលព្រះទ្រង់សព្វព្រះហឬទ័យ ហើយនេះឯងដែលជានិមិត្តរបស់យើង ។

👍👍👍👍

# ៤

# តួនាទីនៃការដឹកនាំ

បើសិនជាមានកត្តាមួយដែលសំខាន់ចំពោះជោគជ័យនៃសកម្មភាពមួយ កត្តានោះគឺជា "ការដឹកនាំ" ។ លក្ខណៈគ្រឹះនៃការដឹកនាំ គឺ ការជះឥទ្ធិពល ។ អ្នកដឹកនាំដឹងពីកន្លែងដែលគេត្រូវទៅ ហើយក៏មានសមត្ថភាពជំរុញទឹកចិត្តអ្នកដទៃអោយទៅដល់ទីនោះជាមួយនឹងគេដែរ ។ អ្នកដែលអាចនាំអ្នកដទៃអោយទទួលបានជោគជ័យនោះគឺជាអ្នកដែលមានសមត្ថភាពជំរុញអ្នកទាំងនោះអោយឆ្ពោះទៅរក កិច្ចសហប្រតិបត្តិការណ៍ ការខិតខំក្នុងការងារ ហើយនៅពេលចាំបាច់ត្រូវលះបង់ផលប្រយោជន៍ ផ្ទាល់ខ្លួនផង ។ នេះមិនមែនមានន័យថា ការដឹកនាំមានលក្ខណៈតែមួយបែបនោះទេ ។ តែមានគន្លឹះសំខាន់មួយដែល អ្នកដឹកនាំ ទាំងអស់ត្រូវមាន: គឺជាសមត្ថភាពក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ ។ អ្នកដឹកនាំនឹងមិនអាចទទួលបានជោគជ័យនោះឡើយ លុះត្រាតែគាត់អាចរៀនដោះស្រាយបញ្ហាជាមួយអ្នកឯទៀតបានសិន ។

> លក្ខណៈគ្រឹះ នៃការដឹកនាំ គឺ "ការជះឥទ្ធិពល" ។ អ្នកដឹកនាំដឹងពីកន្លែងដែលគេត្រូវទៅ ហើយក៏មានសមត្ថភាពជំរុញទឹកចិត្តអ្នកដទៃអោយ ទៅដល់ទីនោះជាមួយនឹងគេដែរ ។

ដោយផ្អែកទៅលើផែនការនៃការសោយរាជរបស់ព្រះជាម្ចាស់ ទ្រង់បានរើសតាំងអ្នកដឹកនាំដើម្បីផ្តើម និងអភិវឌ្ឍចលនានៃការបណ្តុះក្រុមជំនុំ ។ ចលនានៃការបណ្តុះក្រុមជំនុំរួមមានលក្ខណៈផ្សេងៗនៃអ្នកដឹកនាំ និងការជះឥទ្ធិពលតាមករិតផ្សេងៗគ្នាគឺជាជីវិតនៃក្រុមជំនុំ ។ ជាទូទៅ អ្នកដឹកនាំជាតិនានា លើកទឹកចិត្តដល់និកាយនិងប្រទេសជាតិដើម្បីពង្រីកអាណាចក្ររបស់ខ្លួន ។ រីឯអ្នកដឹកនាំជាច្រើនទៀតរួមទាំង គ្រូគង្វាល និងអ្នកផ្សាយដំនឹងល្អ ជះឥទ្ធិពលផ្ទាល់ក្នុងចំនោមពួកគេដើម្បីពង្រឹងភូមិភាគរបស់ខ្លួន ។ ធម្មតា "ជាមូលដ្ឋាន" អ្នកដឹកនាំតំបន់តែងតែដើរតួយ៉ាងសំខាន់ក្នុងមុខតំនែងរបស់ខ្លួន ។ ជាធម្មតាអ្នកដឹកនាំទាំងនេះច្រើនតែធ្វើការជាវិស្វករ គ្រូបង្រៀន រឺជាអ្នកគិតលុយនៅផ្សារ ប៉ុន្តែពួកគាត់ស្ម័គ្រផ្តល់នូវកំលាំងពលកម្មរបស់ខ្លួន ក្នុងការពង្រីកនគរព្រះដោយធ្វើជា អ្នកដឹកនាំក្រុមកោសិកា គ្រូគង្វាលស្ម័គ្រចិត្ត អ្នកបណ្តុះក្រុមជំនុំ អ្នកផ្សាយដំនឹងល្អ អ្នកបង្កើតសិស្ស និងអ្នកបង្រួបបង្រួមការអធិដ្ឋាន ។

ចលនានៃការបណ្តុះក្រុមជំនុំត្រូវការអ្នកដឹកនាំជាច្រើនបែបនេះ ទោះបីជាពួកគេធ្វើការតាមក៏រិតនិងរបៀបផ្សេងៗគ្នាក៏ដោយ គង់តែពួកគេមានគោលដៅ និងមានបេសកកម្មដូចគ្នា គឺថាបំពេញមហាបេសកកម្មតាមរយះការបណ្តុះក្រុមជំនុំដែលរីងមាំល្អមដែលអាចបង្កើតក្រុមជំនុំថែមទៀតក្នុងប្រទេសជាតិ និងក្នុងជីវិតរបស់ខ្លួន ។

**អ្នកដឹកនាំគ្រីស្ទានគឺជាបុគ្គលដែលមានៈ**



- **ចារិកលក្ខណៈ**
- **ការជះឥទ្ធិពល**
- **និមិត្ត**

**ចារិកលក្ខណៈ-អ្នកបំរើ**

ការដឹកនាំបែបគ្រីស្ទានត្រូវតែមានលក្ខណៈខុសគ្នា ពីការដឹកនាំខាងលោកិយ មានន័យថាមិនមែនផ្អែកទៅលើ ឋានៈ រឺ អំណាចជាសំខាន់នោះទេ គឺផ្អែកទៅលើ លក្ខណៈជាអ្នកបំរើវិញ។ ព្រះយេស៊ូគឺជាអ្នកបំរើដ៏អស្ចារ្យដែលបានយាងមកលើផែនដីនេះ។ ទ្រង់បានបង្រៀនយ៉ាងច្បាស់ប្រឆាំងចំពោះការដឹកនាំដើម្បីបំរើប្រយោជន៏ផ្ទាល់ខ្លួន (ម៉ាថាយ ២០: ២០-២៨, យ៉ូហាន ១៣:១-១៦) ដែលជាគំរូនៃការបង្រៀននេះនៅក្នុងព័ន្ធកិច្ចរបស់ទ្រង់ដល់មនុស្ស ដូចមានក្នុងគម្ពីរ (ភីលីព ២:៣-១១)។ ក្នុងសណ្ឋានជាអ្នកបំរើ នោះទ្រង់បានបន្ទាបអង្គទ្រង់ធ្វើតាមព្រះទ័យនៃព្រះវរបិតា (លូកា ២២:៤២, យូហាន ៦:៣៨, ភីលីព ២: ៣-៨)។ ទ្រង់បានជួយនិង នាំផ្លូវគ្រប់គ្នាជាដរាប។ សព្វថ្ងៃនេះទ្រង់ត្រូវបានគេចងចាំទុកជានិច្ចចំពោះការបំរើដល់ ជនគ្រប់គ្នាថាជា អង្គសង្គ្រោះ ជាគ្រូ ជាអ្នកប្រោសអោយជា និងជាអ្នកជួយគំនិត។ មនុស្សជាច្រើនមិនបានគិតថាព្រះយេស៊ូជា "អ្នកដឹកនាំ" ដ៏សំខាន់នោះទេ គឺដោយព្រោះតែយល់ខុសពីលក្ខណៈនៃការដឹកនាំទៅតាម ជាន់ថ្នាក់ តំនែង រឺឋានៈដែលព្រះយេស៊ូមានតែបន្តិចបន្តួច។ ផ្ទុយទៅវិញ ព្រះយេស៊ូគឺជាអ្នកដឹកនាំដ៏ពិតប្រាកដ។ មិនមែនគ្រាន់តែ មានហ្វូងមនុស្សដ៏ច្រើនដើរតាមទ្រង់ក្នុងកំឡុងជីវភាពលើផែនដីរបស់ទ្រង់នោះទេ ប៉ុន្តែព្រះយេស៊ូបានដុតបញ្ឆេះ អោយមាន ចលនាដ៏អស្ចារ្យ គ្រប់សម័យកាលទាំងអស់ ដូចនេះហើយបានជាមនុស្សរាប់លានអ្នកនៅតែដើរតាមទ្រង់ដល់សព្វថ្ងៃនេះ។



វាមានសារៈសំខាន់ណាស់ដែលយើងត្រូវយល់ថា ចំពោះគ្រីស្ទាន ការដឹកនាំ និងលក្ខណៈជាអ្នកបំរើ ដើរទៅស្របគ្នា។ ព្រះយេស៊ូទ្រង់ជាអ្នកដឹកនាំមិនមែនដោយសារតែ ទ្រង់បានបន្ទាបខ្លួនជាអ្នកបំរើនោះទេ តែដោយសារតែទ្រង់ជាអ្នកដឹកនាំពិតប្រាកដមែន។ គឺផ្តើមចេញមកពីតួនាទីរបស់ទ្រង់ជាអ្នកបំរើដែលព្រះយេស៊ូបានចាប់ផ្តើមសកម្មភាពដែលធ្វើអោយពិភពលោកនេះក្រឡាប់ចក្រ។ ព្រះយេស៊ូបានប្រទាននូវជីវិតទ្រង់ដល់អស់អ្នកដើរតាម។ ព្រះអង្គគឺជាកំពូលអ្នកដឹកនាំតាំងពីដើម ឥលូវនេះ និងរៀងរហូតទៅក៏ព្រោះតែទ្រង់ជាអ្នកបំរើដ៏អស្ចារ្យតាំងពីមុនរហូតដល់អស់លក្ប។

អស់អ្នកណាដែលដើរតាមព្រះយេស៊ូ ទ្រង់ប្រទានអំណាចដល់គេអោយដឹកនាំដូចជាទ្រង់ដែរ (យ៉ូហាន ២០:២១)។ ការដឹកនាំមិនមែនដូចជា របៀបនៃការទាក់ទាញភ្ញៀវបែបអ្នកលក់ដូរ ការអនុវត្តន៏តាមការលើកទឹកចិត្តរបស់ទ្រឹស្តីថ្មីៗ រឺក៏ការហ្វឹកហាត់នៃសិទ្ធិអំណាចរបស់ខ្លួននោះទេ។ ដូចជាព្រះយេស៊ូបានសំរេចតាមផែនការរបស់ព្រះ នោះអ្នកដឹកនាំ **កកគ** ("ជោគជ័យនៃការបណ្តុះក្រុមជំនុំ") ត្រូវតែលះបង់ចោលនូវផែនការផ្ទាល់ខ្លួន ហើយទទួលយកផែនការពីព្រះជាម្ចាស់វិញ។

គេដាក់ខ្លួនគេទុកជាអ្នកបំរើ ដើម្បីបង្កើតអោយឃើញលទ្ធផល ។

អ្នកដឹកនាំនៃ **កកត** នៅសតវត្សដំបូងដ៏ចំណានគឺលោកសាវ័កប៉ូល បានជួយទំនុកបំរុង អោយមានចលនានៃ ដំនឹងល្អដ៏ខ្លាំងខ្លានៅអាស៊ីម៉ាណើរ (អាស៊ីកណ្តាល) ដោយផ្តើមចេញពីការបណ្តុះបណ្តាលក្នុងទីក្រុង អេភេសូ (កិច្ចការ ១៩:១០) ។ លោកប៉ូលបាន ប្រគល់ខ្លួបគាត់ដល់អ្នកដែរដើតាមដូចជាព្រះយេស៊ូដែរ ។ នៅពេលដែលលោកពិពណ៌នា ពីលក្ខណៈព័ន្ធកិច្ចរបស់លោកដល់ប្រជាជន អេភេសូ នោះយើងដឹងថា របៀបបន្ទាបខ្លួនធ្វើជាអ្នកដឹកនាំបែបបំរើ គឺជាមូល ដ្ឋានគ្រឹះឆ្ពោះទៅរកជោគជ័យជាអ្នកដឹកនាំរបស់គាត់ (កិច្ចការ២០:១៧-២១) ។

**ការជះឥទ្ធិពល-ការជំរុញទឹកចិត្ត**

ជាទំលាប់ទៅហើយដែលអ្នកដឹកនាំ ក្រុមជំនុំជាច្រើនត្រូវបានគេគិតថាជាអ្នក "បំពេញ" ព័ន្ធកិច្ច ។ ផ្ទុយទៅវិញ កិច្ចការចំបងនៃការដឹកនាំគឺ ជះឥទ្ធិពលដើម្បីជំរុញទឹកចិត្តអ្នកដទៃទៀតអោយជួយបង្ហើយកិច្ចការរបស់ព្រះ ។ អ្នកដឹកនាំគ្រីស្ទាន គឺដូចជាកសិករដែលដាំដុះ គ្រាប់ពូជ ដោយប្រើប្រាស ទឹក និង ដី ប៉ុន្តែ គ្មានអំណាចធ្វើអោយគ្រាប់ពូជនោះដុះបានទេ (១កូរិនថូស ៣:៦-៧) ។ ការងាររបស់កសិករគឺថែទាំដំណាំដោយបញ្ចៀសរាល់ឧបសគ្គដែលរាំងដល់ការលូតលាស់ ព្រមទាំងផ្តល់អោយនូវបរិយាកាសដែលអំនោយផលដល់ការលូតលាស់របស់វា ។ សកម្មភាពដាំដុះនេះគឺស្រដៀងគ្នាដែរទៅនឹងអ្នកដឹកនាំ នៃ **កកត** ។ ដូចជាកសិករគាត់ជា "អ្នកធ្វើ" ប៉ុន្តែវាកាន់តែមានលក្ខណៈត្រឹមត្រូវទៀត បើនិយាយថា គាត់ "ជះឥទ្ធិពល" ។ អ្នកដឹកនាំនៃ **កកត** ជាអ្នកជំរុញទឹកចិត្ត គឺជាមនុស្សដែលបង្កើតស្ថានភាព ដែកអាចធ្វើអោយសកម្មភាពទាំងឡាយអាចកើតមានឡើង ។

ការជំរុញទឹកចិត្តអាចមានការលំបាកខ្លាំងសំរាប់មនុស្សដែលស្វែងរកតំលៃអោយខ្លួនឯងក្នុងកិច្ចការដែលគេធ្វើ ។ គេអាចនឹងរកឃើញនូវ វិធីសាស្រ្ត **កកត** នៃការធ្វើព័ន្ធកិច្ច ជាជំហានដែលមិនគួរអោយជឿ ពីព្រោះ សកម្មភាព**កកត** ភាគច្រើនមិនបានពឹងផ្អែកទៅលើខ្លួនគេផ្ទាល់ទេ តែផ្អែកទៅលើកិច្ចការដែលព្រះទ្រង់ធ្វើតាមរយៈអ្នកដឹកនាំទាំងឡាយវិញ ។ ចលនានៃ **កកត** មិនអាចត្រូវបាន ចាត់ចែង ត្រួតពិនិត្យ រឺគ្រប់គ្រង ដោយនណាផ្សេងទៀតក្រៅពីព្រះជាម្ចាស់នោះទេ ។ អ្នកដឹកនាំគ្រាន់តែធ្វើតាមក្រោមការដឹកនាំរបស់ព្រះ ក្នុងការជះឥទ្ធិពល ដែលអាចជំរុញគ្រប់ទាំងសកម្មភាពការងារទៅបាន ។

| **អ្នកដឹកនាំតាមទំលាប់** | **អ្នកដឹកនាំជំរុញទឹកចិត្ត** |
|---|---|
| "ធ្វើអោយការងារបានសំរេច" | "ជំរុញទឹកចិត្តមនុស្សអោយចូលរួម" |
| អ្នកជំនាញការ | អ្នក បំពាក់បំប៉ន, បណ្តុះបណ្តាល, ជំរុញទឹកចិត្ត |
| អ្នកធ្វើ | អ្នកបែងចែកសិទ្ធអំណាច |

| អ្នកដឹកនាំតាមទំលាប់ | អ្នកដឹកនាំជំរុញទឹកចិត្ត |
|---|---|
| បំពេញការងារក្នុងព័ន្ធកិច្ចបានល្អ | បំពាក់បំប៉នអ្នកដទៃអោយ ធ្វើព័ន្ធកិច្ចដោយមានប្រសិទ្ធិភាព |

បើសិនជាមនុស្សមិនត្រូវបានបំពាក់បំប៉ន អោយបំពេញមហាបេសកកម្មទេ នោះវាជាបរាជ័យនៃការដឹកនាំ ហើយ ។ គឺជាផែនការរបស់ព្រះដែលសាងសង់ក្រុមជំនុំ តាមរយៈអ្នកដឹកនាំ ដែលបំពាក់បំប៉នដល់សមាជិក (អេភេសូ ៤:១១-១៣) ។ ផ្នែកមួយក្នុងចំនោមទីសំគាល់នៃជោគជ័យទាំងឡាយសំរាប់អ្នកបំពាក់បំប៉ន គឺជាប្រសិទ្ធិភាពក្នុងការរីកលូតលាស់នៃព័ន្ធកិច្ចរបស់អ្នកដឹនាំដទៃទៀត ។ អ្នកដឹកនាំនៃ **កកត** យល់ពី យុទ្ធសាស្រ្តនៃជោគជ័យខាងលើនេះ ហើយចាត់ទុកវាជាលក្ខណៈសំខាន់ចំពោះការបំពាក់បំប៉នអ្នកដទៃតាមរយះ ការលើកទឹកចិត្ត និង ជំរុញ ពួកគេអោយចេះប្រើប្រាសអំណោយទាន ទេពកោសល្យ និង សមត្ថភាពរបស់ខ្លួន ។ ការបំពាក់បំប៉ន អ្នកផ្សាយដំនឹងល្អ អ្នកដឹកនាំក្រុមកោសិកា អ្នកបណ្តុះក្រុមជំនុំ ព្រមទាំងគ្រូគង្វាល តាមរបៀបធ្វើពហុគុណ នោះធ្វើអោយមានការអភិវឌ្ឍន៏ចលនា នៃការបណ្តុះក្រុមជំនុំ ។

**និមិត្តគំនិតនៃ "អ"**



អ្នកដឹកនាំនៃ **កកត** មានទិសដៅតែមួយដូចគ្នា ដែលធ្វើដំនើរឆ្ពោះទៅមុខដោយសួរថា "តើព្រះទ្រង់សព្វព្រះហឫទ័យធ្វើអ្វី?" សំរាប់ជាតិសាសន៏ ទីក្រុង និងតំបន់របស់ពួកគេ ដោយពួកគេជឿជាក់ថា ព្រះទ្រង់ចង់អោយ មនុស្សទាំងអស់មានឱកាសបានលឺ និងឆ្លើយតបទៅនឹងដំនឹងល្អ ហើយការនេះតំរូវអោយក្រុមជំនុំតំបន់ធ្វើទីបន្ទាល់អោយបានច្បាស់លាស់ ។

គំនិតនៃ "**អ**" មានឥទ្ធិពលលើលក្ខណៈរបស់អ្នកដឹកនាំ **កកត** ដូចជា ក្នុងគោលដៅរស់នៅប្រចាំថ្ងៃ តួនាទីក្នុងក្រុមជំនុំ និង ក្នុងសហគមរបស់គាត់ ។ អ្នកដឹកនាំទាំងនេះមិនគ្រាន់តែចាប់ផ្តើមអោយមានកម្មវិធី រឺរៀបចំជាវិជ្ជាស្ថានទាំងឡាយនោះទេ ។ ពួកគេជំរុញសកម្មភាពតាមរយះ ការប្រមូលផ្តុំអ្នកជឿ អោយឆ្ពោះទៅបំពេញនូវមហាបេសកកម្ម ។ ពួកគេធ្វើក្រោម ការដឹកនាំរបស់ព្រះក្នុងការ ជះឥទ្ធិពលដើម្បីផ្លុំរូបកាយរបស់ផងព្រះគ្រីស្ទអោយឆ្ពោះទៅរកការបំពេញមហាបេសកកម្មតាមរយះការបណ្តុះក្រុមជំនុំដែលអាចបង្កើតក្រុមជំនុំផ្សេងៗទៀតបាន ។

អ្នកដឹកនាំរបស់ **កកត** មិនមែនបង្កើតនិមិត្តទេ ។ ជួនកាលអ្នកដទៃយល់ថាអ្នកដឹកនាំទាំងនេះបានបង្កើតនិមិត្តឡើងដោយព្រោះតែអ្នកដឹកនាំ នៃ **កកត** បានសំឡឹងឃើញកិច្ចការដែលអ្នកដទៃមើលមិនឃើញ ។ និមិត្ត **កកត** ពិតជានិមិត្តរបស់ព្រះពិតប្រាកដ ។ ជាធម្មតាអ្នកដឹកនាំនៃ **កកត** រកឃើញនិមិត្តនេះតាមរយះ ការស្វះស្វែងតាមសំនួរគន្លឹះមួយថា "តើព្រះទ្រង់សព្វព្រះទ័យចង់ធ្វើអ្វី?" ។ សំនួរដ៏សំខាន់មួយនេះអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការដឹកនាំ ។ វាអាចនាំទៅដល់លទ្ធផលមួយដែលលើសជាងអ្នកដឹកនាំដ៏ទៃធ្លាប់គិតដល់ ។ អ្នកដឹកនាំនៃ**កកត**ជឿលើព្រះយេស៊ូគ្រីស្ទនៅពេលដែលទ្រង់មានបន្ទូលថាទ្រង់នឹងសាងសង់ក្រុមជំនុំទ្រង់ឡើង (ម៉ាថាយ ១៦:១៨) ហើយពួកគេជំរុញទឹកចិត្តអ្នកដ៏ទៃអោយជឿលើទ្រង់ដែរ ។

# ៥

# ក្រុមជំនុំ

ព្រះយេស៊ូគ្រីស្ទជាម្ចាស់នៃក្រុមជំនុំ។ ព្រះគម្ពីរ កូលុស ១:១៨ ពណ៌នាថា "ទ្រង់ជាសិសានៃរូបកាយរបស់ក្រុមជំនុំ"។ ក្រុមជំនុំមិនមែនមានតែជា គ្រូគង្វាល ការប្រជុំមួយក្រុម រឺក៏ ជានិកាយមួយនោះទេ។ ក្រុមជំនុំគឺជារូបកាយទាំងមូលរបស់ព្រះគ្រីស្ទ គឺគ្រប់ទាំងគ្រីស្ទាននៅគ្រប់ក្រុម។ ក្រុមជំនុំ ដែលជារូបកាយទាំងមូល គឺជាឧបករណ៍របស់ផងព្រះក្នុងការឈោងចាប់ពិភពលោក។ ក្រុមជំនុំមិនមែនបង្កើតឡើងសំរាប់ផលប្រយោជន៍ខ្លួនឯងទេ, តែត្រូវបានបង្កើតឡើងដើម្បីបំពេញមហាបេសកកម្មវិញ។

**ការប្រៀបធៀប គំរូនៃក្រុមជំនុំ**

ជាញឹកញយក្រុមជំនុំដួលទៅរករបៀបមួយក្នុងចំនោមរបៀបពីរយ៉ាង។ គឺអាចជារបៀបនៃក្រុមជំនុំរួមបញ្ចូលគ្នា រឺក៏អាចជា ភ្នាក់ងារនៃចលនាប្រមូលផ្តុំ ដើម្បីឈោងចាប់ពិភពលោកលោកថ្វាយព្រះគ្រីស្ទ។ របៀបទាំងនេះកើតមានឡើងសំរាប់បំរើអោយសមាជិកក្រុមជំនុំតែម៉្យាងគត់ រឺក៏អាចមានគោលបំនងច្រើនជាងនេះ។

ពីររបៀបផ្សេងគ្នាសំរាប់ការប្រៀបធៀបនេះ ត្រូវបានបង្ហាញនៅទំព័របន្ទាប់។ ទី(១) ជាក្រុមជំនុំ "រួមបញ្ចូលគ្នា" ប្រៀបធៀបជាមួយ ក្រុមជំនុំដែលជា "ភ្នាក់ងារនៃចលនាប្រមូលផ្តុំ" និងទី(២) ជាក្រុមជំនុំ បំរើអោយកម្មវិធី ផ្ទាល់ខ្លួនប្រៀបធៀបនឹង ក្រុមជំនុំ "មហាបេសកកម្ម"។

១, ក្រុមជំនុំ "រួមបញ្ចូលគ្នា " ប្រៀបធៀបនឹងក្រុមជំនុំដែលជា "ភ្ជាក់ជានៃចលនាប្រមូលផ្តុំ" ។

## ក្រុមជំនុំរួមបញ្ចូលគ្នា



| ក្រុមជំនុំ | គ្រូគង្វាល | ពិភពលោក (លោកិយ) |
|---|---|---|
| សមាជិកត្រូវបានគេហៅថាជា "ក្រុមជំនុំធម្មតា" ។<br><br>ក្រុមជំនុំធម្មតាជួយផ្គត់ផ្គង់ដល់គ្រូគង្វាលអោយធ្វើព័ន្ធកិច្ច ។ ក្រុមជំនុំ បង្ហាញពីការជួយជ្រមជ្រែង របស់គេ ដោយចូលរួមក្នុងកម្មវិធី ថ្វាយដង្វាយ និងយល់ស្របទៅនឹង សកម្មភាព និងការសំរេចចិត្តរបស់ គ្រូគង្វាល់ ។<br><br>ក្រុមជំនុំធម្មតាជឿជាក់ថា គោលបំនងសំខាន់របស់ក្រុមជំនុំ គឺមើលថែរក្សារាល់តំរូវការរបស់សមាជិកក្រុមជំនុំ ។<br><br>ក្រុមជំនុំធម្មតាមិនបានមើលឃើញការទទួលខុសត្រូវរបស់ផងខ្លួន ក្នុងការផ្សាយដំនឹងល្អដល់មនុស្សបាត់បង់ទេ ។ | គ្រូគង្វាល់ត្រូវបានគេទទួលស្គាល់ថាជាអ្នកជំនាញការព័ន្ធកិច្ច ។ លោកត្រូវបានគេហៅថា "លោកឪពុក " "លោកគ្រូ" រឺក៏ ជា "គ្រូគង្វាល" ។ លោកគឺជា "អ្នកធ្វើព័ន្ធកិច្ច" ។<br><br>ជាទូទៅក្នុងរចនាសម្ពន្ធនេះ គ្រូគង្វាលទទួលខុសត្រូវលើកម្មវិធីថ្វាយបង្គំ ដោយ ចាត់ទុកសមាជិកគ្រាន់តែជា "អ្នកជំនួយ" ។ | គ្រូគង្វាល គឺជាមនុស្សតែម្នាក់គត់ដែលប្រឈមមុខជាមួយនឹងលោកិយ ។ មនុស្សគេនិយាយថា ជាធម្មតាគ្រូគង្វាលមិនបានចេញទៅដោយស្មោះត្រង់ដើម្បីឈោងចាប់លោកិយនោះទេ គឺគាត់ត្រូវបានគេ "បង់ថ្លៃអោយធ្វើការនេះតែប៉ុណ្ណោះ" ។<br><br>លោកីយ៏មិនបាននាំមកថ្វាយព្រះគ្រីស្ទទេ ។ រីឯគ្រូគង្វាលព្យាយាមស្ទើរតែនឹងស្លាប់ខ្លួនដើម្បីធ្វើគ្រប់ទាំងព័ន្ធកិច្ច ។ |

## ក្រុមជំនុំដែលជាភ្នាក់ងារចលនាប្រមូលផ្តុំ



| អ្នកដឹកនាំ | ក្រុមជំនុំ | ពិភពលោក (លោកិយ) |
|---|---|---|
| ការងារជាចំបងរបស់អ្នកដឹកនាំ គឺបំពាក់បំប៉ននដល់សមាជិកក្រុមជំនុំដើម្បីអោយគេអាចធ្វើព័ន្ធកិច្ចក្នុងលោកិយនេះ (អេភេសូ ៤:១១-១៦)។<br>អ្នកដឹកនាំត្រូវតែដឹងពីតំរូវការ និងអំ-ណោយទានខាងឯវិញ្ញាណនៃសមាជិកក្រុមជំនុំរបស់ខ្លួនដើម្បីអោយគេអាចបំពាក់បំប៉នអ្នកទាំងនោះអោយធ្វើព័ន្ធកិច្ចដែលមានប្រសិទ្ធិភាពត្រឹមត្រូវពេញលេញ។ | ក្រុមជំនុំធម្មតាត្រូវបានគេបណ្តុះបណ្តាលអំពីការដឹកនាំ ដើម្បីអោយក្លាយជា "អ្នកធ្វើព័ន្ធកិច្ច (បេសកជន)"។<br>ដូច្នោះក្រុមជំនុំមួយដែលមានសមាជិក ១០០ នាក់គួរតែសង្ឃឹមថានឹងមានអ្នកធ្វើព័ន្ធកិច្ច១០០នាក់ដែរ (មិនមែនជាគ្រូគង្វាលទេ) ។សមាជិកក្រុមជំនុំត្រូវបន្តការប្រើអំណោយទានខាងឯវិញ្ញាណក្នុងការធ្វើព័ន្ធកិច្ចទៅគ្នាទៅវិញទៅមកព្រមទាំងឈោងចាប់មនុស្សបាត់បង់។<br>ការផ្សព្វផ្សាយដំនឹងល្អទៅក្នុងលោកិយគឺជាការទទួលខុសត្រូវជាចំបង របស់សមាជិកក្រុមជំនុំ។<br>ការដឹកនាំបែបក្រុម ជំនុំ ផ្តល់អោយមានការបំពាក់បំប៉ន ដល់សមាជិកដើម្បីអោយទទួលនូវការទទួលខុសត្រូវនេះ។ | ពិភពលោកគឺជាទីកន្លែង ដែលសមាជិកទាំងឡាយរស់នៅ។<br>សមាជិកក្រុមជំនុំជាអ្នកធ្វើព័ន្ធកិច្ច ពេញម៉ោងនៅកន្លែងដែលពួកគេរស់នៅ និងធ្វើការ។<br>សង្គមគ្រប់ជាន់ថ្នាក់ទាំងអស់ ត្រូវបានជ្រៀតចូលដោយ ដំនឹងល្អ (ម៉ាថាយ ២៨:១៩-២០)។ |

**២. ក្រុមជំនុំ បំរើអោយកម្មវិធីផ្ទាល់ខ្លួន  ប្រៀបធៀបនឹង ក្រុមជំនុំ មហាបេសកកម្ម**

របៀបមួយទៀតដែលយើងត្រូវក្រលេកមើលទាំងផ្តោតអារម្មណ៏ទៅនោះគឺ ក្រុមជំនុំដែលបំរើអោយកម្មវិធីផ្ទាល់ខ្លួន ប្រៀបធៀបជាមួយនឹង ក្រុមជំនុំមហាបេសកកម្ម។ នៅក្នុងក្រុមជំនុំបំរើអោយកម្មវិធីផ្ទាល់ខ្លួន កម្មវិធីធ្វើឡើងភាគច្រើនមានលក្ខណៈដោយឡែកពីគ្នា និង មានឡើងសំរាប់គោលបំណងរៀង១ខ្លួន។ នៅក្នុងក្រុមជំនុំមហាបេសកកម្ម កម្មវិធី សកម្មភាព និងផែនការទាំងអស់នៃក្រុមជំនុំមានគោលបំណងតែមួយ គឺថា ផ្សព្វផ្សាយដំនឹងល្អ។

**ក្រុមជំនុំបំរើអោយកម្មវិធីផ្ទាល់ខ្លួន**




**ក្រុមជំនុំ មហាបេសកកម្ម**



# កត្តានៃការបណ្តុះក្រុមជំនុំដោយគ្រប់ទិសទី

ហាបាគុក ២:១៤ " ដ្បិតមនុស្សនឹងស្គាល់ដល់សិរីល្អនៃព្រះយេហូវ៉ា នៅពេញលើផែនដីដូចជាទឹកក៏នៅពេញសមុទ្រដែរ ។




ទំនុកដំកើង ១២៧:១ " បើគ្មានព្រះយេហូវ៉ាសង់ផ្ទះឡើង នោះពួកជាងដែលសង់គេធ្វើការជាឥតប្រយោជន៍ទេ" ។

# ៦

# ចលនានៃការអធិដ្ឋាន

ដើម្បីអោយចលនានៃការបណ្តុះក្រុមជំនុំកើតមានឡើង ការខិតខំអធិដ្ឋានត្រូវតែអោយមានការប្រមូលផ្តុំ។ យុទ្ធសាស្ត្រនៅក្នុងការអធិដ្ឋាន សំរាប់ជោគជ័យនៃការបណ្តុះក្រុមជំនុំ ត្រូវតែផ្តោតអារម្មណ៏ទៅលើចំនុច ដែលវាត្រូវកើតឡើងនៅតាមភូមិនិមួយៗ អ្នកជិតខាងក្នុងទីរួមខេត្ត ទីក្រុងនៃប្រទេសជាតិរបស់អ្នក និងក្នុងចំនោមមនុស្សតាមក្រុមដែលមិនទាន់ឈោងចាប់បាននៅឡើង។ មានវិធីផ្សេងៗគ្នា ជាច្រើន ដែលមនុស្សយើងបានរៀបចំការអធិដ្ឋានបែបប្រគុំតន្ត្រី សំរាប់ទីក្រុង រឺប្រទេសជាតិណាមួយ។

យើងដឹងថា ព្រះមិនបាច់ត្រូវការការអធិដ្ឋានរបស់ពួកយើងក្នុងការសំរេចព័ន្ធកិច្ចនេះទេ។ ប៉ុន្តែ នៅក្នុងផែនការនៃការសោយរាជ និង ទំនាយ ទ្រង់បានជ្រើសរើស និង ធ្វើអោយយើងក្លាយជាមនុស្សមានប្រយោជន៏ព្រមទាំងការអធិដ្ឋានរបស់យើងដើម្បីអោយយើងថាផែនការរបស់ទ្រង់បានសំរេចក្នុងចំនោមប្រជាជនទាំងឡាយ។ ព្រះសព្វព្រះទ័យប្រើការអធិដ្ឋានរបស់អ្នកដើម្បីសំរេចមហាបេសកកម្ម។ ទ្រង់ចង់អោយការអធិដ្ឋានរបស់អ្នក ផ្សារភ្ជាប់ជាមួយការបណ្តុះក្រុមជំនុំ ដើម្បីប្រកាសដំនឹងល្អ។ ដូច្នោះព្រះនឹងប្រើប្រជារាស្ត្រនៃទ្រង់អោយកាន់តែមានប្រសិទ្ធិភាព នៅពេលដែលគេរួមគ្នាអធិដ្ឋានក្នុងការដឹកនាំនិងខិតខំក្នុងកិច្ចការទ្រង់ ដើម្បីបង្កើតក្រុមជំនុំរបស់ទ្រង់តទៅទៀត។

យុទ្ធសាស្ត្រនៃការអធិដ្ឋាននៅក្នុងទ្រង់ទ្រាយដ៏ធំ ត្រូវការកត្តាគន្លឹះសំខាន់ៗដូចជា: ការស្រាវជ្រាវ ការបំផុសនិមិត្ត ការបណ្តុះបណ្តាល ព្រមទាំងការស្វែងរកនិង ការដាក់បណ្តាញអធិដ្ឋានអ្នកដឹកនាំ។

**ការស្រាវជ្រាវការអធិដ្ឋាន**

ពីព្រោះតែជាបំណងព្រះហឫទ័យរបស់ផងព្រះដែលផ្សះផ្សារមនុស្សជាមួយនឹងទ្រង់ ព្រមទាំងប្រកាសពីសិរីល្អរបស់ទ្រង់ក្នុងចំនោមជនជាតិ វាទំនងណាស់ដែលព្រះវិញ្ញាណបរិសុទ្ធ បានបណ្តាលអោយមនុស្សមានចិត្តក្នុងការអធិដ្ឋានសំរាប់អ្នកជិតខាង តំបន់ ទីក្រុង រឺក៏ប្រទេសជាតិរបស់គេរួចជាស្រេច។ ជំហានដំបូងក្នុងការប្រមូលផ្តុំការអធិដ្ឋានលើទ្រង់ទ្រាយដ៏ធំ គឺស្វែងរកមនុស្ស ដែលមានចិត្តពុះកញ្ជ្រោលចង់តែអធិដ្ឋាន។

នៅពេលដែលក្រុមអធិដ្ឋានដែលបានបង្កើតឡើងមានរូបរាងច្បាស់លាស់ហើយ គេត្រូវតែផ្សារភ្ជាប់ជាមួយនឹងអ្នកដែលធ្វើការផ្សាយដំនឹងល្អ និង អ្នកបណ្តុះក្រុមជំនុំ នៅក្នុងតំបន់ រឺក៏ភូមិភាគរបស់គេ។ ជារឿយៗ ក្រុមអធិដ្ឋាន និងបណ្តាញរបស់គេត្រូវបានកាត់ផ្តាច់ចេញពីចលនានៃការផ្សាយដំនឹងល្អនិងការបណ្តុះក្រុមជំនុំដោយមិនបានអធិដ្ឋានអោយទេ។

លើសពីនេះទៀត អ្នកដឹកនាំនៃក្រុមអធិដ្ឋានទាំងនេះគួរតែទទួលបាននូវការលើកទឹកចិត្ត ក្នុងការធ្វើការរួបរួមក្រុម និងបណ្តាញ នៃការអធិដ្ឋានក្នុងផ្នែកផ្សេងទៀតនៃទីក្រុង ភូមិភាគ រឺក៏ប្រទេសជាតិរបស់គេ។ បទពិសោធន៍ និងនិមិត្តរបស់ពួកគេអាចប្រើដើម្បីអភិវឌ្ឍអ្នកដឹកនាំនៃការអធិដ្ឋានដទៃទៀត។

ម្តងម្កាល ក្រុមអធិដ្ឋាន ព្រមទាំងបណ្តាញទាំងនេះអាចរួមគ្នាជាមួយក្រុមជំនុំរបស់ពួកគេដើម្បីធ្វើការអធិដ្ឋានប្រគុំតន្ត្រីដ៏ធំមួយ។ ការប្រជុំនេះផ្តោតអារម្មណ៏ទៅលើការសរសើរតំកើង និងការថ្វាយបង្គំព្រមទាំងការជំរុញនូវដំនឹងល្អ។ ធ្វើបែបនេះបង្កើនការរួបរួមក្នុងចំនោមគ្រីស្ទាន ដែលអាចទទួលបានលទ្ធផលក្នុងកិច្ចសហការណ៏យ៉ាងជិតស្និទ្ធ។

បើសិនជាការ ស្រាវជ្រាវបង្ហាញថា របៀបនៃការអធិដ្ឋានដែលត្រូវបានរៀបចំឡើង មានចំលើយតបកើតឡើង តិចតួចពេក នោះគួរតែផ្តោតអារម្មណ៏លើការទូលដល់ព្រះដើម្បី រើសតាំងអ្នកដឹកនាំអធិដ្ឋានដែលមានសក្តានុពលភាពក្នុងការបំផុសនិមិត្ត និង យុទ្ធសាស្រ បង្រួបបង្រួមការអធិដ្ឋានក្នុងចំនោមអ្នកជឿតាមក្រុមជំនុំតំបន់។




**បណ្តុះបណ្តាល និង បំពាក់បំប៉ន មនុស្សអោយអធិដ្ឋានសំរាប់ការបង្កើតក្រុមជំនុំគ្រប់ទិសទី។**

ពេលដែលមនុស្សមាននិមិត្តអំពីអ្វីដែលព្រះចង់អោយកើតមាននៅក្នុងតំបន់របស់ពួកគេពេលនោះគេនឹងត្រូវការគំនិតដែលមានប្រយោជន៏ និង ជំនួយអំពីរបៀបដែលបញ្ចូលការអធិដ្ឋានយ៉ាងពេញលេញទៅនឹងចលនានៃដំនឹងល្អ។ ការបណ្តុះបណ្តាលយ៉ាងស្ទាត់ជំនាញនៅក្នុងវិធីសាស្រ្តផ្សេងៗដែលលើកទឹកចិត្តដល់ការអធិដ្ឋាន មានដូចខាងក្រោមនេះ:

- ការអធិដ្ឋានដែលមានមិត្តសំលាញពានាក់: ក្រុមតូចមួយដែលមានមិត្តសំលាញ់បីនាកអធិដ្ឋានអោយគ្នាទៅវិញទៅមក។
- អធិដ្ឋានដោយដើរ: ជាពេលដែលយើងដើរហើយអធិដ្ឋានទូលអង្វរសំរាប់តំបន់គោលដៅណាមួយ។
- ក្រុមអធិដ្ឋានជំនួយ: ជាក្រុមមួយដែលទ្រទ្រង់ ក្រុមដែលបណ្តុះក្រុមជំនុំ តាមរយះការអធិដ្ឋានទូលអង្វរ។
- សង្គ្រាមវិញ្ញាណ: ការអធិដ្ឋានជាយុទ្ធសាស្រ្ត ដើម្បីគត់សំគាល់ទៅលើទីមាំមួនរបស់សាតាំង និងដើម្បីវាយកំទេច ព្រមទាំងវាយតបតទៅនឹងសកម្មភាពរបស់វា។
- ការចែកចាយពតិមាន: ត្រូវប្រាកដច្បាស់ថា ក្រុមអធិដ្ឋាននៅតែមានទំនាក់ទំនងដោយផ្តល់នូវពតិមាន និងផ្សារភ្ជាប់ទៅនឹងការផ្សាយដំនឹងល្អព្រមទាំងកិច្ចខិតខំបណ្តុះក្រុមជំនុំ។

- ការអធិដ្ឋានដោយប្រគុំតន្ត្រីៈ ការប្រជុំគ្នាដើម្បីអធិដ្ឋាន ដែលជួបជុំគ្នាជាទៀងទាត់ ហើយមានអ្នកដឹកនាំអធិដ្ឋានដែល "ត្រួតពិនិត្យ" ពេលវេលានៃការអធិដ្ឋាន។

- ថ្ងៃបុណ្យអធិដ្ឋានសំរាប់ប្រទេសជាតិៈ ថ្ងៃបុណ្យជាតិដែលគេទទួលស្គាល់សំរាប់ការអធិដ្ឋាន ជាពិសេសអធិដ្ឋាទូលអង្វរសំរាប់ប្រទេសជាតិតែម្តង់។

- ការអធិដ្ឋាននិងការតមអត់ៈ ពេលវេលាដែលផ្តោតទៅលើការអធិដ្ឋាន ដោយយកកន្លែងមួយសំរាប់សកម្មភាពប្រចាំថ្ងៃ ។

**ស្វែងរកនិងភ្ជាប់បណ្តាញអ្នកដឹកនាំអធិដ្ឋាន**

ដើម្បីអោយចលនាមួយមានប្រសិទ្ធិភាព គឺត្រូវមាន ការដឹកនាំ។ អ្នកដឹកនាំអធិដ្ឋានត្រូវដើរក្នុងតួនាទីតាមកំរិតផ្សេងៗនៃចលនាអធិដ្ឋាន ។ អ្នកដឹកនាំខ្លះនឹងដឹកនាំក្រុមអធិដ្ឋានផ្សេងៗ គឺប្រហែលជានៅក្នុងក្រុមជំនុំតំបន់ រឺក៏សមាជិកមកពីក្រុមជំនុំតំបន់ជាច្រើនក្នុងសហគមន៍។ អ្នកផ្សេងទៀតនឹងធ្វើជាអ្នកដឹកនាំ បណ្តាញនៃការអធិដ្ឋានផ្សេងៗ ដូចជា ក្រុមតូចៗ រឺក៏តែឯកឯងនៅតាមភូមិភាគ ទីក្រុង រឺក៏ប្រទេសជាតិ ដែលជាអ្នកមានចិត្ត ពុះកញ្ជ្រោលក្នុងការអធិដ្ឋានដើម្បីចលនានៃដំនឹងល្អ ក្នុងតំបន់នោះ។




**ចារិកលក្ខណៈនៃអ្នកដឹកនាំអធិដ្ឋានដែលមានប្រសិទ្ធិភាព**

- ក្នុងលក្ខណៈនៃការដឹកនាំក្រុមជំនុំត្រូវតែមានអត្តចារិកចុះចូលនិងបន្ទាបខ្លួន។ គាត់មិនគួរយល់ថាខ្លួនគាត់សំខាន់ជាងអ្នក

ដឹកនាំក្រុមជំនុំនោះទេ ។

- មានសមត្ថភាពដឹកនាំការប្រជុំអធិដ្ឋាន គឺថាអាចរក្សានូវការផ្តោតអារម្មណ៍នៃការប្រជុំអធិដ្ឋាន និងអាចទប់ស្កាត់រាល់ការអធិដ្ឋានដែលមិនសមស្រប រឺមិនមានសារៈប្រយោជន៏ ។
- មានការប្តេជ្ញាចិត្តខ្លាំងខ្លាចំពោះព្រះយេស៊ូគ្រីស្ទ និងមានជំនឿរឹងមាំក្នុងលំហាត់ប្រាណខាងវិញ្ញាណដូចជា ការអានព្រះបន្ទូល ការអធិដ្ឋានផ្ទាល់ខ្លួន និងការប្រកបទំនាក់ទំនង ។ល ។
- មានទំនាក់ទំនងល្អជាមួយអ្នកដទៃ និងមានកេរ្តិ៍ឈ្មោះក្នុងចំនោមអ្នកជឿក្នុងក្រុមជំនុំរបស់ខ្លួន ។
- មិនភពប្រសព្វនឹងការនិយាយដើមគេ ព្រមទាំងអាចទុកចិត្តបាន ។
- មាននិមិត្តក្នុងការបណ្តុះក្រុមជំនុំគ្រប់ទិសទី ។ គាត់មានសមត្ថភាពក្នុងការភ្ជាប់ទំនាក់ទំនងនិមិត្តនេះជាមួយអ្នកដទៃ ។
- មានសមត្ថភាពសំរបសំរួលការផ្តល់ពតិមានរវាងក្រុមអធិដ្ឋាន និង ចលនាបណ្តុះក្រុមជំនុំ ។

អ្នកដឹកនាំអធិដ្ឋានសំរាប់ប្រទេសជាតិត្រូវបំផុសអោយមានការអធិដ្ឋានសំរាប់ការដោះស្រាយបញ្ហា និងវិបត្តិដែលមានក្នុងប្រទេសជាតិទាំងមូល ។ ពួកគេក៏លើកទឹកចិត្តអោយអធិដ្ឋានសំរាប់អស់អ្នកដែលបំរើការក្នុងជួររាជរដ្ឋាភិបាល និងពលទាហាន ។ល ។ ពួកគេបំផុសបំផុលអោយមានបណ្តាញអធិដ្ឋានទូទាំងប្រទេសជាតិ ដែលមានកម្មភាពអធិដ្ឋានច្បាស់លាស់ និងអាចសំរបទៅតាមសកម្មភាពដូចជា ថ្ងៃបុណ្យអធិដ្ឋានសំរាប់ប្រទេសជាតិ ។ អ្នកដឹកនាំអធិដ្ឋានប្រទេសជាតិទាំងនេះអាចភ្ជាប់បណ្តាញជាមួយនឹងអ្នកដឹកនាំអធិដ្ឋានជាតិមកពីប្រទេសដទៃទៀតនៅជុំវិញពិភពលោក ។

**ការអធិដ្ឋានមិនសំអាងថា តើវាត្រូវតែមាននៅក្នុងតំបន ទីក្រុង ភូមិភាគ រឺក៏លក្ខណៈជាតិនោះទេ ផ្ទុយទៅវិញ គោលដៅនៃការបង្រួបបង្រួមការអធិដ្ឋាននិងចលនានៃការអធិដ្ឋានគឺត្រូវអោយឃើញព្រះគ្រីស្ទជាមូលដ្ឋាន ដែលទ្រង់អភិវឌ្ឍក្រុមជំនុំអោយមានភាពងាយស្រួលដល់ជនជាតិ និមួយៗដើម្បីអោយមនុស្សទាំងអស់អាចលឺហើយឃើញដំនឹងល្អតាមរបៀបមួយដែលមានតុល្យភាពហើយស្របទៅនឹងស្ថានភាពរបស់ពួកគេ ។**

# ៧

# ការស្រាវជ្រាវៈ ពត៌មានសំរាប់គោលដៅយុទ្ធសាស្ត្រ

ការស្រាវជ្រាវគឺជាយុទ្ធសាស្ត្រមួយដែលជួយដល់ចលនាប្រមូលផ្តុំក្រុមជំនុំ អោយឆ្ពោះទៅកាន់ការបំពេញមហាបេសកកម្ម។ វាជួយដល់ ភ្នាក់ងារ និងក្រុមជំនុំអោយដឹងពីកន្លែងដែលក្រុមជំនុំត្រូវបង្កើតឡើងព្រមទាំងពីវិធីសាស្ត្រនៃការផ្សាយដំនឹងល្អ ដែលទទួលបានជោគជ័យ រឺបរាជ័យ ក្នុងចំនោមមនុស្សគ្រប់ក្រុម។

**ការស្រាវជ្រាយក៏អាចៈ**

- ជួយដល់អ្នកធ្វើការខាងគ្រីស្ទាន អោយយល់ដឹងពីរូបភាពដ៏ធំ នៃអ្វីដែលព្រះសព្វព្រះហឫទ័យនឹងធ្វើនៅក្នុងតំបន់របស់អ្នករឺក្រុមមនុស្ស។
- ជួយពួកគេអោយនៅតែផ្តោតអារម្មណ៏ទៅលើកិច្ចការនៃការបំពេញមហាបេសកកម្ម។
- ធ្វើអោយគេប្រាកដច្បាស់ថា យុទ្ធសាស្ត្ររបស់គេនៅតែមានប្រសិទ្ធិភាពនិងងាយបទបែនបាន។
- ជួយអោយពួកគេដឹងនៅពេលដែលការងារបានសំរេច។

**ឧទាហរណ៏ក្នុងព្រះបន្ទូល**

ជាញឹកញយនៅពេលដែលព្រះត្រាសហៅមនុស្សអោយទទួលព័ន្ធកិច្ចថ្មី ទ្រង់ដឹកនាំគេអោយត្រួតពិនិត្យទៅលើស្ថានភាព ទាំងឡាយដែលនៅជំវិញគេជាមុន។ ក្នុងស្ថានភាពនិមួយៗត្រូវបានយកមករៀបរាប់នៅខាងក្រោម ដោយការស្រាវជ្រាវជាផ្នែកមួយនៃផែនការរបស់ព្រះ ដែលសំរេចកិច្ចការរបស់ទ្រង់ជាមួយមនុស្ស ពេលវេលា និងទីកន្លែងច្បាស់លាស់។

- នៅក្នុងព្រះគម្ពីរជនគណនា ព្រះតំរូវអោយជនជាតិអ៊ីស្រាអែល ជ្រើសរើសទាហានច្រើនល្មមដើម្បីរៀបចំត្រៀមធ្វើចំបាំង (ជនគណនា ១:១-៤៦)។ រឿងនេះបណ្តាលអោយជនជាតិអ៊ីស្រាអែលរៀបចំប្រជាជនគេដើម្បីកាន់កាប់ទឹកដី។ សំរាប់ការបណ្តុះក្រុមជំនុំ ពត៌មានដែលទទួលបានពីការស្រាវជ្រាវអំពីអ្នកដែលអាចធ្វើកិច្ចការបាន គឺជាយុទ្ធសាស្ត្រសំខាន់សំរាប់ ចលនាប្រមូលផ្តុំ។
- ព្រះបានបញ្ជាអោយអ្នកស៊ើបការទៅប្រមូលពត៌មានជាដំបូង នៅលើទឹកដីដែលជនជាតិអ៊ីស្រាអែលនឹងកាន់កាប់ (ជនគណនា ១៣:១-១៤:៣៨)។ តាមរយះការស៊ើបអង្កេតរបស់អ្នកស៊ើបការ ជនជាតិអ៊ីស្រាអែលអាចមើលឃើញទឹកដីនិងកំនត់អំពីយុទ្ធសាស្ត្រដែលត្រូវប្រើ ព្រមទាំងថាតើឧបសគ្គអ្វីដែលត្រូវជំនះនៅពេលដែលគេលុកលុយដណ្តើមយកទឹកដី។

ចំពោះការបណ្ដុះក្រុមជំនុំ ការស្រាយជ្រាវបានល្អពីតំបន់នៃគោលដៅ អាចបង្ហាញពីប្រភេទនៃមនុស្សដែលត្រូវបញ្ចូលទៅក្នុងការបណ្ដុះក្រុមជំនុំនេះ និងពីរបៀបប្រាស្រ័យទាក់ទងផ្ទាល់ជាមួយមនុស្ស ព្រមទាំងឧបសគ្គដែលត្រូវយកជ័យជំនះលើ ។

✸ ព្រះយេស៊ូបានយាងទៅក្នុងចំនោមមនុស្សហើយបានឃើញពីសេចក្ដីត្រូវការរបស់ពួកគេមុនពេលដែលទ្រង់ចាត់សិស្សអោយចេញទៅធ្វើការក្នុងចំនោមពួកគេ (ម៉ាថាយ ៩: ៣៥-១០: ១) ។ ដោយផ្អែកទៅលើបទពិសោធន៏ផ្ទាល់ខ្លួនទ្រង់មានព្រះទ័យករុណា ជាពន់ពេកចំពោះពួកគេ ។ បទពិសោធន៏នៃការសង្កេតនេះបានជួយជំរុញទឹកចិត្តទ្រង់ ក្នុងការបង្រួបបង្រួមមនុស្ស ដើម្បីអធិដ្ឋាន និងធ្វើព័ន្ធកិច្ច ។ ចំពោះការបណ្ដុះក្រុមជំនុំ ការស្រាវជ្រាវជាដំបូង គឺផ្សារភ្ជាប់ជាមួយសេចក្ដីមេត្តាករុណា ការរួបរួមអធិដ្ឋាន និងព័ន្ធកិច្ច ។

✸ នៅក្នុងយ៉ូហាន ៤:៣៥ ព្រះអង្គម្ចាស់យេស៊ូបានបង្គាប់អោយសិស្សរបស់ទ្រង់ "សំឡឹងមើលទៅ" ចំរូតខាងឯព្រលឹងវិញ្ញាណរបស់មនុស្ស ។ ពេលខ្លះយើងភ្លេចពីសណ្ឋានដែលព្រះសំឡឹងមើលទៅមនុស្ស ។ តើយើងសំឡឹងមើលទៅមនុស្សដោយបែបយ៉ាងណាដែរ? តើយើងគ្រាន់តែមើលរំលងពួកគេរឺអី? តើយើងមើលគេចាត់ទុកដូចជាឧបសគ្គរឺ? គឺវាងាយស្រួលនឹងភ្លេចណាស់ថាព្រះចង់អោយយើងចេញទៅដើម្បីនាំមនុស្សមកឯទ្រង់ ។ ទ្រង់ប្រើការប្រៀបធៀបពីចំរូតនៅពេលដែលអ្នកជ្រូតចេញទៅឯវាល ដើម្បីប្រមូលផលផ្លែដែលទុំល្អ ហើយនាំយកទៅដល់ម្ចាស់ដី (យ៉ូហាន ៤: ៣៥-៣៨) ។

✸ នៅពេលដែលព្រះអម្ចាស់បន្ថែមចំនួនដល់ពួកគេ ក្រុមជំនុំដំបូងក៏នៅតែបន្តការលូតលាស់បង្កើនចំនួនក្នុងក្រុមជំនុំព្រមទាំងផ្សាយប្រាប់បន្តទៀត (កិច្ចការ ២: ៤១, ៤៧, ៤:៤, ៥: ១៤, ៩:៣១) ។ ហើយពតិមានបែបនេះបានផ្ដល់អោយនូវមុខសញ្ញាជាកន្លែង និងរបៀបដែលព្រះកំពុងធ្វើការក្នុងជីវិតមនុស្សនៃភូមិភាគណាមួយ ។

**តំរូវការសំរាប់ការស្រាវជ្រាវសព្វថ្ងៃ**

> ពតិមាន និងការស្រាវជ្រាវប្រាប់ដល់ក្រុមជំនុំពី អ្វីដែលត្រូវធ្វើ អ្នកណានឹងធ្វើការ ពេលណាចាប់ផ្ដើមធ្វើ ធ្វើនៅកន្លែងណា ហើយដឹងដោយរបៀបណានៅពេលដែលជំហាននៃ**កកគ**បានសំរេច ។

ការទទួលយក និងថែរក្សារូបភាពនៃ កំលាំងចំរូតដ៏ទាន់សម័យត្រឹមត្រូវមួយ ដែលក្រុមជំនុំបានធ្វើមក កំពុងធ្វើ ហើយនឹងត្រូវធ្វើបន្តទៀត នោះតំរូវអោយមានការធ្វើផែនការ ការស្រាវជ្រាវ និងការវាយតំលៃយ៉ាងប្រុងប្រយ័ត្ន ។ វាក៏មានសារៈសំខាន់ខ្លាំងណាស់ដែរក្នុងការសិក្សាអំពីចំរូតដែលក្រុមជំនុំធ្វើព័ន្ធកិច្ច ។ ជាញឹកញាប់ណាស់ដែលក្រុមជំនុំធ្វើការស្ថិតក្រោមសេចក្ដីសន្និដ្ឋានខុស ការស្រមោលស្រមៃគ្មានទិសដៅ បែបហួសសម័យ និងទិន្នន័យមិនត្រឹមត្រូវ ។ សេចក្ដីពិតពីម្សិលមិញ អាចងាយនឹងក្លាយជារឿងមិនពិតនៅថ្ងៃនេះ ។ នៅពេលដែលរឿងនេះកើតឡើង នោះអាណាចក្រនៃភពងងឹតនឹទទួលបានផលប្រយោជន៏ ។ យើងប្រលូកជាមួយនឹងចំបាំងនៃអាណាចក្រ (កូលុស ១:១៣-១៤) ។ ដើម្បីអោយនគរនៃពន្លឺយកជ័យជំនះលើចំបាំង យើងត្រូវតែយកការពិតជាទីពឹងជ្រក ។ សេចក្ដីពិតគឺជា ការពិត ភាពជាក់ស្ដែង និងពន្លឺដែលមានសារៈសំខាន់ក្នុងការតតាំងនឹងភពងងឹត ។ ព្រះយេស៊ូមានបន្ទូលថា "សេចក្ដីពិតនឹងដោះអ្នកអោយរួច" ប៉ុន្តែសេចក្ដីពិតដ៏ធំឧត្តមអំពីព្រះនឹងមិនមានឥទ្ធិពលទេ លុះត្រាតែមានទំនាក់ទំនង ទទួលយក ព្រមទាំង ប្រព្រឹត្តិតាមយ៉ាង

ល្អប្រសើរ។ ពតិមានល្អអំពី អ្នកដែលត្រូវឈោងចាប់យក ដែលជាវាលចំរូត គឺតំរូវអោយមានទំនាក់ទំនងដ៏ពិតយ៉ាងមានប្រសិទ្ធិភាព។ ពតិមានអពីលក្ខណៈនៃអ្នកដែលមិនទាន់បានសង្គ្រោះជួយអោយមានការបង្រួបបង្រួមរូបកាយទាំងមូលនៃព្រះគ្រីស្ទនៅក្នុងទីក្រុង រឺក៏ភូមិភាគ ដើម្បីឈោងចាប់មនុស្សទាំងអស់នោះដោយដំនឹងល្អ។

ពេលខ្លះការបណ្តុះក្រុមជំនុំ និងការអភិវឌ្ឍន៏ក្រុមជំនុំនៅនឹងថ្កល់ព្រោះខ្វះខាតនូវពតិមានដែលត្រឹមត្រូវ។ ជ័យជំនះក្នុងព័ន្ធកិច្ចតំរូវអោយមានលក្ខណៈដែលត្រឹមត្រូវដូចជា ពតិមាន របៀប ពេលវេលា និងការទទួលខុសត្រូវ។ ការទទួលបានពតិមានត្រឹមត្រូវមិនមែនធានាថាទទួលជោគជ័យនោះទេ តែអ្នកមិនអាចសំរេចការនោះបានដោយគ្មានវាដែរនោះទេ។ ហេតុអ្វីបានជាក្រុមជំនុំខ្លះក្នុងតំបន់មួយមានការរីកលូតលាស់ ហើយខ្លះទៀតមានការអន់ថយ រឺនៅក្រិន? ការស៊ើបអង្កេតយ៉ាងប្រុងប្រយ័ត្ន ជារឿយៗបង្ហាញអោយឃើញពីភាពខ្វះខាតនៃការយល់ដឹងពីលក្ខណៈខុសគ្នានៃ សង្គម និងវប្បធម៌ដែលមាន នៅក្នុងសង្គមមនុស្ស។ អ្នកដឹកនាំក្រុមជំនុំបែបនេះមើលឃើញវាលចំរូតទាំងអស់ហាក់បីដូចជាផ្លែប៉ោម ប៉ុន្តែមិនបានមើលឃើញដំឡូងនិងទំពាំងបាយជូរផងនោះទេ។

**ការស្រាវជ្រាវអំពី "ទីលានចំរូត"**

> ជាទូទៅ យើងត្រូវការពតិមានដើម្បីប្រាប់យើងអោយដឹងពីបញ្ហា៣យ៉ាងៈ
> ១,តើក្នុងកំឡុង១០ឆ្នាំកន្លងទៅ បានធ្វើអ្វីខ្លះហើយ?
> ២, តើអ្វីខ្លះទៅដែលកំពុងតែធ្វើនៅសព្វថ្ងៃនេះ?
> ៣, តើអ្វីទៅដែលនឹងត្រូវធ្វើតទៅទៀតដើម្បីឈានទៅដល់គោលដៅរបស់យើង?

ឃ្លា "ទីលានចំរូត" ត្រូវបានលើកឡើង ក្នុងសាច់រឿងចេញពីយ៉ូហានជំពូក ៤ ត្រង់ចំនុចនេះហើយដែលព្រះយេស៊ូ ទ្រង់បង្គាប់អោយសាវ័ករបស់ទ្រង់ "សំឡឹងមើល" ទៅឯទីលានចំរូត ដ្បិតបានក្រហមល្មមច្រូតហើយ។ ពាក្យថា "សំឡឹងមើល" និង "ទីលានចំរូត" អាចឃើញយ៉ាងច្បាស់។ "សំឡឹងមើល" មានន័យថា "សិក្សា រឺ ពិនិត្យពិច័យដោយការឆ្លុះបញ្ចាំងនូវការបកស្រាយនូវរបស់អ្វីមួយ" ពាក្យនេះនិយាយអំពីការស្រាវជ្រាវ។ ពាក្យថា "ទីលានចំរូត" សំដៅចំពោះមនុស្ស។ ព្រះយេស៊ូហៅពួកសាវ័កអោយសំឡឹងមើលទៅមនុស្សដែលកំពុងមកឯគេ ដែលអ្នកទាំងនោះ ដូចជាបានលឺតាមរយៈស្ត្រីអំពីព្រះយេស៊ូ និងដំនឹងល្អរបស់ទ្រង់ ដោយនៅពេលនោះព្រះយេស៊ូកំពុងតែមានព្រះបន្ទូលអំពីចំរូតខាងព្រលឹងវិញ្ញាណ (លូកា ១០, ម៉ាថាយ ៩)។

នៅពេលដែលយើងគិតថានឹងឈោងចាប់ដល់តំបន់នៃគោលដៅ (ដូចជាភូមិភាគណាមួយ ជារឿយៗ យើងប្រឈមមុខនឹងតំបន់នយោបាយ) រឺក៏ ប្រជាជននៃគោលដៅ (ដែលជារឿយៗយើងប្រឈមមុខនឹង វប្បធម៌ ទំនៀមទំលាប់ ភាសា និង ជំនឿរបស់ពួកគេ) ដូច្នោះហើយទើបយើងត្រូវការពតិមានជាច្រើនប្រភេទ។ អ្នកបណ្តុះក្រុមជំនុំគួរតែយល់ដឹងពីភាពខុសគ្នានៃ សង្គម វប្បធម៌ និងសាសនា នៃក្រុមដែលជាគោលដៅ។ ជាញយដង យើងត្រូវការវិធីសាស្ត្រថ្មីៗសំរាប់ការផ្សាយដំនឹងល្អ ការបណ្តុះបណ្តាល និងការបណ្តុះក្រុមជំនុំ។ ការនេះក៏អាចយកទៅប្រើសំរាប់ក្រុមជំនុំដែលមានស្រាប់ហើយ។ "ជំនួញធម្មតា" បង្កើតអោយមាន "ផលធម្មតា" ការផ្លាស់ប្តូរនៃពេលវេលាដែលយើងរស់នៅ ជាញឹកញាប់ បង្កើតអោយមាន

ភាពមិនចុះសំរុងគ្នារវាងក្រុមជំនុំនិងមនុស្សជំនាន់ក្រោយ ។ ចំពោះការយល់ដឹងត្រូវតែទទួលយកពីការឆ្លុះបញ្ចាំងពីពិភពលោក ហើយគំនិតខាងក្រៅក្រុមជំនុំផង ។ ការប្រមូលផ្តុំពត៌មានអំពីទីលានចំរូតអាចត្រូវធ្វើឡើងតាមរយៈការសាកសួរនិងការស្រង់មតិផ្ទាល់តែម្តង់ ។ ទិន្នន័យជាមូលដ្ឋាននៃទីលានចំរូតខ្លះអាចទទួលបានពីក្នុងមជ្ឈដ្ឋានសង្គម បណ្ណាល័យ និង ការិយាល័យរដ្ឋការ ។ ពត៌មានបន្ថែមទៀតអាចទទួលបានតាមរយៈ កុំព្យូទ័រ គឺ អ៊ិនធឺណែត និង តាមវែបសាយធ៍ ។ មួយចំនួនខ្លះទៀតនៃ "មូល ដ្ឋានស្រាវជ្រាវ" នឹងមានសារៈសំខាន់ក្នុងការបំពេញនូវចន្លោះខ្វះខាត អោយទាន់សម័យ ព្រមទាំងធ្វើអោយមានសុពលភាព ។ តំបន់នៃការស្ទាបស្ទង់ និង សាកសួរ គួរតែត្រូវធ្វើឡើងដើម្បីអោយដឹងពីមូលដ្ឋានថ្មីៗ នៃសេចក្តីត្រូវការខាងសាច់ឈាម សតិអារម្មណ៏ និងវិញ្ញាណផ្សេងៗ ។ វាក៏អាចមានសារៈប្រយោជន៏ក្នុងការសាកសួរមន្ត្រីរាជការតាមតំបន់ដើម្បីអោយដឹងថាតើពួកគេត្រូវការជំនួយបែបណា និងដើម្បីសូមអោយអ្នកដ៏ទៃទៀតអធិដ្ឋានដល់គេជានិច្ច!

**ការស្រាវជ្រាវអំពី "កំលាំងចំរូត"**

កំលាំងចំរូត ផ្តុំឡើងពី ក្រុមជំនុំ និកាយ ក្រុមជំនុំចំរុះ រួមទាំងវិទ្យាស្ថានអប់រំ ការបណ្តុះបណ្តាលព័ន្ធកិច្ច ព្រមទាំងការផ្សព្វផ្សាយពត៌មានគ្រីស្ទានផ្សេងៗ ។ ដើម្បីប្រមូលទិន្នន័យនៃកំលាំងចំរូតអ្នកត្រូវដឹងពីចំនួននៃក្រុមជំនុំ អត្តសញ្ញាណរបស់គេ របៀបរៀបចំសមាគមន៏ ទំហំនិងការចែកចាយតាមទីតាំង និងមនុស្សតាមក្រុម ។ វាមានសារៈសំខាន់ណាស់ក្នុងការរកអោយឃើញថាតើស្ថានភាពក្រុមជំនុំដើរដល់ណាហើយ ដែលយើងអាចគត់សំគាល់ថា ក្រុមជំនុំមួយណារីកចំរើនមួយណាមិនរីកចំរើន តើហេតុអ្វី? អ្នកនឹងចង់ដឹងថា អ្នកណាចូលរួមក្នុងក្រុមជំនុំ ហើយអ្នកណាមិនចូលរួម តើហេតុអ្វី? ជាចុងក្រោយ វាមានសារៈសំខាន់ក្នុងការរកអោយឃើញថា អ្នកណាប្រើវិធីសាស្ត្រជោគជ័យខាងផ្នែកការដឹកនាំ ការផ្សាយដំនឹងល្អ ការបណ្តុះបណ្តាល ព័ន្ធកិច្ចនៃក្តីមេត្តា និងការបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជុំ ។

ជួនកាលពត៌មានដែលត្រូវការខ្លះអាចមានរួចទៅហើយ ហើយប្រើការបាន ភាគច្រើននៃពត៌មានទាំងនេះនឹងត្រូវទទួលយកជាដំបូង ។ នេះជាការល្អ ដែលអ្នកត្រូវសិក្សាអោយបានច្បាស់ពីពត៌មានដែលអ្នកមានរួចហើយ ។ វាមិនត្រឹមតែបង្កើនចំនេះដឹងជាមូលដ្ឋានរបស់អ្នកទេ ប៉ុន្តែវាក៏ផ្តល់អោយអ្នកនូវភាពជឿជាក់ បើគ្មានវាទេគឺមិនអាចធ្វើទៅរួចបានឡើយ ។

**ពត៌មានដែលត្រូវការ-សង្ខេបឡើងវិញ**

- គត់សំគាល់ ស្វែងរកទីតាំង និងពិពណ៌នាអំពីស្ថានភាពនៃវាលចំរូតនិង កំលាំងចំរូត ។
- ផ្តល់អោយនូវរូបភាពដែលច្បាស់លាស់មួយអំពីកន្លែងដែលក្រុមជំនុំត្រូវបោះទីតាំង និងកន្លែងដែលមិនត្រូវបោះ ។ សូមប្រើផែនទីដើម្បីធ្វើការនេះ ។
- គត់សំគាល់ពីកន្លែងដែលក្រុមជំនុំកំពុងលូតលាស់ និងមិនលូតលាស់ ហើយខំអោយបានយល់ពីមូលហេតុនេះ ។
- ផ្តល់នូវរូបភាពដែលច្បាស់លាស់មួយពីក្រុមកុលសម្ពន្ធ និងវប្បធម៌ដែលបង្កើតឡើងជាតំបន់មួយ ។
- វាយតំលៃពីទីកន្លែងនៃក្រុមជំនុំសព្វថ្ងៃនេះដោយប្រៀបធៀបថ្មីមទៅនឹងគោលដៅរយៈពេលខ្លី និងរយៈពេលវែង ។
- ពិពណ៌នាពីកិច្ចការដែលនៅសល់ដើម្បីឈោងចាប់គោលដៅ សំរាប់ទីតាំង កុលសម្ពន្ធនិងវប្បធម៌តាមក្រុមផ្សេងៗ ។

- គត់សំគាល់ពីតំបន់សំខាន់ៗនៃសង្គមដែលមានទុក្ខលំបាកវេទនា ។
- ពិពណ៌នាពីប្រវត្តិនៃនយោបាយ  វប្បធម៌ និង ព្រលឹងវិញ្ញាណ ។ គត់សំគាល់ពីទីមាំមួនរបស់ខ្មាំងសត្រូវ ។
- ពិចារណាអំពីក៏រិតនៃការជះឥទ្ធិពលនិងផលប៉ះពាល់របស់ក្រុមជំនុំទៅលើ កត្តាផ្សេងៗនៃសង្គម ។

**ប្រើប្រាស់ពត៌មានដែលទទួលបានពីការស្រាវជ្រាវ**

ទោះបីជាពត៌មានវាសំខាន់ហើយមានប្រយោជន៏ក៏ដោយ គង់តែវាត្រូវការមនុស្សដើម្បីសំរេចកិច្ចការដែរ  គឺដើម្បីអោយមនុស្សស្មោះត្រង់របស់ព្រះទាំងប្រុសទាំងស្រីដែលមានការប្តេជ្ញាចិត្តចង់ឃើញផែនការរបស់ព្រះបានបំពេញដល់រូបកាយនិងកូនក្រមុំរបស់ទ្រង់  ដែលជាអ្នកថែរក្សាជ័យកចិត្តទុកដាក់ក្នុងការហ្វឹកហាត់ប្រើប្រាសអំណោយទាននិងជំនាញរបស់គេ ហើយជាអ្នកដែលនឹងលះបង់ដើម្បីអោយអ្នកដ៏ទៃទៀតមានជីវិត ។

ការចែកចាយលទ្ធផលនៃការស្រាវជ្រាវដល់ការដឹកនាំនៃតំបន់អាចធ្វើអោយមានការភ្លឺភ្នែកឡើង ។ វាជួយអោយគេឃើញពីលក្ខណៈដែលព័ន្ធកិច្ចរបស់ពួកគេចូលទៅក្នុងរូបភាពធំទាំងមូល ។  នៅពេលដែលគេឃើញការងារដែលនៅសល់នោះពួកគេដឹងថាគេមានចំនែកក្នុងការបង្ហើយកិច្ចការនេះ ដោយខ្លួនគេផ្ទាល់ ព្រមទាំងអ្នកដទៃទៀតផង ។  ពត៌មានបូកបញ្ចូលជាមួយនឹង ការបើកសំដែងពីកិច្ចការនិងបំណងព្រះហឫទ័យរបស់ទ្រង់នោះផ្តល់នូវ "ការត្រាសអោយហៅធ្វើកិច្ចការ "ដល់ក្រុមជំនុំដើម្បីដឹកនាំទៅដល់ការកាន់កាប់ទឹកដីក្នុងមនុស្សជំនាន់នេះ ។

# ៨

# ការបំផុសនិមិត្ត



### ជំរុញទឹកចិត្តរាស្ត្ររបស់ព្រះអោយធ្វើកិច្ចការរបស់ទ្រង់

### និមិត្តបង្ហាញពីទិសដៅ

និមិត្តនាំមនុស្សអោយឆ្ពោះទៅមុខ គឺថាៈវាផ្តល់អោយពួកគេនូវ ទិសដៅ ។ នៅភូមិភាគខ្លះខ្វះខាតចលនានៃការបណ្តុះក្រុមជំនុំ ពីព្រោះក្រុមជំនុំតំបន់នៅទីតាំងទាំងនោះមិនមាននិមិត្ត ។ ចុះតើមនុស្សអាចខំឆ្ពោះទៅរកការដែលគេមើលមិនឃើញយ៉ាងដូចម្តេច រឺក៏មើលឃើញត្រឹមតែគោលដៅមិនច្បាស់លាស់ដែលត្រូវសំរេចបាននៅពេលអណាគតរឺអី? ហាក់បីដូចជាប៉មបញ្ចាំងភ្លើងសំរាប់នាំផ្លូវនាវាដែរ ឯនិមិត្តជួយដល់យើងអោយនៅតែសំលឹងមើលត្រង់ទៅឯគោលដៅជានិច្ច ។ យើងមិនអាចធ្វើចលនាទៅកាន់ទីដែលយើងមិនអាចមើលឃើញបានទេ ។ ប៉ុន្តែបើសិនជាយើងនៅតែផ្ចង់មើលទៅឯគោលដៅ នោះផ្លូវរបស់យើងនឹងបានត្រង់ ។

### និមិត្តជំរុញនូវការលើកទឹកចិត្ត

បញ្ហាមួយដែលធំជាងគេបំផុតនៅក្នុងក្រុមជំនុំសព្វថ្ងៃនេះគឺផ្តើមចេញពីការដែលមិនបានយល់ដឹងពីគោលបំណងពិតប្រាកដនៃក្រុមជំនុំរបស់ខ្លួន ។ រូបកាយនៃព្រះទោរទន់ទៅរកការងោគងុយ ។ ហាក់បីដូចជាចៀមគ្មានអ្នកគង្វាល ដោយសារតែឧបសគ្គបន្តិចបន្តួចនោះធ្វើអោយប្រជារាស្ត្ររបស់ផងព្រះបាត់បង់នូវជំហាននៃក្តីជំនឿក្នុងការសំឡឹងទៅរកគោលដៅ ដែលគេត្រូវការពីគំនិតនៃ "**អ**" ។ ការបំផុសនិមិត្តនាំក្រុមជំនុំអោយត្រលប់ទៅរក ការយល់ដឹងសារជាថ្មីវិញអំពីគោលបំណងរបស់ខ្លួន ហើយបន្ទាប់មកក៏ធ្វើការទទួលខុសត្រូវលើក្រុមជំនុំតំបន់អោយឆ្ពោះទៅរកគោលបំណងវិញ ។ អ្នកជឿទាំងឡាយ ត្រូវតែរំលឹកអោយបានទៀងទាត់អំពីបំណងសំខាន់របស់ព្រះ ថាជាគោលបំណងរបស់យើង គឺថាៈ ត្រូវធ្វើជាឧបករណ៍សំរាប់ផ្សះផ្សារជាតិសាសន៍ទាំងអស់ទៅនឹងព្រះជាម្ចាស់ ។ និមិត្តត្រូវបានគេបំផុលបំផុសហើយបំផុលបំផុស ឡើងវិញទៀត ។ វិធីផ្សេងៗដើម្បីសំរេចការនេះ គឺតាមរយៈការអធិប្បាយនិងការបង្រៀន អំពីគោលបំណងរបស់ក្រុមជំនុំ និងសណ្ឋាននៃកិច្ចការមហាបេសកកម្ម រឺក៏ដោយពិភាក្សាពីគំនិតនៃ "**អ**" និងដោយសួរសំនួរដ៏ចំបាច់មួយថា "តើព្រះទ្រង់សព្វហឫទ្យព្រះទ័យធ្វើអ្វី?"

### និមិត្តនិងសេចក្តីជំនឿ

បំណងព្រះហឫទ្ស័យដ៏ជាក់ច្បាស់របស់ព្រះគឺចង់អោយមានសិស្សនៅគ្រប់ទាំងកុលសម្ពន្ធនិងមនុស្សជាតិ ។ ប៉ុន្តែមនុស្ស

មួយចំនួនឆ្លើយតបដោយចិត្តសង្ស័យក្នុងការសំរេចគោលដៅនេះដោយសំអាងថាៈ "យើងជាមនុស្សតូចទាបហើយក្រីក្រណាស់យើង គ្មានសមត្ថភាពរួមចំណែកក្នុងកិច្ចការនេះបានទេ ហើយវាមិនអាចធ្វើទៅរួចបានឡើយ" តើព្រះទ្រង់ត្រាស់ហៅយើងអោយធ្វើកិច្ចការដែលយើងមិនអាចធ្វើកើតឬ? តើព្រះទ្រង់ហៅយើងអោយធ្វើកិច្ចការ ដោយមិនបានបំពាក់បំប៉នយើងឬអី? បើសិនជាដូច្នោះមែន តើមានបាត់អ្វីទៅ? នោះគឺសេចក្តីជំនឿ!

ក្នុងព្រះគម្ពីរហេព្រើរ ១១:៦ យើងបានអានថា "តែបើឥតមានសេចក្តីជំនឿទេនោះមិនអាចនឹងគាប់ដល់ព្រះ ហឫទ័យព្រះបានឡើយ" នៅក្នុងជំពូកដដែល យើងអានពី វិរបុរសដ៏អស្ចារ្យមួយចំនួនក្នុងគម្ពីរសញ្ញាចាស់ ដែលមានជំនឿ លើកិច្ចការដែលព្រះត្រាស់ហៅអោយធ្វើ ហើយគេប្រតិបត្តិតាមសេចក្តីជំនឿនោះដែរ ដែល "ដោយសារសេចក្តីជំនឿនោះគេបានឈ្នះនគរដទៃ បានសំរេចការសុច្ចរិត បានទទួលសេចក្តីសន្យា" (ហេប្រើ ១១:៣៣)។ ព្រះផ្តល់និមិត្តមួយដល់យើង។ ជំនឿមានសារៈ សំខាន់ដើម្បីអោយយើងធ្វើអោយបានលើសជាងការដែលយើងគ្រាន់តែ ក្រលេកមើលទៅនិមិត្ត ហើយនិយាយថា "ខ្ញុំយល់ព្រម" ក៏ប៉ុន្តែតែ។ "ដើម្បីអោយចលនានៃការបណ្តុះក្រុមជំនុំនៅក្នុងភូមិភាគរបស់អ្នកមានដំនើរការ ពិតប្រាកដ អ្នកត្រូវតែឆ្លើយតបទៅនឹងនិមិត្តដោយជំនឿ។" ការឆ្លើយតបដោយជំនឿនឹងបានពរមកពីព្រះ!

## តួនាទីរបស់អ្នកនៅក្នុងការបំផុសនិមិត្ត



ដោយខ្លួនអ្នកផ្ទាល់ តើអ្នកអាចធ្វើអោយកើតមានក្រុមជំនុំឡើងសំរាប់មនុស្សជាតិគ្រប់គ្នាក្នុងប្រទេសជាតិរបស់អ្នក បានទេ.? ពិតមែនហើយ គឺមិនបានទេ។ ម្តងទៀត ដោយខ្លួនអ្នកផ្ទាល់ តើអ្នកអាចធ្វើអោយកើតមានក្រុមជំនុំឡើងសំរាប់មុស្សជាតិគ្រប់គ្នាក្នុងតំបនីក្នុងទីក្រុងរបស់អ្នក បានីទេ.? គឺពិតជាមិនបានទេ។ ប៉ុន្តែព្រះអាចជួយអ្នកអោយឈោងចាប់គោលដៅនិមួយៗទាំងនេះបាន។ មានកិច្ចការមួយចំនួនដែលអ្នកអាចធ្វើដើម្បីជំរុញទឹកចិត្ត និងប្រាប់ដល់អ្នកដទៃដើម្បី ធ្វើអោយនិមិត្តរបស់ព្រះត្រលប់ជានិមិត្តរបស់គេរៀងខ្លួន ព្រមទាំងធ្វើការរួមគ្នាជាមួយនឹងពួកគេដើម្បីឆ្ពោះទៅរកការបំពេញនិមិត្តនោះ។

**និមិត្តគឺជាថាមពលដែលរក្សាស្ថេរភាពចលនាអោយឆ្ពោះទៅមុខជានិច្ច។ ដូច្នោះត្រូវតែរក្សានូវការបំផុសនិមិត្តជានិច្ច។**

## ទីមួយត្រូវមាននិមិត្ត

ផែនការរបស់ព្រះមិនតំរូវអោយអ្នកមានក្រុមជំនុំនោះទេ ប៉ុន្តែត្រូវតែបង្កើតសិស្សនៅគ្រប់ទាំងសាសន៍វិញ។ ចូរក្រលេកមើលទៅទីលានចំរូតទាំងមូល មិនមែនគ្រាន់តែមើលទៅចំរូតមួយផ្នែកតូចរបស់អ្នកដែលឃើញ ថាវាទុំល្មមច្រូតហើយនោះទេ។ ចូរស្វែងរកកិច្ចការដែលព្រះកំពុងតែធ្វើនៅក្នុងភូមិភាគរបស់អ្នក។ រួចអោយមានចិត្តឆេះឆួលនៅក្នុងកិច្ចការរបស់ព្រះ។ ចាប់ផ្តើមអធិដ្ឋានសំរាប់ទីលានចំរូតទាំងមូល។ ព្រមទាំងទទួលស្គាល់ថាអ្នកមានចំណែកនៅក្នុងកំលាំងចំរូតរបស់ព្រះសំរាប់តំបន់របស់អ្នក។

**ទីពីរ ចែកចាយនិមិត្ត**

ចែកចាយនូវចិត្តឆេះឆួលរបស់អ្នកអំពីនិមិត្តរបស់ព្រះ ។ ជួយអ្នកផ្សេងទៀតក្នុងក្រុមជំនុំរបស់អ្នកអោយគេដឹងថាគេក៏មានចំណែកក្នុងផែនការរបស់ព្រះសំរាប់ពិភពលោកនេះ ។ ហើយកំលាទឹកចិត្តពួកគេអោយយល់ពីសារៈសំខាន់នៃការងាររបស់គេ ។ ព្រមទាំងអធិដ្ឋានជាមួយពួកគេសំរាប់ទីលានចំរូតទាំងមូល ។ ឧទាហរណ៍ ដូចជាធ្យូងបើសិនជាវានៅតែឯង នោះងាយនឹងរលត់ណាស់ តែបើសិនជានៅផ្តុំគ្នាវិញ នោះកំដៅនឹងកាន់តែខ្លាំងហើយនៅបានយូរ ។ ឯគ្រីស្ទានក៏បែបនេះដែរ ។

**ទីបី ផ្តើមធ្វើតាមនិមិត្ត**

សហការជាមួយគ្រូគង្វាលឯទៀតនៅក្នុងភូមិភាគរបស់អ្នក ។ ចែកចាយនិមិត្ត របស់អ្នកដើម្បីអោយឃើញថា ភូមិភាគទាំងមូលបានបង្កើតសិស្សសំរាប់សិរីល្អនៃព្រះ ។ អធិដ្ឋានជាមួយពួកគេសំរាប់បំពេញនូវមហាបេសកកម្ម នៅភូមិភាគរបស់អ្នក ។ ធ្វើការជាមួយគ្រូគង្វាលនិងក្រុមជំនុំដែលមានចិត្តគំនិតដូចគ្នាដើម្បីឈោងចាប់ភូមិភាគទាំងមូលរបស់អ្នក ។ ចាប់ផ្តើមធ្វើការស្រាវជ្រាវដើម្បីរុករកទីកន្លែងសំរាប់បង្កើតក្រុមជំនុំថ្មី ។ ធ្វើគំរោងការអធិដ្ឋានយ៉ាងជាក់ច្បាស់អំពីកន្លែង និងរបៀបក្នុងការបណ្តុះក្រុមជំនុំថ្មីទាំងនេះ ។ ចាប់ផ្តើមបណ្តុះបណ្តាលអ្នកដែលអាចបណ្តុះក្រុមជំនុំទាំងនោះ ។ ផ្តល់កំលាំងដល់អ្នកដឹកនាំថ្មីៗទាំងនេះដើម្បីអោយបណ្តុះក្រុមជំនុំថ្មីៗជាច្រើនទៀត ។ ធ្វើការស្រាវជ្រាវ និងអធិដ្ឋានអោយកាន់តែច្រើនថែម ទៀត ។

**សេចក្តីបញ្ចប់**

ការបំផុសនិមិត្តបង្កើនអោយមានកំរិតនៃការប្តេជ្ញាចិត្តចំពោះគោលបំណងរបស់ព្រះសំរាប់ក្រុមជំនុំ ។ ប៉ុន្តែនិមិត្តផ្តល់អោយនិងបណ្តាលអោយមានទិសដៅ លើកលែងតែមនុស្សគេបានលឺ បានយល់ហើយមានការផ្លាស់ប្រែក្នុងចិត្តនូវអ្វីដែលគេអាចទទួលបាន ។ និមិត្តក្នុងព្រះបន្ទូល ត្រូវតែមានការបំផុសឡើងដើម្បី ធ្វើអោយមានការឆេះឆួលក្នុងជំនឿ និងធ្វើអោយមានការផ្លាស់ប្រែខាងក្នុងចិត្តក្នុងជីវិតរបស់មនុស្ស ។ បើសិនជាតំលៃនៃជីវិតមនុស្សជាច្រើន មិនមានការផ្លាស់ប្រែទេ នោះការផ្លាស់ប្រែក្នុងលក្ខណៈជាចំបងដូចជា ក្នុងឥរិយាបថ ការប្រព្រឹត្ត និងព័ន្ធកិច្ចគ្រាន់តែជាការបង្ហាញអោយគេឃើញ ហើយក្នុងរយះពេល ខ្លីប៉ុណ្ណោះ ។

**និមិត្តត្រូវតែបន្តអោយមានជាស្ថេរភាពចំពោះមុខមនុស្សដើម្បីនាំមកនូវ ការផ្លាស់ប្រែខាងក្នុងដែលជាលទ្ធផលបង្ហាញអោយឃើញសកម្មភាពខាងក្រៅដែលនាំទៅដល់ចលនានៃការបណ្តុះក្រុមជំនុំតាមព្រះគម្ពីរ ។**

# ៩

# ការផ្សាយដំនឹងល្អ ដែលនាំទៅដល់ការបណ្ដុះក្រុមជំនុំ

វាមិនអាចទៅរួចបានទេក្នុងការបណ្ដុះក្រុមជំនុំដោយគ្មានការផ្សាយដំនឹងល្អ ប៉ុន្តែការផ្សាយដំនឹងល្អតែមួយមុខគត់គឺមិនគ្រប់គ្រាន់ទេ។ ចំពោះអ្នកដែលបណ្ដុះក្រុមជំនុំ គោលដៅគឺមិនមែនគ្រាន់តែធ្វើអោយមនុស្សដឹងពីដំនឹងល្អ រឺក៏គ្រាន់តែធ្វើការសំរេចចិត្តជាធម្មតាដើម្បីព្រះគ្រីស្ទនោះទេ។ លើសពីនេះទៀត គោលដៅនោះគឺបង្កើតអោយមានសិស្សដែលនឹងមករួមគ្នាដើម្បីថ្វាយបង្គំនិងធ្វើការរីកចំរើនក្នុងចង្កោមនៃរាស្ត្ររបស់ផងព្រះ។ បើសិនជាក្រុមជំនុំគឺជាឧបករណ៏ដ៏សំខាន់របស់ព្រះដើម្បីធ្វើការផ្សាយដំនឹងល្អលើពិភពលោក នោះជានិច្ចកាលការផ្សាយដំនឹងល្អគួរតែបង្កើតអោយមានជាការរីកលូតលាស់ក្រុមជំនុំរឺការបណ្ដុះក្រុមជំនុំតំបន់។

**ស្ពានទាំង២- ព្រះពន្ទូលនិង ការទំនាក់ទំនង**



| ស្ពានទី១ | ស្ពានទី២ |
|---|---|
| ការពិតនៃព្រះបន្ទូល | ការទំនាក់ទំនង |
| ដំណឹងល្អត្រូវបានលឺ | ដំណឹងល្អត្រូវបានឃើញ |
| ការពិតអំពីព្រះ | សង្គមមនុស្ស |
| ផែនការ នៃការសង្គ្រោះ | ក្រុមជំនុំ |

ស្ពានទាំង២ត្រូវតែបានឆ្លងកាត់ដើម្បីនាំទៅដល់ការសង្គ្រោះដែលជ្រាតចូលទៅក្នុងក្រុមជំនុំតំបន់។ ស្ពានទី១ គឺជាវិជ្ជាអំពីព្រះ។ ការនេះទាក់ទងទៅនឹងការពិតអំពីព្រះដែលជាមូលដ្ឋាននៃដំនឹងល្អ។ ១ទៀតជាស្ពាននៃទំនាក់ទំនង។ វាត្រូវតែមានការទំនាក់ទំនងដែលជួយដល់មនុស្ស អោយរួមសាមគ្គី ទៅក្នុងការប្រកបគ្នានៃអ្នកជឿទាំងអស់ក្នុងតំបន់ណាមួយ។ បើសិនជាមនុស្សបានលឺ (បានទទួលការពិតនៃព្រះបន្ទូល) ដោយគ្មានបទពិសោធន៍ជាមួយការទំនាក់ទំនង នោះដំណើរការនៃការ បង្កើតសិស្សនឹងមិនបានយូរអង្វែងឡើយ។

**គោលការណ៏សំខាន់៧ដែលជួយផ្សារភ្ជាប់ការផ្សាយដំនឹងល្អទៅនឹងការបណ្តុះក្រុមជំនុំ**

ជាញឹកញយការផ្សាយដំនឹងល្អតាមរបៀបចាស់នាំមនុស្សអោយទៅដល់ចំនុចមួយនៃការសំរេចចិត្តខ្លួនឯងសំរាប់ព្រះគ្រីស្ទ ប៉ុន្តែមិនបាននាំពួកគេអោយឆ្លងកាត់ស្ពាននៃការទំនាក់ទំនងទៅក្នុងការប្រកបគ្នានៃអ្នកជឿតាមតំបន់ទេ។ ដូច្នេះ អ្នកជឿថ្មី នៅតែមិនបានបណ្តុះបណ្តាលអោយក្លាយជាសិស្ស រឺមិនបានទទួលការជះឥទ្ធិពលពីអ្នកជឿដទៃទៀតឡើយ។

ក្នុងចំនោមមួយរឺទាំងអស់នៃគោលកាណ៏ខាងក្រោម អ្នកដឹកនាំក្រុមជំនុំរឺក៏អ្នកបណ្តុះក្រុមជំនុំអាចនាំជីវិតមនុស្សបាត់បង់អោយឆ្លងកាត់ស្ពានទាំង២ ដែលនាំគេអោយបានសង្គ្រោះហើយមានចំនែកយ៉ាងសកម្មក្នុងរូបកាយនៃព្រះគ្រីស្ទ។

**១.ប្រើប្រាសនិមិត្តនៃការបណ្តុះក្រុមជំនុំដើម្បីដឹកនាំការឃោងចាប់ដោយដំនឹងល្អ**

អស់អ្នកដែលចូលក្នុងការងារផ្សាយដំនឹងល្អ ក្នុងគំនិតរបស់គេត្រូវតែមាន "**អ**"។ អ្នកទាំងនោះនាំមនុស្សទៅក្នុងសេចក្តីសង្គ្រោះនៃព្រះគ្រីស្ទ ហើយធ្វើគ្រប់ការទាំងអស់ទាំងបន្តការហ្វឹកហ្វឺនដល់អ្នកជឿថ្មីដើម្បីអោយគេបានរីកចំរើន និងអាចប្រកបគ្នាជាមួយអ្នកជឿផ្សេងទៀតបាន។ ដូច្នោះ យុទ្ធសាស្រ្តនៃការផ្សាយដំនឹងល្អគួរតែធ្វើគំរោងការណ៏ សំរាប់បណ្តុះក្រុមជំនុំថ្មីៗ។ ក្រុមផ្សាយដំនឹងល្អ គួរតែទទួលខុសត្រូវចំពោះការងារដែលធ្វើជាមួយក្រុមជំនុំផ្សាយដំនឹងល្អក្នុងតំបន់អោយអស់ពីសមត្ថភាពដែលពួកគេអាចធ្វើទៅបានដើម្បីបង្វឹកបង្វឺនអ្នកជឿថ្មីទាំងឡាយ។ កន្លែងដែលគ្មានក្រុមជំនុំសោះ យុទ្ធសា-ស្រ្តទាំងឡាយគួរតែបានអភិវឌ្ឍដើម្បីចាប់ផ្តើមក្រុមជំនុំថ្មីពីអ្នកជឿដំបូង។

**២.ប្រើប្រាសទំនក់ទំនងធម្មជាតិ**

មនុស្សគ្រប់គ្នាមានទំនក់ទំនងជាមួយមិត្តភ័ក្ត បងប្អូន អ្នករួមការងារ និងអ្នកដទៃទៀតដែលគេស្គាល់ច្បាស់ហើយជាអ្នកដែលគេទាក់ទងយ៉ាងទៀងទាត់ ។ ការទំនាក់ទំនងជាធម្មជាតិនេះផ្តល់អោយនូវសេរីភាពក្នុងការបញ្ចេញមតិ។ ជាញយដង ការផ្លាស់ប្រែជំនឿ "ធ្វើដំណើរ" តាមរយះបណ្តាញទាំងនេះដោយព្រោះថាដំនឹងល្អ ប្រៀបដូចជាចរន្តអគ្គិសនីនៅតាមផ្លូវដែលមិនសូវមានការរាំងស្ទះទេ។

ព្រះយេស៊ូទ្រង់ជ្រាបពីទំនាំទំនងធម្មជាតិទាំងនេះ ហើយមានសមត្ថភាពឃោងចាប់មិនគ្រាន់តែបុគ្គលម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តាញទាំងឡាយនៃបុគ្គលទាំងនោះដ៏ល្អប្រសើរផង។ នៅក្នុងព្រះគម្ពីរម៉ាថាយ ៩: ៩-១០ ព្រះយេស៊ូមានបន្ទូល ហៅលោកម៉ាថាយ ហើយបន្ទាប់មកក៏យាងទៅឯផ្ទះរបស់លោកដែលនៅទីនោះ មានបណ្តាញនៃអ្នកយកពន្ធទាំងអស់បានមកជុំគ្នា ។ បន្ទាប់ ពីព្រះយេស៊ូបានជួបលោកអនទ្រេ ដែលជាអ្នកនេសាទ រំពេចនោះក្រុមនៃអ្នកនេសាទទាំងអស់បាន

ដើរតាមទ្រង់ដែរ (យ៉ូហាន ១: ៤០-៤១)។ នៅពេលដែលព្រះយេស៊ូផ្សាយដំនឹងល្អជាមួយមនុស្សម្នាក់ ទ្រង់តែងតែប្រាប់អោយអ្នកនោះផ្សាយដំនឹងល្អ នេះទៅដល់អស់អ្នកដែលនៅក្នុងបណ្តាញរបស់ផងគេ (លូកា ៨:៣៨-៣៩)។ ដូចគ្នានេះដែរ ព្រះគម្ពីរកិច្ចការគឺពោរពេញទៅ ដោយសាច់រឿងនៃក្រុមគ្រួសារទាំងមូល (កិច្ចការ១១:១៤, ១៦:៣១) និងភូមិទាំងមូល (កិច្ចការ៩:៣៥) បានទទួលជឿ ដល់ព្រះគ្រីស្ទដោយសារតែការផ្លាស់ប្រែរបស់មនុស្សតែម្នាក់។

**៣. តំរូវអោយអ្នកជឿថ្មីធ្វើទីបន្ទាល់ភ្លាមៗ**

ជំនឿដែលរកឃើញថ្មីអាចបន្តការរាលដាល។ ទោះបីជាគ្មានការយល់ដឹងជ្រាលជ្រៅអំពីព្រះក៏ដោយ អ្នកជឿថ្មីៗនឹងមានសេចក្តីអំណរ ក្នុងការចែកចាយទីបន្ទាល់នៃការផ្លាស់ប្រែដែលកើតមានឡើងដោយក្តីមោះមុតបំផុត។ អ្នកដទៃអាចឃើញការផ្លាស់ប្រែភ្លាមបន្ទាប់ពីការទទួលជឿរបស់គាត់ ប្រសើរជាងគេអាចឃើញការផ្លាស់ប្រែនេះក្រោយពេលដែលគាត់ឆ្លងកាត់ស្ថានភាពលូតលាស់បែបជាគ្រីស្ទានហើយ។

ព្រះគម្ពីរយ៉ូហានជំពូក៤ផ្តល់អោយនូវឧទាហរណ៍ ដ៏ល្អនៃអ្នកជឿដំបូងបំផុតដែលជាទីបន្ទាល់មួយដ៏មានប្រសិទ្ធិភាព។ នៅពេលដែលស្ត្រីសាសន៏សាមារីមានបាប បានជួបជាមួយព្រះយេស៊ូគ្រីស្ទ គាត់បានធ្វើទីបន្ទាល់យ៉ាងសាមញ្ញ ប៉ុន្តែស៊ីជំរៅដែលថា: "ចូរមកមើលបុរសម្នាក់ដែលបានប្រាប់ខ្ញុំពីរឿងរ៉ាវដែលខ្ញុំធ្លាប់បានធ្វើ។ តើនេះអាចជាព្រះគ្រីស្ទទេ? " ស្ត្រីម្នាក់នេះមិនអាចឆ្លើយសំនួរដ៏ពិបាកអំពីព្រះបានទេ តែគាត់បានដឹងពីរឿងដែលបានកើតឡើងចំពោះគាត់។ ហើយតើនណាអាចជំទាស់នឹងគាត់បាន? ព្រោះគាត់និយាយតែពីអ្វីដែលគាត់ធ្លាប់បានបទពិសោធន៏ហើយ។ ទាំងនេះគឺជាការដែលគាត់ត្រូវដឹងដើម្បីនាំអ្នក ដទៃទៀតទៅឯព្រះគ្រីស្ទ។ មនុស្សជាច្រើនប្រញាប់ប្រញាលចេញពីទីក្រុងដើម្បីទៅជួបព្រះយេស៊ូ។ តើទីបន្ទាល់ដែលស្ត្រីនេះត្រូវធ្វើនឹងមានប្រសិទ្ធិភាពយ៉ាងណា បើសិនជាគាត់ត្រូវរង់ចាំមួយឆ្នាំសិនទើបអាចប្រាប់រឿងគាត់បាន?

**៤. ទៅដើម្បី "អ្នកយាមទ្វារ** (អ្នកមានកិត្តិយសក្នុងសង្គមដែលគាំទ្រដំនឹងល្អ)"

គ្រប់ទាំងក្រុមមនុស្សរួមទាំងអ្នកខ្លះដែលជះឥទ្ធិពលជាងអ្នកឯទៀត។ នៅពេលដែលការផ្លាស់ប្រែកើតឡើងក្នុងក្រុមមួយ ជាធម្មតាអ្នកទាំងនេះហើយដែលជាអ្នកចាប់ផ្តើមអោយមានការផ្លាស់ប្រែ រឺយ៉ាងហោចណាស់ក៏បណ្តោយអោយវាកើតឡើងបានដែរ។ នៅពេលដែល "អ្នកមានឥទ្ធិពល" ទាំងនេះត្រូវបាននាំមកព្រះគ្រីស្ទដោយជោគជ័យហើយ នោះអ្នកឯទៀតនឹងមកតាមក្រោយ។ យើងហៅអ្នកទាំងនេះថា "អ្នកយាមទ្វារ" ។ ដោយព្រោះតែការជះឥទ្ធិពលរបស់ពួកគេទៅលើក្រុមហើយដោយសារតែពួកគេហើយគឺជាអ្នកដែលអាចបើកផ្លូវអោយយើងចូលទៅយ៉ាងងាយស្រួលដល់ទាំងក្រុមតែម្តង។

តើនណាទៅជាអ្នកយាមទ្វារ? ជាអ្នកដែល:

- មានកេរ្តិ៍ឈ្មោះក្នុងចំនោមដៃគូរបស់គាត់។
- បើកអោយមានទំនាក់ទំនងជាមិត្តសំលាញ់ជាមួយអ្នក។
- បើកចិត្តទទួលដំនឹងល្អ។

លោកសាវ័កប៉ូលដែលជាអ្នកបណ្តុះក្រុមជំនុំដ៏ចំណានបានយល់យ៉ាងច្បាស់ពីរឿងនេះ ។ លោកមានសង្ឃឹមយ៉ាងជាក់ក្នុងការយកជោគជ័យលើមនុស្សដែលមានឥទ្ធិពល ។ យល់ដឹងពីឥទ្ធិពលដ៏ខ្លាំងខ្លាដែលមហាក្សត្រមាន (សុភាសិត ១៦: ១៥, ១៩:១២) លោកបានបោះគោលដៅទៅរកពួកគេយ៉ាងច្បាស់ (កិច្ចការ ៩:១៥)! លោកបានប្រកាសដំនឹងល្អដល់លោក ភេលីចដែលជាចៅហ្វាយខេត្ត លោកភេស្ទុស និងព្រះរាជាអ័គ្រីប៉ា (កិច្ចការ ២៣-២៦) ។ យុទ្ធសាស្ត្របណ្តុះក្រុមជំនុំយ៉ាងសាមញ្ញរបស់លោកប៉ូលត្រូវបានបង្រៀនក្នុងក្រុមជំនុំ ហើយនិងនៅក្នុងផ្ទះនៃ "អ្នកយាមទ្វារ" ។ ឧទាហរណ៏ នៅក្នុងក្រុងភីលីពអ្នកយាមទ្វារ គឺលីឌា (កិច្ចការ ១៦:១១-១៥) នៅឯក្រុងថែស្សាឡូនីចគឺជាយ៉ាសុន (កិច្ចការ ១៧:១-៩) និងនៅក្រុងកូរិនថូស គឺមាន ទីតុស យូស្ទុស (កិច្ចការ ១៨:៧) ។ នៅពេលដែលលោកប៉ូលនាំនណាម្នាក់មកឯព្រះគ្រីស្ទ ជាញយដងអ្នកឯទៀតនឹងមកតាមក្រោយដែរ ។

ឧទាហរណ៏ផ្សេងទៀតអំពី "អ្នកយាមទ្វារ"

- អ្នកយាមគុកក្រុងភីលីព (កិច្ចការ ១៦:៣២-៣៤) ។
- លោកគ្រីសប៉ុស (កិច្ចការ ១៨:៨) ។
- លោកស្ទេផានាស (១កូរិនថូស ១៦:១៥-១៦) ។




### ៥. ស្វែងរក "ស្ថានភាពដូចគ្នា"

ជួនកាលយុទ្ធសាស្ត្រ "ស្ថានភាពដូចគ្នា" គឺជាអ្វីដែលយើងត្រូវការដើម្បីចាប់ផ្តើមទំនាក់ទំនងនិងនាំមនុស្សថ្វាយព្រះគ្រីស្ទ ។ តាមរយះ " ស្ថានភាពដូចគ្នា " គឺយើងចង់បានន័យថា ជាសកម្មភាពសាមញ្ញៗទាំងឡាយណាដែលមានលក្ខណៈដូចគ្នារវាងអ្នកជឿនិងអ្នកមិនជឿ ។ ស្ថានភាពដូចគ្នា អាចត្រូវបានគេប្រើក្នុងគោលបំណងអភិវឌ្ឍនូវការប្រាស្រ័យទាក់ទងគ្នា និងភ្ជាប់ទំនាក់ទំនងនូវដំនឹងល្អ ។

ចូរចំណាយពេលបីបួននាទី ដើម្បីសរសេរអំពីសកម្មភាពនៃស្ថានភាពដូចគ្នាមួយចំនួនដែលទាក់ទងទៅនឹងឆាកជីវិត

ជាគ្រិស្ទានរបស់អ្នក។ ចូរសរសេរនូវសកម្មភាពទាំងនេះ នៅក្នុងចន្លោះដែលបានផ្តល់អោយ នៅពីក្រោមអក្សរ "A" នៅក្នុងដ្យាក្រាម នៃ"ស្ថានភាពដូចគ្នា" ។ ជាបន្ទាប់ ចូរសរសេរសកម្មភាពពិតប្រាកដក្នុងថ្ងៃធម្មតាដែលអ្នកមិនអាចធ្វើបានក្នុងភាពជា គ្រិស្ទាន ប៉ុន្តែវាសាមញ្ញសំរាប់ក្រុមមនុស្សមិនទាន់បានសង្គ្រោះនៅឡើងដែលអ្នកកំពុងដាក់គោលដៅ។ ចូរសរសេរចំលើយទាំងនេះទៅក្នុងរង្វង់ "C"ដែលបង្ហាញស្រាប់។ ជាចុងក្រោយ នៅក្នុងផ្នែក "B" ចូរសរសេរនូវសកម្មភាពដែលអ្នកយល់ថាគឺអាចទទួលយកបានសំរាប់អ្នកនិងសំរាប់មនុស្សមិនទាន់បានជឿដែលនៅជុំវិញអ្នកផងដែរ។




**៦. ពិចារណាពីការរាំងស្ទះនៃវប្បធម៌**

មនុស្សកំរនឹងអាចឆ្លងកាត់ការរារាំងនៃវប្បធម៌ណាស់។ មនុស្សអាចធ្វើការសំរេចចិត្តដើរតាមព្រះយេស៊ូគ្រិស្ទ ប៉ុន្តែភាគច្រើន គេពិបាកនឹងចូលរួមក្នុងក្រុមជំនុំដែលគេត្រូវដើរឆ្លងស្ពាននៃវប្បធម៌។ ការនេះបង្ហាញនូវភាពរាំងស្ទះពីវប្បធម៌សង្គម។ ពួកគេចូលចិត្តរស់នៅជាមួយមនុស្សដែលមានស្ថានភាពដូចគ្នាដូចជាក្នុងសង្គម ជនជាតិ និង ក្នុងសេដ្ឋកិច្ច។

ក្នុងការបង្កើតក្រុមជំនុំដែលមានប្រសិទ្ធិភាពមួយ ចំពោះអ្នកជឿថ្មីអាចមានការស្រុះស្រួលគ្នាជាង បើសិនជាមិនតំរូវអោយពួកគេឆ្លងកាត់ការរាំងស្ទះដូចខាងលើនេះទេ។ ប៉ុន្តែជាញឹកញយ ក្រុមជំនុំចាស់ៗដែលបានកើតឡើងចង់តែបង្ហាញពីវប្បធម៌ ចំរុះអន្តរជាតិដែលគេមិនស្គាល់ហើយមិនងាយស្រួលនឹងទទួល។ លោកប៉ូលមានបំណងសំរបសំរួលវប្បធម៌របស់គាត់ដើម្បីកាត់បន្ថយ ឧបសគ្គដែលឈរនៅចន្លោះលោកនិងមនុស្សដែលលោកត្រូវខិតខំឈោងចាប់ (១កូរិនថូស ៩)។ ការបណ្តុះក្រុមជំនុំគឺជាវិធី ដែលមានប្រសិទ្ធភាពមួយដើម្បីទាញយកផលប្រយោជន៍ពីគោលការណ៍ដូចគ្នានេះ។ ក្រុមជំនុំថ្មីគឺប្រៀបបានទៅនឹងថង់ស្បែកស្រាថ្មីដែលក្រុមជំនុំនេះអាចមានទំរង់ដូចទៅនឹងវប្បធម៌និងសង្គមរបស់អ្នកជឿថ្មីទាំងនេះ។

" ខណៈពេលដែលកំពុងបំរើក្នុងទ័ពអាមេរិក  ខ្ញុំត្រូវបានគេបង្រៀនថា មិនថាកំលាំងទ័ពអាកាស រឺកំលាំងកាំភ្លើងធំ ដែលអ្នកនាំយកទៅដល់គោលដៅខ្លាំងយ៉ាងណានោះទេ  ទីបំផុតទឹកដីគង់តែបានកាន់កាប់ដោយទាហានថ្មើរជើងដែលមានតែកាំភ្លើងដៃប៉ុណ្ណោះ" ។  ការនេះក៏ពិតផងដែលខាងផ្នែកឯវិញ្ញាណ ។ នៅចុងបំផុត មិនថា កំលាំងផ្សាយដំនឹងល្អ ការប្រកាសតាមវិទ្យុ ការចែកចាយឯកសារដែលអ្នកបានធ្វើប៉ុណ្ណានោះទេ   ប៉ុន្តែជាដំណើរនៃអ្នកបណ្តុះក្រុមជំនុំ ដែលបំពាក់បំប៉នដោយព្រះបន្ទូលនិងដំនឹងល្អព្រមទាំង ផ្តល់កំលាំងដោយការអធិដ្ឋាន  គឺអ្នកទាំងនេះហើយដែលយកជ័យជំនះ និងនាំមនុស្សក្នុងភូមិព្រមអ្នកជិតខាង ថ្វាយដល់ព្រះយេស៊ូគ្រីស្ទដោយបង្កើតអោយមានការអធិប្បាយដំនឹងល្អ និងការបង្កើតក្រុមជំនុំបន្តទៀត"

លោក រិច កូរ៉ែល  Rich Correll  ជាអ្នកបណ្តុះបណ្តាលក្រុមជំនុំអន្តរជាតិ

# ១០

# ការបណ្តុះបណ្តាល



គឺជាផែនការរបស់ព្រះដែលទ្រង់សាងសង់ក្រុមជំនុំឡើងតាមរយះអ្នកដឹកនាំដែលធ្វើការហ្វឹកហ្វឺនដល់សមាជិក(អេភេសូ ៤:១១-១៣)។ ការបណ្តុះបណ្តាលច្រើនក៏រិតដែលមានប្រយោជន៏គឺជាកត្តាសំខាន់មួយចំពោះចលនានៃ **កកគ**។ ការហ្វឹកហ្វឺនអ្នកផ្សាយដំនឹងល្អ អ្នកដឹកនាំក្រុមកោសិកា អ្នកបណ្តុះក្រុមជំនុំ និងគ្រូគង្វាលក្នុងរបៀបនៃការធ្វើ ពហុគុណ អាចបង្កើនអោយមានភាពរឹងមាំនិងការរីកចំរើនដល់ក្រុមជំនុំ។ នៅពេលដែលមនុស្សប្រុសស្រីធម្មតាទទួលនូវជំនាញជាមូលដ្ឋានដែលមានសារៈប្រយោជន៏ទៅប្រើប្រាសអំណោយទានរបស់គេ នោះចូរប្រុងប្រយ័ត្ន!

បើសិនជាអ្នកចង់អោយការបណ្តុះក្រុមជំនុំមានចលនា អ្នកត្រូវតែបណ្តុះបណ្តាលរាស្ត្ររបស់ផងព្រះ។ គ្រប់ទាំងក្រុមជំនុំគួរតែជាមជ្ឈមណ្ឌល់បណ្តុះបណ្តាល ហើយគ្រប់ទាំងគ្រីស្ទានដែលស្ថិតក្នុងព័ន្ធកិច្ចនិមួយៗគួរតែមានចំនែកក្នុងការបណ្តុះបណ្តាលអ្នកដទៃអោយធ្វើព័ន្ធកិច្ច។ ប្រជារាស្ត្ររបស់ព្រះទាំងអស់ត្រូវតែទទួលបាននូវការលើកទឹកចិត្ត ការហ្វឹកហ្វឺននិងការបង្រួបបង្រួម។ គឺវាសាមញ្ញបែបហ្នឹងឯង!

**ការបណ្តុះបណ្តាលផ្តោតទៅលើជំនាញនៃការធ្វើព័ន្ធកិច្ច**

មនុស្សជាច្រើនបានយល់ច្រលំអំពី ការបណ្តុះបណ្តាលជាមួយ ការបង្រៀន និងការអធិប្បាយ។ យើងត្រូវតែធ្វើទាំង៣នេះក្នុងព័ន្ធកិច្ច តែយើងគួរតែដឹងយល់ពីភាពខុសប្លែកគ្នា។

❁ ការអធិប្បាយៈ ប្រកាសប្រាប់, ថ្លែងប្រាប់ រឺ នាំពាក្យពីសេចក្តីពិតដែលធ្វើអោយអ្នកស្តាប់ផុសចេញជាការប្តេជ្ញាចិត្តក្នុងគំនិតដើម្បីមានការទទួលខុសត្រូវនិងធ្វើការសំរេចចិត្ត។

❁ ការបង្រៀនៈ ការផ្តល់, ការផ្ទេរពត៌មាន រឺសេចក្តីពិត ដើម្បីអោយអ្នកស្តាប់យល់ពីការពិតក្នុងរបៀបនៃការគិតផ្ទាល់ខ្លួនគេ។

❁ ការបណ្តុះបណ្តាលៈ ហ្វឹកហ្វឺន អភិវឌ្ឍជំនាញ តាមវិធីដែលមានប្រយោជន៏ ដើម្បីអោយការប្រព្រឹត្តិ និងសកម្មភាពនៃអ្នកហ្វឹកហាត់ត្រូវបានផ្លាស់ប្រែ ដែលអាចសំរេចការងារពិតប្រាកដណាមួយ។

ក្រុមជំនុំជាច្រើនអធិប្បាយដោយជំនឿ ហើយបង្រៀនដោយត្រឹមត្រូវ ប៉ុន្តែធ្លាក់ចុះខាងការបណ្តុះបណ្តាលប្រជា

វាស្រ្តរបស់ផងព្រះដើម្បីធ្វើព័ន្ធកិច្ច ។ ការបណ្តុះបណ្តាលជាដំនើរការដ៏រស់រវើកមួយហើយវិធីដ៏ល្អបំផុតក្នុងការបណ្តុះបណ្តាលអ្នកដ៏ទៃគឺបញ្ចូលគេអោយទទួលខុសត្រូវលើព័ន្ធកិច្ច ។ពួកគេនឹងរៀនបានយ៉ាងច្រើន ពីកិច្ចការដែលគេធ្វើ ។

**ខាងក្រោមនេះជាដំនើរការនៃជំហានទាំង៥ដែលជួយអ្នកអោយអភិវឌ្ឍជំនាញពិតប្រាកដមួយ**

**ជំហាន១:** "ខ្ញុំធ្វើ" ធ្វើព័ន្ធកិច្ចជាគំរូដល់អ្នកហ្វឹកហាត់មុនពេលដែលត្រូវការ ។ ឧទាហរណ៍ផ្ទាល់របស់អ្នកជាចំនុចផ្តើមនៃការបណ្តុះបណ្តាល ។ ជាធម្មតាការបណ្តុះបណ្តាលត្រូវធ្លាក់ចុះដោយសារតែខ្វះការធ្វើជាគំរូអំពីជំនាញនោះ ។

**ជំហាន២:** " ខ្ញុំធ្វើ, អ្នកមើល" ខណៈពេលដែលអ្នលហ្វឹកហាត់ "មើល" ក្នុងជំហាន១គឺមិនសូវមានសកម្មភាពទេ ជាសកម្មភាពតែម្ខាង ។ តែក្នុងជំហាននេះវិញ យើងមានភាពរស់រវើក ជាសកម្មភាពអន្តរកម្មទាំងសងខាងរវាអ្នកដឹកនាំនិង អ្នកហ្វឹកហាត់ ។ អ្នកហ្វឹកហាត់ដឹងថា គាត់កំពុងតែត្រូវបានគេបណ្តុះបណ្តាលហើយកំពុងតែ ក្រេបជញ្ជក់យកគ្រប់អ្វី១ ដែលគាត់អាចរៀនបានតាមការសង្កេតមើលព័ន្ធកិច្ចរបស់អ្នក ។ ការពន្យល់ពីសកម្មភាពរបស់អ្នកគឺមានសារៈសំខាន់ណាស់ ។ ប្រាប់ដល់អ្នកហ្វឹកហាត់នូវកិច្ចការដែលអ្នកធ្វើហើយហេតុអ្វីបានជាអ្នកធ្វើវាតាមរបៀបនេះ ។

**ជំហាន៣:** "យើងធ្វើជាមួយគ្នា" ជំហាននេះប្រៀបដូចជាកូនក្មេងកំពុងតែរៀនជិះកង់ដោយមានឪពុកម្តាយចាំជួយទប់ពីក្រោយពេលដែលចាំបាច់ ។ វត្តមានរបស់អ្នកអាចធ្វើអោយអ្នកហ្វឹកហាត់មានទំនុកចិត្ត ហើយអ្នកអាចជួយគេបើសិនជាមានបញ្ហា តែគាត់ក៏ត្រូវតែធ្វើការសាកល្បងនូវកិច្ចការដែលគាត់រៀនពីអ្នកដែរ ។

**ជំហាន៤:** "អ្នកធ្វើ, ខ្ញុំមើល" សង្កេតមើលអ្នកហ្វឹកហាត់ដោយមិនចាំបាច់ជ្រៀតជ្រែក ។ បណ្តោយអោយគាត់ធ្វើរហូតបានជោគជ័យរឺបរាជ័យ បន្ទាប់ពីសកម្មភាពរួចមកជាសំងាត់សូមពន្យល់ពីភាពខ្លាំងនិងលក្ខណៈខ្វះខាតដោយត្រង់១តាមការ ដែលអ្នកបានសង្កេត ។ វាជាប្រការសំខាន់ដែលយើងពន្យល់ប្រាប់គេទាំងផលវិជ្ជមាននិងផលអវិជ្ជមាន ប៉ុន្តែពេលណាអាចទៅរួចសង្កត់ធ្ងន់ទៅលើផលវិជ្ជមាន ។

**ជំហាន៥:** "អ្នកធ្វើ" នៅពេលណាដែលអ្នកគិតថាអ្នកដឹកនាំថ្មីបានរួចរាល់ហើយ ចូរផ្ទេរកិច្ចការអោយគាត់ទាំងស្រុងតែម្តង ។ តែកុំរហ័សពេក ប៉ុន្តែជាធម្មតាបែរជាចាំយូរពេកទៅវិញ ហើយធ្វើអោយហ្វឹកហាត់ទៅជា ខ្សោយដោយយើងនៅតែបន្តវត្តមាននៅទីនោះ ។ លើកទឹកចិត្តដល់ដៃគូរការងារទាំងនេះអោយចាប់ផ្តើមបណ្តុះបណ្តាលអ្នកផ្សេងទៀតក្នុងជំនាញព័ន្ធកិច្ចផ្សេង១ ។

## ការបណ្តុះបណ្តាលគួរតែមានការបង្កើតឡើងបន្ត

ចលនានៃការបណ្តុះក្រុមជំនុំតំរូវអោយមានវិធីសាស្រ្តនិងទ្រឹស្តីបណ្តុះបណ្តាលដែលអាចយកទៅបង្រៀនបន្តដល់អ្នកដទៃទៀត ។ លោកសាវ៏កប៉ូលសង្ឃឹមថា ការបណ្តុះបណ្តាល/ការហ្វឹកហ្វឺនរបស់លោកចំពោះធីម៉ូថេនឹងបន្តរហូតដល់៤ជំនាន់ ។ គឺចាប់ផ្តើមជាមួយនឹងសាវ៏កប៉ូលដែលនៅតែបន្តការបង្រៀនចេញពីចិត្តរបស់គាត់ (២ធីម៉ូថេ ២: ២) ។ លោក

ធីម៉ូថេក៏ចាប់បង្រៀនដល់មនុស្សដែល "អាចបង្រៀនអ្នកដទៃទៀតបាន" ។ គំរូទាំង៤តំនននេះគឺជារបៀបនៃយុទ្ធសាស្ត្រមួយ ដើម្បីធ្វើគំរោងការបណ្តុះបណ្តាល ។ តម្រូវការដ៏សាមញ្ញនេះគឺថាអ្នកដទៃអាចបន្តអោយគ្នា ដោយមិនបាច់ប្រើសម្ភារៈ ថ្លៃៗ ចំនេះដឹងខ្ពង់ខ្ពស់ រឺក៏ការអប់រំជាផ្លូវការទេ ។

គោលការណ៏នៃការធ្វើពហុគុណនេះអាចប្រើទៅលើជីវិតនៃក្រុមជំនុំគ្រប់កំរិត ។ អ្នកដឹកនាំក្រុមតូចបណ្តុះបណ្តាល ដល់កូនក្រុមអោយដឹកនាំក្រុមថ្មី ។ អ្នកបណ្តុះក្រុមជំនុំធ្វើការកត់សំគាល់ និងថែទាំគាំទ្រជំនាញនៃការធ្វើព័ន្ធកិច្ចរបស់អ្នកជឿ ថ្មីដែលទទួលការបង្រៀនបន្ទាប់ទៀតពីការដឹកនាំក្នុងក្រុមជំនុំ ។ គ្រូគង្វាលបណ្តុះបណ្តាលដល់សមាជិកអោយក្លាយជាគ្រូ គង្វាលនៃព័ន្ធកិច្ចថ្មី រឺក៏សាខាក្រុមជំនុំ ។




២ធីម៉ូថេ ២:២

**ធ្វើអោយការបណ្តុះបណ្តាលងាយស្រួលដល់មនុស្សគ្រប់គ្នា**

គឺជាការងាររបស់ក្រុមជំនុំដែលត្រូវបណ្តុះបណ្តាលអ្នកកិច្ចការដើម្បីបំពេញមហាបេសកកម្ម ។ នៅពេលដែលមនុស្ស គេគិតដល់ការបណ្តុះបណ្តាលព័ន្ធកិច្ច ជាធម្មតាពួកគេគិតដល់ សិក្ខាសាលា និងសាលាគម្ពីរ រឺក៏កម្មវិធីដែលមានទីតាំងពិត ប្រាកដ ។ រឿងនេះគួរអោយសោកស្តាយណាស់ ដោយកម្មវិធីបណ្តុះបណ្តាលខ្លះៗដែលមានប្រសិទ្ធិភាពក្នុងពិភពលោកភាគ ច្រើន មិនមានទីតាំងច្បាស់លាស់ និងយកក្រុមជំនុំជាមូលដ្ឋាន ។ ចូរគិតថាបើសិនជាអ្នកធ្វើកិច្ចកាក្រុមជំនុំ ចេញទៅទទួល ការបណ្តុះបណ្តាលនៅសាលាដ៏ឆ្ងាយមួយ នោះវាអាចបង្អាក់ចលនាបណ្តុះក្រុមជំនុំបាន ។ ម៉្យាងវិញទៀត នៅពេលដែលក្រុម ជំនុំតំបន់មានការទទួលខុសត្រូវខ្លាំង ទៅលើការបណ្តុះបណ្តាលអ្នកធ្វើការងារ ពេលនោះការបណ្តុះបណ្តាលនិងមានឡើង សំរាប់មនុស្សជាច្រើន ។

**ការបណ្តុះបណ្តាលរួមបញ្ចូលទាំងការប្រៀនប្រដៅ**

ជាមូលដ្ឋានការប្រៀនប្រដៅគឺជាទំនាក់ទំនងដែលមានគោលបំនងច្បាស់លាស់មួយដែលមនុស្សណាម្នាក់ចេះរឺក៏មាន របស់អ្វីមួយផ្តល់ទៅអោយមនុស្សម្នាក់ទៀតក្នុងពេលបង្រៀន ព្រមទាំងផ្តល់លទ្ធផលក្នុងការលូតលាស់ និងការអភិវឌ្ឍន៏ ។

ការបណ្ដុះបណ្ដាលគួរតែធ្វើឡើងដោយមានទំនាក់ទំនងក្នុងរយះពេលយូររវាងអ្នកប្រៀនប្រដៅ និងអ្នកហ្វឹកហាត់។ អ្នកប្រៀនប្រដៅសង្កេតមើលក្នុងកិច្ចការរបស់អ្នកហ្វឹកហាត់ ទាំងផ្ដល់ការលើកទឹកចិត្តនិងអធិដ្ឋានអោយព្រមទាំង វាយតំលៃលទ្ធផលដែលទទួលបានដោយផ្ដល់ជាដំបូន្មាននិងការកែលំអ។ អ្នកប្រៀនប្រដៅមិនមែនជាអ្នកប្រាជ្ញមានកិត្តិយសដែលចាំតែផ្ដល់អោយនូវការបង្រៀនរឹនិពន្ធសៀវភៅនោះទេ។ ផ្ទុយទៅវិញគាត់ជាមិត្តសំលាញម្នាក់ ដែលទៅសួរសុខទុក្ខដល់អ្នកហ្វឹកហាត់ក្នុងកិច្ចការងារដើម្បីសង្កេតមើលសកម្មភាពរបស់ពួកគេ អធិដ្ឋានអោយគេ លើកទឹកចិត្តគេ ព្រមទាំងជួយដល់គេទៀតផង។ ការស្ទាបស្ទង់របស់អ្នកបណ្ដុះក្រុមជំនុំដែលមានចំនែកក្នុងកម្មវិធី បណ្ដុះ បណ្ដាលជាផ្លូវការបង្ហាញថា ចេញពីអត្ថប្រយោជន៍ទាំងអស់នៃកម្មវិធីបណ្ដុះបណ្ដាល ការសាកសួរសុខទុក្ខ (ការប្រៀនប្រដៅ) ត្រូវបានផ្ដល់តំលៃអោយខ្ពស់ជាងគេបំផុតក្នុងគ្រប់សកម្មភាពទាំងអស់ ហើយក៏ផ្ដល់អត្ថប្រយោជន៍ជាងការបង្រៀននិងជំនួយខាងផ្នែកថវិការ។

**ការប្រៀនប្រដៅរួមបញ្ចូលទាំង:**

- មានទំនាក់ទំនងជាមួយមនុស្សជាជាងគ្រប់គ្រងគេ។
- ហ្វឹកហ្វឺនមនុស្សជាជាងត្រួតពិនិត្យលើគេ។
- ផ្ដល់អោយមនុស្សជាជាងទាញយកតំរូវការពីគេ។
- លើកទឹកចិត្តដល់មនុស្សជាជាង រិះគុណគេ។
- ដាស់តឿនមនុស្សជាជាងបង្ខំគេ
- បញ្ចុះបញ្ចូលដល់មនុស្សជាជាងបញ្ជាគេ។
- បណ្ដុះបណ្ដាលមនុស្សជាជាងបង្រៀនទ្រឹស្ដីដល់គេ។

> ការស្ទាបស្ទង់របស់អ្នកបណ្ដុះក្រុមជំនុំដែលមានចំនែកក្នុងកម្មវិធី បណ្ដុះ បណ្ដាលជាផ្លូវការបង្ហាញថា ចេញពីអត្ថប្រយោជន៍ ទាំងអស់នៃកម្មវិធីបណ្ដុះបណ្ដាល ការសាកសួរសុខទុក្ខ (ការប្រៀនប្រដៅ) ត្រូវបានផ្ដល់តំលៃអោយខ្ពស់ជាងគេបំផុត ក្នុងគ្រប់សកម្មភាពទាំងអស់ ហើយក៏ផ្ដល់អត្ថប្រយោជន៍ជាងការបង្រៀននិងជំនួយខាងផ្នែកថវិការ។

**ការបណ្ដុះបណ្ដាលអ្នកបណ្ដុះក្រុមជំនុំ**



ដើម្បីអោយការបណ្ដុះក្រុមជំនុំគ្រប់ទិសទីកើតឡើង ក្រុមជំនុំថ្មីៗត្រូវតែបណ្ដុះអោយមានឡើងគ្រប់ទីកន្លែង! ត្រូវតែមានអ្នកបណ្ដុះក្រុមជំនុំទាំងអស់នោះ ដូច្នេះការបណ្ដុះបណ្ដាលអ្នកបណ្ដុះក្រុមជំនុំត្រូវតែជាកត្តាសំខាន់។ ប៉ុន្តែការបណ្ដុះក្រុមជំនុំមិនមែន "កើតឡើងដោយឯងៗទេ" វាត្រូវការ ការងារនិងការអធិដ្ឋានដែលហ្មត់ចត់ ដើម្បីជំរុញ ទឹកចិត្តអោយក្រុមជំនុំតាម តំបន់ចាត់មនុស្សអោយទៅធ្វើការបណ្ដុះបណ្ដាល រៀបចំសម្ភារៈបណ្ដុះបណ្ដាលហ្វឹកហ្វឺន និង ផ្ដល់ដំបូន្មាន ដល់អ្នកបណ្ដុះក្រុមជំនុំថ្មី។ នៅពេលដែលអ្នកបណ្ដុះក្រុមជំនុំ ចូលទៅក្នុងទីលានចំរូត ជាធម្មតាពួក គេត្រួសត្រាយប្រឈមមុខលើទឹកដី ខ្មាំងសត្រូវ ដើម្បីព្រលឹងមនុស្ស (២កូរិនថូស ៤:៤, កូលុស ១:១៣)។ អ្នកបណ្ដុះក្រុមជំនុំត្រូវធ្វើជាអ្នកផ្សាយដំនឹងល្អដែលមានសមត្ថភាព ជាអ្នកដឹកនាំក្រុមតូចដ៏ល្អក៏ដូចជាជំនាញអប់រំដល់សិស្សទាំងឡាយដែលទើបនឹងជឿថ្មី។ លើសពីនេះ ទៀតសង្គ្រាមខាងជំវិញ្ញាណ ដែលជាផ្នែកមួយដែលជៀសមិនរួចក្នុងបទ ពិសោធន៍នៃការ

បណ្តុះក្រុមជំនុំតំរូវអោយមាន ការរៀបចំយ៉ាងត្រឹមត្រូវខាងឯវិញ្ញាណដើម្បីអោយអ្នកបណ្តុះក្រុមជំនុំ ទទួលបានជោគជ័យ ។

មានអ្នកបណ្តុះក្រុមជំនុំជាច្រើនចាប់ផ្តើមព័ន្ធកិច្ចរបស់គេដោយគ្មានជំនាញអស់ទាំងនេះទេ ។ វិធីល្អបំផុតក្នុងការទទួលយកជំនាញនេះគឺតាមរយៈ បទពិសោធន៍ ការព្យាយាម និងកំហុស ព្រមទាំងការបណ្តុះបណ្តាលដោយមានការផ្តល់ដំបូន្មានយ៉ាងហ្មត់ចត់ ។ តាមវិធីនេះអ្នកបណ្តុះក្រុមជំនុំនឹងរៀន អ្វីដែលត្រូវធ្វើ របៀបដែលត្រូវធ្វើ ព្រមទាំងអ្វីដែល ត្រូវបង្រៀនដែលក្រុមជំនុំថ្មីមួយនឹងកើតឡើង ។

**ទ្រង់ទ្រាយនៃការហ្វឹកហ្វឺនអ្នកបណ្តុះក្រុមជំនុំដោយជោគជ័យ**

ការបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំមិនមែនគ្រាន់តែបង្រៀនត្រឹមតែពតិមានប៉ុណ្ណោះទេ តែក៏ត្រូវការជំនាញដែលមានប្រយោជន៍ដែលអាចបង្កើតក្រុមជំនុំថ្មីបាន ។ កម្មវិធីបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំដែលទទួលបានជោគជ័យនោះគឺៈ

**មានការបង្កើតឡើងជាបន្តបន្ទាប់**

ការបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំ ត្រូវតែធ្វើឡើងតាមរបៀបមួយងាយស្រួលក្នុងការបង្កើតឡើងជាបន្តទៀតនៃអ្នកបណ្តុះក្រុមជំនុំជំនានទី២និងទី៣ ។ វិធីសាស្ត្រនៃការបង្រៀននិងសម្ភារៈដែលត្រូវប្រើគួរតែត្រូវបានគេរៀបចំឡើងជាស្រេច ដើម្បីអោយគេទាំងនោះអាចយកទៅធ្វើការបង្រៀនឡើងវិញដល់អ្នកដទៃទៀតតាមទំរង់ដដែល ។ អ្នកបណ្តុះក្រុមជំនុំប្រាថ្នាចង់បង្រៀនអ្នកបណ្តុះក្រុមជំនុំដទៃទៀតក្នុងវិធីដដែល ដែលជារបៀបដែលពួកគេបានរៀន ។

**សមហេតុសមផល**

ការបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំដែលត្រូវស្ថានការ គឺមើលឃើញពីតំរូវការនៃអ្នកហ្វឹកហាត់នៅក្នុងស្ថានភាពរបស់ពួកគេ ។ ការបង្រៀនគួរតែបញ្ជាក់ពីផលវិបាកជាមូលដ្ឋានដូចជា ឧបសគ្គនិងបញ្ហាដែលអ្នកបណ្តុះក្រុមជំនុំនឹងជួបប្រទះ ។

**ពិតជាក់ស្តែង**

ការបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំត្រូវតែអោយមានលក្ខណៈពិតជាក់ស្តែងនិងជំនាញច្បាស់លាស់ដោយស្របទៅតាមតំរូវការនៃជីវភាពពិតៗនៃព័ន្ធកិច្ច ។ ព័ន្ធកិច្ចគឺបង្ហាញពីទីតាំងជាចំបងសំរាប់ការដឹកនាំ មិនមែនការអប់រំទេ ។

**កាតាលិក (ដែលជួយជំរុញអោយមានភាពប្រសើរឡើង)**

កម្មវិធីបណ្តុះបណ្តាលមួយមិនអាចហ្វឹកហ្វឺនអ្នកបណ្តុះក្រុមជំនុំអោយបានពេញលេញនោះទេ ។ ប៉ុន្តែវាអាចផ្តល់អោយនូវនិមិត្ត ធនធាន បង្ហាញពីជោគជ័យ លើកទឹកចិត្តក្នុងកិច្ចសហារបតិបត្តិការណ៍ និងធ្វើអោយមានការចាប់ផ្តើមឡើង ។ នៅថ្ងៃអនាគតការបណ្តុះបណ្តាលផ្សេងទៀតខាងទេវសាស្ត្រវិទ្យា និងស្ថានភាពជាក់ស្តែងនឹងជាតំរូវការដល់អស់អ្នកដែលដឹកនាំក្រុមថ្មី ដែលជាកត្តាខាងក្រៅនៃការបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំដែលមានជំនាញ ។

**លទ្ធផល-បង្ហាញអោយឃើញ**

គ្រប់ការបណ្តុះបណ្តាលទាំងអស់មានគោលដៅនៃការប្តូរសកម្មភាពនៅក្នុងជីវិតនៃអ្នកហ្វឹកហាត់ ។ ចំនេះដឹងអំពី

ការបណ្ដុះក្រុមជំនុំមិនមែនជាគោលដៅទេ ទោះជាយ៉ាងណាក៏ដោយ ចំនេះដឹងលើការអភិវឌ្ឍន៏ដ៏ល្អមួយនៃគោលកាណ៏ទាំងស្រុងអំពីរបៀបនៃការបណ្ដុះក្រុមជំនុំនៅតែមានតំរូវការ ។ ជាងនេះទៀត ការផ្លាស់ប្ដូក្នុងការយល់ឃើញ និងសកម្មភាពព័ន្ធកិច្ច គឺអាចរកឃើញបាន ។ អ្នកហ្វឹកហាត់ត្រូវតែបានគេជួយអោយធ្វើការតាមរយៈដំនើរការនៃការស្រាវជ្រាវ ការផ្ដើមគំនិត និងការអនុវត្តន៏ដោយមានប្រសិទ្ធិភាព ចំពោះអត្ថប្រយោជន៏ ការយល់ឃើញ សកម្មភាពនិងជំនឿរបស់គាត់ ។

ខុសគ្នាពីសិក្ខាសាលា និងកម្មវិធីសិក្សាសាលាព្រះគម្ពីរភាគច្រើន ដោយការបណ្ដុះបណ្ដាលអ្នកបណ្ដុះក្រុមជំនុំផ្ដោតទៅលើកិច្ចការនៅក្នុងទីវាលជាជាង ។ ជោគជ័យដែលទទួលបានមិនអាស្រ័យទៅលើអ្វីដែលសិស្សបានរៀននោះទេ តែដោយសារតែអ្វីដែលសិស្សបានបន្ដចែកចាយ ។ ដោយហេតុនៃការបណ្ដុះបណ្ដាលនេះ ជាលទ្ធផល តើមានក្រុមជំនុំថ្មីកើតឡើងដែររឺទេ? តើក្នុងក្រុមជនុំមានសមាជិកចូលរួមថ្វាយបង្គំប៉ុន្មាននាក់ហើយ?

◆◆◆◆

# ១១

# ចលនាប្រមូលផ្តុំ

**ក្រុមជំនុំទាំងអស់នាំដំនឹងល្អដល់ពិភពលោកទាំងមូល!**

សំរែកក្នុងពេលសង្គ្រាមគឺទាមទារអោយប្រមូលផ្តុំ។ ពាក្យថា "ប្រមូលផ្តុំ" ជាធម្មតាមានន័យថា កែនមនុស្សអោយត្រៀមខ្លួននិងចូលរួមនៅកន្លែងដែលគេអាចជួយដោះស្រាយបញ្ហាណាមួយយ៉ាងខ្លាំងខ្លា។

> នៅពេលដែលរូបកាយទាំងមូលរបស់ព្រះគ្រីស្ទផ្តុំគ្នាជាស្រេចដើម្បីធ្វើទីបន្ទាល់សំរាប់ព្រះគ្រីស្ទ នោះព្រះនឹងធ្វើអោយក្រុមជំនុំចំរើនឡើង ឈោះទៅរកគោលដៅនៃការបង្កើតសិស្ស។

នៅពេលដែលក្រុមជំនុំខិតខំក្នុងការលូតលាស់ គោលដៅអស់កល្បជានិច្ចនៃមនុស្សរាប់លាននាក់នេះហើយ ដែលជាមូលហេតុ។ អ្នកបង្រួបបង្រួមប្រមើលឃើញថាការរីកចំរើនរបស់ក្រុមជំនុំដែលពិតប្រាកដនោះ ត្រូវប្រឈមមុខនឹងចំបាំងខាងវិញ្ញាណ។ ទាហានដែលមានភាពឧស្សាហ៍ព្យាយាមគេស្រែកឡើងដើម្បីអោយមានការប្រមូលផ្តុំ។

**ហេតុអ្វីបានជាអ្នកជឿត្រូវតែរួបរួមគ្នា?**

- ☐ ព្រះយេស៊ូអធិដ្ឋានថា អ្នកដែលដើរតាមទ្រង់ត្រូវតែរួបរួមគ្នា (យ៉ូហាន ១៧)។
- ☐ ទ្រង់បានបង្កើតក្រុមជំនុំឡើងអោយ ធ្វើកិច្ចការរួមគ្នាជារូបកាយតែមួយ (១កូរិនថូស ១២, រ៉ូម ១២)។

ជាធម្មតាចលនានៃការប្រមូលផ្តុំមិនមែនគ្រាន់តែជាគំនិតល្អមួយនោះទេ លើសនេះទៅទៀតវាសំខាន់ណាស់។ គ្មានផ្នែកណាមួយនៃរូបរាងកាយអាចធ្វើសង្គ្រាមខាងវិញ្ញាណតែឯកឯងនោះទេ។ ក្រុមជំនុំធ្វើការងារបានប្រសើរខ្លាំងណាស់នៅពេលដែលគ្រប់ផ្នែកត្រូវបានប្រមូលផ្តុំឆ្ពោះទៅកាន់ការសំរេចគោលដៅ។ បើមិនមានលក្ខណៈនៃចលនាប្រមូលផ្តុំបែបនេះទេ ក្រុមជំនុំច្បាំងចេញទៅពីចំនុចមួយដែលមានភាពកំសោយ ដោយមិនបានប្រើអោយអស់គ្រប់ទាំងសមាជិកដូចដែលព្រះសព្វព្រះហឫទ័យនោះទេ។

**ចលនាប្រមូលផ្តុំផ្តោតអារម្មណ៏ទៅលើមនុស្សនិងធនធាន**

មនុស្សត្រូវតែមាននិមិត្តរួមតែមួយ។ តើអោយមនុស្សធ្វើការជាមួយគ្នាដូចម្តេចកើតបើគេមិនបានព្យាយាមសំរេចនូវគោលដៅតែមួយស្របគ្នាផង? បើគ្មាននិមិត្ត តើអោយមនុស្សរួបរួមគ្នាដើម្បីអ្វីទៅ? ចលនានៃការប្រមុលផ្តុំ មិនអាចទៅរួចទេបើគ្មាននិមិត្តរួមតែមួយ។ និមិត្តរួមតែមួយធ្វើអោយមានការផ្តោតអារម្មណ៏ ទៅលើចលនាប្រមូលផ្តុំ។ ឯនិមិត្តនេះគឺមកតែពីព្រះប៉ុណ្ណោះ គឺថាចំពោះនិមិត្តមួយមកពីព្រះជាម្ចាស់អាចនាំអោយមនុស្សរួបរួមគ្នាដើម្បីទប់ទល់សង្គ្រាមវិញ្ញាណ។

ការអធិដ្ឋានទទូចសូមអោយដឹងថា "តើព្រះសព្វព្រះហឫទ័យចង់ធ្វើអ្វី?" គឺទំនងជាវិធីដែលអាចជួយដល់យើងយ៉ាងប្រសើរជាងគេក្នុងការបំផុសនិមិត្តឆ្ពោះទៅរកចលនាប្រមូលផ្តុំ ។

មនុស្សត្រូវតែទទួលបាននូវការបណ្តុះបណ្តាល ។ ការបណ្តុះបណ្តាលត្រូវតែធ្វើទៅតាមនិមិត្ត ។ គ្រប់ផ្នែកនៃរូបរាងកាយត្រូវតែដឹងពីតួនាទីរបស់ពួកគេ និងអំណោយទាននិមួយៗដែលបានបង្ហាញអោយឃើញ ។ ក្នុងលក្ខណ:នេះ សមាជិកទាំងអស់នៃរូបរាងកាយត្រូវចូលរួមក្នុងកិច្ចការហើយសំរេចតាមគោលដៅ ។

**ការបំពេញមហាបេសកកម្មនៅក្នុងប្រទេសជាតិមួយគួរតែត្រូវបានគេធ្វើឡើងជាចំបងជាមួយនឹងធនធានព្រមទាំងការផ្តើមគំនិតនៃអ្នកមានជំនឿក្នុងប្រទេសនោះ ។**

មនុស្សត្រូវតែបញ្ចេញអស់ពី សមត្ថភាពនូវធនធានរបស់ខ្លួន ។ នៅពេលដែលគេខ្វះខាតធនធានក្នុងការ ធ្វើកិច្ចការដែលព្រះបានត្រាស់ហៅអោយធ្វើ ពួកគេនឹងគ្មានការរួបរួមទេ ។ ឯធនធាននោះមានដូចជា ថវិការ ឧបករណ៍ ឯកសារសិក្សា ជំនាញ ។ល ។ ដើម្បីអោយចលនានៃ កកគមានការកើតឡើងប្រភេទនៃធនធានបែបនេះហើយដែលគេត្រូវការ ។ ប៉ុន្តែ ការបំពេញមហាបេសកកម្មនៅក្នុងប្រទេសជាតិមួយគួរតែត្រូវបានគេធ្វើឡើងជាចំបងជាមួយនឹងធនធានព្រមទាំងចាប់ផ្តើមជាមួយអ្នកមានជំនឿក្នុងប្រទេសនោះ ។ ការផ្តល់អោយនូវធនធានទាំងនេះ គឺជាមូលដ្ឋានគ្រឹះនៃសេចក្តីពិត ដែលចេញពីបេះដូងនៃប្រជារាស្ត្ររបស់ផងព្រះផ្ទាល់ ធ្វើការបរិចាកយ៉ាងមានតំលៃសំរាប់កិច្ចការដ៏នឹងល្អ ។ ដង្វាយនិងយ័ញ្ញបូជារស់របស់គេគួរតែបានប្រើប្រាសដើម្បីផ្គត់ផ្គង់ដល់កិច្ចការរបស់ពួកគេដែលបំរើព្រះ ។

ដូចព្រះយេស៊ូមានបន្ទូលថា "ពីព្រោះទ្រព្យសម្បត្តិរបស់អ្នកស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ (ម៉ាថាយ៦: ២១) ។ នៅពេលដែលមនុស្សម្នាក់ផ្តល់អោយនូវទ្រព្យសម្បត្តិ និងថវិការរបស់ខ្លួនដើម្បីផលប្រយោជន៏ ណាមួយ ក្នុងចិត្តអ្នកនោះនឹងខិតខំតស៊ូក្នុងភាគហុនរបស់គាត់ ។ បើសិនជាមនុស្សមិនបានផ្តល់ការលះបង់ក្នុងការងារព័ន្ធកិច្ចតំបន់នោះទេ នោះគេក៏គ្មានកំលាំងចិត្តបន្តសំរេចការនោះដែរ ។ ហេតុការមួយដែលកើតឡើងនឹងមានឥទ្ធិពលយ៉ាងខ្លាំងខ្លា គឺនៅពេលដែលមនុស្សគេសំរេចចិត្តថាកម្មវិធីរឺក៏ព័ន្ធកិច្ចមួយ នោះជារបស់ផងគេ ហើយថាវាអាចទទួលបានជោគជ័យ រឺក៏បរាជ័យ អាស្រ័យទៅលើកិច្ចការរបស់ផងព្រះ តាមរយ:ពួកគេផ្ទាល់ ។

ធនធានអាចយកមកពីប្រភពខាងក្រៅ ដូចជា ក្រុមជំនុំ និងភ្នាក់ងារបេសកកម្ម ដើម្បីអោយការងារថ្មីកើតមានឡើង ។ ទោះយ៉ាងនេះក្តី បញ្ហានេះគួរតែជាការលើកលែង ហើយក៏មិនមែនជារបៀបមួយសំរាប់ស្វែងរកធនធាន នោះដែរ ។

**ឧទាហរណ៏ក្នុងព្រះគម្ពីរពីចលនានៃការប្រមូលផ្តុំ**

**ដង្វាយស្ម័គ្រចិត្តសំរាប់រោងឧបោសថ**

ម៉ូសេបានប្រមូលដង្វាយពីជនជាតិអ៊ីស្រាអែល ដើម្បីសាងសង់រោងឧបោសថនៅខណ:ពេលដែលប្រជាជនអ៊ីស្រាអែលមិនមានផ្ទះសំបែងនៅឡើយពេលរស់នៅឯទីរហោស្ថាន (និក្ខមនំ ២៥: ១-៨) ។ ប្រជាជនបានថ្វាយនូវ សត្វពាហន: ទ្រព្យ

សម្បត្តិផ្ទាល់ខ្លួន ហើយសូម្បីតែកំលាំងពលកម្មរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងការត្រាសហៅក្នុងចលនា រួបរួម (និក្ខមនំ ៣៥: ៤-២៩)។ ពួកគេមិនបានទាមទារអោយថ្វាយតែម្តងនោះទេ តែគេថ្វាយដោយស្ម័គ្រចិត្តវិញ។ តាមពិតទៅពួកគេបានថ្វាយលើសពីតំរូវការទៅទៀត ដូច្នោះហើយលោកម៉ូសេបានស្នើអោយបញ្ឈប់នូវការថ្វាយបន្តទៀត (និក្ខមនំ ៣៦: ៤-៧)!

**ការសាងសង់កំផែងទីក្រុងយេរូសាលឹមឡើងវិញ**

បន្ទាប់ពីការនិរទេស នេហេមាបានប្រមូលផ្តុំប្រជាជនយូដា ដើម្បីសាងសង់កំផែងក្រុងយេរូសាលឹមឡើងវិញ។ លោកបានបំផុសនិមិត្ត ប្រមូលធនធានហើយប្រើមនុស្សអោយត្រូវនឹងអំណោយទានរបស់គេ។ គោលដៅ និងនិមិត្តដើម្បីសាងសង់កំផែងទីក្រុងយេរូសាលឹមឡើងវិញរបស់លោកនេហេមា បានមកដល់គាត់ដែលជាលទ្ធផលនៃពតិមាន (ការស្រាវជ្រាវ) បានលឺពស្ថានភាពនៃទីក្រុងយេរូសាលឹម និងតាមរយះការអធិដ្ឋាន (នេហេមា ១: ២-៤)។ ចលនានៃការប្រមូលផ្តុំប្រជាជនយូដាក្នុងទីក្រុងយេរូសាលឹមបានលទ្ធផលជាការរួមកំលាំងសាមគ្គីមួយ ដែលធ្វើអោយលទ្ធផល ទទួលបានកើនលើសទ្វេដង។ កំផែងត្រូវបានសង់រួចរាល់ក្នុងរយះពេល ៥២ថ្ងៃ ពិតជាលឿនអស្ចារ្យខ្លាំងណាស់ ដែលបណ្តាលអាយជាតិសាសន៍ដែលនៅជិតខាងមានការភ័យខ្លាចជាខ្លាំង (នេហេមា ៦: ១៥-១៦)។ នៅពេលដែលប្រជារាស្ត្រ របស់ផងព្រះរួបរួមគ្នា និងសំរេចកិច្ចការ តាមគំរោការណ៏របស់ព្រះជាម្ចាស់នោះព្រះប្រទានពរតាមរបៀបដ៏អស្ចារ្យផ្សេងៗជាច្រើន។

**សកម្មភាពបេសកកម្មរបស់សាវ័កប៉ូល**

សាវ័កប៉ូលបានបង្រួបបង្រួមបណ្តាជន។ គាត់បង្រៀនថា គ្រប់ៗគ្នាមានអំណោយទានខាងឯវិញ្ញាណ (រ៉ូម ១២, ១កូរិនថូស ១២, អេភេសូ ៤) ហើយធ្វើអោយក្រុមជំនុំដឹងពីសក្តានុពលភាព ដែលពួកគេទាំងនោះផ្តើមធ្វើព័ន្ធកិច្ច (១កូរិន-ថូស ៤-៩, រ៉ូម ១៥: ១៤)។ សាវ័កប៉ូលបានបណ្តុះបណ្តាលធីម៉ូថេ ដោយជំរុញទឹកចិត្តគាត់អោយហ្វឹកហាត់ ការប្រើប្រាសអំណោយទានខាងឯវិញ្ញាណយ៉ាងខ្លាំងខ្លា ព្រមទាំងនែនាំគាត់អោយបង្រួបបង្រួមអ្នកដទៃបន្តទៀត (២ធីម៉ូ ថេ ២: ២)។ មិនមែនគ្រាន់តែធីម៉ូថេប៉ុណ្ណោះជាមនុស្សតែម្នាក់គត់ ដែលត្រូវបានបង្រួបបង្រួមដោយសាវ័កប៉ូលនោះទេ។ ដំនើរបេសកកម្មចុងក្រោយរបស់សាវ័កប៉ូល គឺជាដំនើរនៃចលនាបង្រួបបង្រួមការបណ្តុះបណ្តាលសិស្សដូចដែលយើងបាន អានពីមនុស្ស៧នាក់ដែលធ្វើដំនើរជាមួយលោក និងរៀនពីលោក (កិច្ចការ ២០: ៤)។ នៅក្នុងសំបុត្ររបស់សាវ័កប៉ូល លោកបានរៀបរាប់ពីអេប៉ាប្រាស ដេម៉ាស អើយីព ទីតុស ភីបេ និង អ្នកផ្សេងៗទៀត។ នៅក្នុងព្រះគម្ពីររ៉ូម ១៦ លោកប៉ូលបានជំរាបសួរ ដល់មនុស្ស ២៧នាក់ ជាអ្នកដែលគាត់បានជះតទ្ធិពលទៅលើ រឺ ជំរុញទឹកចិត្តតាមរបៀបផ្សេងៗក្នុងព័ន្ធកិច្ច និងផ្តល់អោយនូវភស្តុតាងចំពោះបណ្តាញទំនាក់ទំនងរវាងមនុស្សយ៉ាងច្រើនសន្ធឹកដែលលោកបានបង្រួបបង្រួមនៅពេលលោកធ្វើដំនើរបេសកកម្ម។

លោកប៉ូលបានបង្រួបបង្រួមក្រុមជំនុំជាច្រើនដើម្បីផ្តល់អោយក្រុងជំនុំក្រុងយេរ៉ូសាលឹមនៅពេលដែលគេត្រូវការ .(រ៉ូម ១៥:២៥-២៧, ១កូរិនថូស ១៦:១-២, ២កូរិនថូស ៨:១-៦, ៩:៦-១១)។ លោកប៉ូលបានបង្រៀនអំពីការអោយ ការលើកទឹកចិត្តដល់ក្រុមជំនុំដើម្បីអោយគេជ្រមជ្រែងដល់អស់អ្នកដែលធ្វើព័ន្ធកិច្ចដល់ពួកគេ (១កូរិនថូស ៩:៤-១៤, ១ធីម៉ូថេ ៥:១៨)។ វាគួរអោយចាប់អារម្មណ៏ណាស់ ដែលត្រូវគត់សំគាល់ពីឃ្លាមួយបានពោលជាដដែលៗថា "ព្រះនៃខ្ញុំទ្រង់

នឹងបំពេញគ្រប់ទាំងអស់ដែលអ្នកត្រូវការ" គឺបានរកឃើញក្នុងអត្ថបទរបស់លោកប៉ូលដែលគាត់បានថ្លែងអំណរគុណដល់ ក្រុមជំនុំភីលីពចំពោះការថ្វាយរបស់ពួកគេ (ភីលីព ៤:១៥-២០) ។ ម៉្យាងទៀតអស់អ្នកដែលថ្វាយនោះគេមានអំណរ ក្នុងសេចក្តីសន្យាដ៏អស្ចារ្យមកពីព្រះដែលទ្រង់នឹងប្រទានរង្វាន់ដល់ពួកគេតាមការដែលគេបានធ្វើ ។ ពិតណាស់ដែលព្រះនឹងប្រទានអោយជាបរិបូរណ៏ចំពោះសេចក្តីត្រូវការរបស់យើង បើសិនជាយើងមានសេចក្តីជំនឿក្នុង ការថ្វាយដោយសទ្ធាដល់ទ្រង់ (២កូរិនថូស ៩:៦-១១, លូកា ៦:៣៨) ។

**សេចក្តីបញ្ចប់**

ចលនាប្រមូលផ្តុំគឺជាកិច្ចការខាងឯវិញ្ញាណ ។ ឯចលនានៃការបណ្តុះក្រុមជំនុំគ្រប់ទិសទីនឹងមិនទទួលជោគជ័យទេ បើគ្មានចលនាប្រមូលផ្តុំដោយមានប្រសិទ្ធិភាព ។ ព្រោះវាជួយអោយមានការផ្តោតអារម្មណ៏ និងបញ្ចេញនូវធនធានដែលមានហើយស្រាប់ដើម្បីធ្វើការផ្សាយដំនឹងល្អក្នុងពិភពលោក គឺជាការបង្កើតក្រុមជំនុំថ្មីគ្រប់ទីកន្លែង ។



**បើសិនជារូបកាយរបស់ព្រះគ្រីស្ទមិនបានរួមគ្នាមកតែមួយនោះទេ គឺវាមិនអាចធ្វើសង្គ្រាមអោយអស់ពីកំលាំងឡើយ ។**

# ការបណ្ដុះក្រុមជំនុំគ្រប់ទិសទី
# អាចធ្វើទៅបាន!



# ១២

# ឧទាហរណ៍ជាក់ស្តែងខ្លះៗអំពីការបណ្តុះក្រុមជំនុំគ្រប់ទិសទី

## នៅប្រទេសពីលីពិន

ជូន បាឡាយូ (Jun Balayo ) បានដឹកនាំសកម្មភាពអន្តរនិកាយ នៅក្នុងប្រទេសពីលីពិនដែលនៅតែមានឥទ្ធិពលដល់សព្វថ្ងៃនេះ។ លោក Jun រួមជាមួយអ្នកមានជំនឿដទៃទៀត បានដាក់គោលដៅដ៏វែងឆ្ងាយដែលនឹងមានក្រុមជំនុំថ្មី ៥០,០០០ ទៀតកើតឡើងក្នុងប្រទេសពីលីពិននៅឆ្នាំ២០០៣។ ដូចជាក្រាហ្វិកខាងក្រោមបង្ហាញស្រាប់ ការលូតលាស់នៅនឹង ហើយមិនមានល្បឿនខ្លាំងខ្លាទេនៅពេលដំបូង។ ទោះជាយ៉ាងនេះក្តី កំលាំងដែលបានមកពីលទ្ធផលនៃចំរូតបានដឹកនាំបង្កើនចលនាបានលឿនជាងពេលកំនត់ ដោយសព្វថ្ងៃនេះ ពួកគេស្ថិតនៅលើគោលដៅ!

ក្រុមជំនុំរីកលូតលាស់ក្នុងប្រទេសពីលីពិនចាប់ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ២០០៣



**ប្រទេសរុស្ស៊ី**

អ្នកដឹកនាំខាងនិកាយបាប់ទីស២០០នាក់មកពីឆ្នេរប៉ាស៊ីហ្វិក នៃប្រទេសរុស្ស៊ី បានជួបជុំគ្នានៅ ខាបារូវស្គី (Khaba rovsk) នៅរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ១៩៩៩ដើម្បីបំផុសនិមិត្តនិងបោះគោលដៅបណ្តុះក្រុមជំនុំ។ នៅប៉ែកនេះនៃប្រទេសរុស្ស៊ីមានរួមបញ្ចូលតំបន់ចំនួន៨ ដែលមានប្រជាជនសរុប ជាង៦លាននាក់។ សមាគមនិកាយបាប់ទីសរុស្ស៊ី (RBU) នេះត្រូវបានរៀបចំឡើងយ៉ាងល្អប្រសើរនៅទីនោះ ហើយមានការផ្តោតអារម្មណ៍ទៅលើការបណ្តុះក្រុមជំនុំគ្រប់ទិសទីយ៉ាង ខ្លាំងខ្លា។

សមាគមនិកាយបាប់ទីសរុស្ស៊ី (RBU) )មានក្រុមជំនុំ៩៦រួចស្រេចទៅហើយព្រមទាំងក្រុមតូចៗនៅក្នុងតំបន់ ដែលលើសពី២៧ក្រុមនៅឆ្នាំ១៩៩១។ ឥលូវនេះ ពួកគេបានបញ្ជូនបេសកជនប្រហែល១៥នាក់ (អ្នកបណ្តុះក្រុមជំនុំ) អោយចាប់ផ្តើមធ្វើការ។

ខាងក្រោមនេះជាគោលដៅដែលគេបានដាក់។ ក្រុមជំនុំចំនួន៩៦ ដែលមានហើយស្រាប់មានសង្ឃឹមក្នុងការធ្វើផែនការបង្កើត៤៦៩ក្រុមជំនុំទៀតនៅ៥ឆ្នាំបន្ទាប់ ព្រមទាំងបានដាក់គោលដៅនៃ "**អ**" ដែលនឹងមានក្រុមជំនុំចំនួន១៩០០ទៀត។ នោះចំនួនក្រុមជំនុំដែលធៀបទៅនឹងចំនួនប្រជាជនគឺ ក្រុមជំនុំមួយអាចមានសមាជិក ៣,៣៣៤នាក់។

**ប្រទេសអ៊ុយក្រែន**

ការបំផុសបំផុលបានកើតមានឡើងក្នុងប្រទេសអ៊ុយក្រែន ហើយជាលទ្ធផលមានក្រុមជំនុំជាច្រើនកំពុងតែត្រូវបានបណ្តុះឡើង។ និកាយទាំង២ គឺបាប់ទីស និង ថ្ងៃទី៥០ បានដាកគោលដៅសំរាប់ការបណ្តុះក្រុមជំនុំជាច្រើន។ ការជួយជំរុញអោយមានការផុលផុសគឺជាព័ន្ធកិច្ចដែលបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំ។ នៅក្នុងកំឡុងឆ្នាំ ១៩៩២ដល់ឆ្នាំ ១៩៩៨ ការបណ្តុះបណ្តាលជាលក្ខណៈអន្តរជាតិរបស់និកាយបាប់ទីសនិងអ្នកបណ្តុះក្រុមជំនុំ បានជួយបណ្តុះអោយមានក្រុមជំនុំចំនួន៣២៧ និង ចាប់ផ្តើមក្រុមតាមផ្ទះបាន៤៦៥ក្រុម ព្រមទាំងបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំបាន ៧៤៨នាក់ នៅ១៧ កន្លែង។

ជាលទ្ធផល ការផ្តោតអារម្មណ៍លើការបណ្តុះក្រុមជំនុំគឺស្ថិតនៅក្នុងប្រទេស ហើយអ្នកជឿជនជាតិអ៊ុយក្រែនសព្វថ្ងៃនេះកំពុងតែដាំក្រុមជំនុំក្នុងប្រទេសដទៃទៀតដែលជាអតីតប្រទេសកុម្មុយនិស្តផងដែរ។

**ប្រទេសរ៉ូម៉ានា**

បច្ចុប្បន្ននេះក្រុមមួយដែលមានជនជាតិរ៉ូម៉ានា៥នាក់បំរើការជាក្រុមនៃ**កកគជាតិ**។ ក្រុមនេះបានបណ្តុះបណ្តាលនិងបង្រួបបង្រួមដល់ក្រុមដែលមកពីក្រុមជំនុំតំបន់នានាចេញពី១៨ប្រទេស។ ក្រុមតាមស្រុកផ្សេងៗប្រើប្រាសគោលការណ៍ដូចគ្នាទៅនឹងក្រុមជាតិដែរ គឺប្រើទៅតាមកំរិតតំបន់។ ក្រុមតាមតំបន់ទាំងនេះ ជួយដល់ក្រុមជំនុំអោយមាននិមិត្តដើម្បីបណ្តុះក្រុមជំនុំ និងជួយគេអោយចេះបង្រួបបង្រួមប្រជាជននៃគេ ព្រមទាំងអោយអ្នកទាំងនោះចេះបណ្តុះបណ្តាលផងដែរ។ តើពួកគេមានប្រសិទ្ធិភាពដែររឺទេ?

នៅឆ្នាំ១៩៩៦ ក្រុមជំនុំចំនួន ១៩ និងអ្នកបណ្តុះបណ្តាលចំនួន៣៦នាក់ត្រូវបានរៀបចំឡើងដោយក្រុមទាំងនេះ។ នៅឆ្នាំ១៩៩៨ ក្រុមដដែលនេះបានជួយដាំក្រុមជំនុំបាន៧៦ ព្រមទាំងរៀបចំអោយមានអ្នកបណ្តុះបណ្តាលបានចំនួន១២៦នាក់។

ក្រុមទាំងនេះបានបណ្តុះក្រុមជំនុំតំបន់ ១៨កន្លែង នៅឆ្នាំ ១៩៩៦ ។ មកដល់ឆ្នាំ ១៩៩៨ ពួកគេមាន៦៧កន្លែង ។

ក្រុមជាតិនិងក្រុមតំបន់បានធ្វើការស្រាវជ្រាវពីការបណ្តុះក្រុមជំនុំរួមគ្នា ។ ដោយព្រោះតែការស្រាវជ្រាវនេះក្រុមទាំងនេះក៏កំពុងបើកសន្និបាតតាមភូមិភាគជាមួយគ្រូគង្វាលតាមតំបន់និងភូមិភាគដែរ ។ ក្រុមទាំងនេះបង្ហាញថា ការបណ្តុះក្រុមជំនុំ គឺស្ថិតក្នុងភាពអន់ថយនៅប្រទេសរ៉ូម៉ានា ហើយនៅក៏រិតនៃការលូតលាស់បច្ចុប្បន្ន ក្រុមជំនុំនៅរ៉ូម៉ានានឹងមិនអាចឈោងចាប់ប្រជាជនរ៉ូម៉ានាជំនាន់នេះបានទេ ។ ពួកគេកំពុងតែធ្វើការអញ្ជើញក្រុមជំនុំបន្ថែមហើយបន្ថែមទៀត ដើម្បីរួមដៃគ្នា និងបណ្តុះបណ្តាល ដល់ក្រុមជំនុំដែលត្រូវបណ្តុះឡើងបន្ថែមទៀត ។

✝✝✝✝

# ជំហានបន្ទាប់



- ✓ ចែកចាយនិមិត្តដើម្បីការបណ្តុះក្រុមជំនុំ។
- ✓ ហៅមនុស្សដើម្បីអធិដ្ឋានសំរាប់ការបណ្តុះក្រុមជំនុំ។
- ✓ ស្វែងរកដៃគូមានចិត្តគំនិតដូចគ្នា ដែលជាអ្នកចង់បណ្តុះក្រុមជំនុំ។
- ✓ រៀបចំជាការជួបជុំរីកសន្និបាតមួយក្នុងទីក្រុងរបស់អ្នករឺក៏តំបន់ដើម្បីផ្សព្វផ្សាយនិមិត្តនៃការបណ្តុះក្រុមជំនុំ។
- ✓ ធ្វើការស្រាវជ្រាវអំពី កំលាំងចំរូត និងទីលានចំរូត។
- ✓ ធ្វើផែនការយុទ្ធសាស្ត្រ ដើម្បីបណ្តុះក្រុមជំនុំបន្ថែម។
- ✓ អភិវឌ្ឍការបណ្តុះបណ្តាលនៃអ្នកបណ្តុះក្រុមជំនុំ។

# ការយល់ដឹងអំពី Alliance

**Alliance** គឺជាបណ្តាញក្រុមជំនុំនិងភ្នាក់ងារបេសកកម្ម បង្កើតឡើងក្នុងការបង្រួបបង្រួមអ្នកមានជំនឿ ដើម្បី ផ្សព្វផ្សាយក្រុមជំនុំដំនឹងល្អដល់ភូមិភាគកណ្តាលនិងខាងកើតនៃអឺរ៉ុប ព្រមទាំងអតីតសហភាពសូវៀត ។ ការបណ្តុះក្រុមជំនុំគ្រប់ទិសទី គឺជាយុទ្ធសាស្ត្រដែលស្វែងរកដើម្បីបង្កើតក្រុមជំនុំតំបន់នៅគ្រប់ទាំងទីក្រុង ភូមិ និងអ្នកជិតខាង ដើម្បីធ្វើអោយអ្នកដែលទទួលយកព្រះយេស៊ូគ្រីស្ទ អាចមានឱកាសប្រកបគ្នាតាមតំបន់ ដែលធ្វើអោយមានការរីកលូតលាស់ក្នុងព្រះគ្រីស្ទ និងទទួលការបំពាក់បំប៉នសំរាប់ព័ន្ធកិច្ច ។ **Alliance** ត្រូវបានសាងសង់ឡើងលើទីតាំងមាំមួនដែលកំលាំងចូលរួម នឹង មានការកើនឡើងយ៉ាងមានប្រសិទ្ធិភាព កាត់បន្ថយនូវការងារជាន់គ្នា និងបង្ហាញពីការរួមរួមក្នុងរូបកាយនៃព្រះគ្រីស្ទ ។

### អ្វីដែលយើងជឿ

- ក្រុមជំនុំតំបន់គឺជាឧបករណ៏ជាចំបងរបស់ព្រះសំរាប់ផ្សាយដំនឹងល្អនិងបង្កើតសិស្ស ។
- ភាពជាដៃគូជាមួយនឹងក្រុមជំនុំនិងស្ថាប័នបេសកកម្មគឺសំខាន់ណាស់ ចំពោះការធ្វើពហុគុណ នៃក្រុមជំនុំតំបន់និងការអភិវឌ្ឍន៏ចលនានៃការបណ្តុះក្រុមជំនុំគ្រប់ទិសទី ។
- ការបណ្តុះបណ្តាលអ្នកដឹកនាំ ជាកត្តាសំខាន់ដើម្បីបណ្តុះក្រុមជំនុំនិងអភិវឌ្ឍក្រុមជំនុំអោយលូតលាស់ឡើង ។

### អ្វីដែលយើងធ្វើ

#### ការអប់រំប្រៀនប្រដៅនិងការបណ្តុះបណ្តាលអ្នកបណ្តុះក្រុមជំនុំ

**Alliance** ផ្តល់នូវជំនាញជាមូលដ្ឋានក្នុងលក្ខណៈជាសិក្ខាសាលាជាមួយនឹងកិច្ចការព័ន្ធកិច្ចជាក់ស្តែងឆ្ពោះទៅរកការចាប់ផ្តើមក្រុមជំនុំដែលអាចបង្កើតក្រុមជំនុំថ្មីបន្តទៀត ។

#### ការប្រមូលពតិមាន

**Alliance** អាចជួយក្នុងការបណ្តុះបណ្តាល និងផ្តល់ជាយោបល់ក្នុងការស្រាវជ្រាវ ព្រមទាំងប្រមូលពតិមានក្នុងតំបន់នៃការបណ្តុះក្រុមជំនុំ និងការលូតលាស់នៃក្រុមជំនុំ ។

#### ការជួយជាយោបល់ក្នុងចលនានៃការអធិដ្ឋាន

**Alliance** អាចជួយអ្នកអោយយល់ច្បាស់ជាងពីតួនាទីនៃចលនាអធិដ្ឋាននៅក្នុងកិច្ចការបណ្តុះក្រុមជំនុំ និងរបៀបដែល អ្នកអាចសំរបសំរួលចលនានៃការអធិដ្ឋានក្នុងភូមិភាគរបស់អ្នក ។

#### ការបំផុសនិមិត្ត

**Alliance** អាចជួយអ្នកក្នុងការបំផុសនិមិត្តសំរាប់ក្រុមជំនុំថ្មីជាមួយនឹងការបង្កើតគំនិតសំរាប់ សិក្ខាសាលានៅលើគោលការណ៏ នៃការបណ្តុះក្រុមជំនុំគ្រប់ទិសទី ។៚